

សង្ខេបរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល

២០២០

# បរិយាបន្ន និងការអប់រំ៖

## ទាំងអស់គ្នា មានន័យថា យើងទាំងអស់គ្នា

UNESCO
United Nations
Educational, Scientific and
Cultural Organization

Sustainable
Development
Goals

Global
Education
Monitoring
Report

## សង្ខេបរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល

## ២០២០

# បរិយាបន្ន
# និងការអប់រំ៖

## ទាំងអស់គ្នា មានន័យថា យើងទាំងអស់គ្នា

ISBN: 978-92-3-100388-2
Phnom Penh, July 2020
Language: Khmer
Original: English

សេចក្តីប្រកាសអ៊ីនឈ័ន និងក្របខ័ណ្ឌសកម្មភាពវិស័យអប់រំ ឆ្នាំ ២០៣០ ចែងថា របាយការណ៍ពិនិត្យតាមដានការអប់រំជាសកល មានតួនាទីជា "យន្តការសម្រាប់ពិនិត្យតាមដាន និងរាយការណ៍ពីគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ និងពីការអប់រំដែលត្រូវបានបញ្ចូលទៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្សេងទៀត" និង "រាយការណ៍ពីការអនុវត្តយុទ្ធសាស្ត្រជាតិ និងអន្តរជាតិ ដើម្បីទាមទារឱ្យគ្រប់ដៃគូពាក់ព័ន្ធទាំងអស់មានគណនេយ្យភាពចំពោះអ្វីដែលពួកគេបានសន្យា ជាផ្នែកមួយនៃការតាមដានបន្ត និងការពិនិត្យលើគោលដៅអភិវឌ្ឍន៍ដោយចីរភាពជារួម"។ របាយការណ៍នេះត្រូវបានរៀបចំឡើងដោយអ្នកជំនាញឯករាជ្យមួយក្រុម ក្រោមការដឹកនាំរបស់យូណេស្កូ។

ឈ្មោះ តួនាទី ដែលត្រូវបានប្រើប្រាស់ និងព័ត៌មានដែលបង្ហាញក្នុងឯកសារបោះពុម្ពផ្សាយនេះ មិនមែនជាការបញ្ចេញមតិរបស់យូណេស្កូ ពាក់ព័ន្ធនឹងស្ថានភាពស្របច្បាប់របស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ណាមួយ ឬសមត្ថកិច្ចរបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់នេះ ឬពាក់ព័ន្ធនឹងការកំណត់ព្រំប្រទល់ដែនរបស់ប្រទេស ដែនដី ទីក្រុង ឬតំបន់ទាំងនេះឡើយ។

ក្រុមការងាររៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកលនេះ គឺជាអ្នកទទួលខុសត្រូវលើការជ្រើសរើស និងការបង្ហាញអង្គហេតុ ក្នុងឯកសារបោះពុម្ពផ្សាយនេះ និងលើទស្សនៈដែលត្រូវបានបញ្ចេញក្នុងឯកសារនេះ។ ទស្សនៈទាំងនេះមិនមែនជាទស្សនៈយូណេស្កូ ហើយមិនតម្រូវឲ្យយូណេស្កូជាប់កាតព្វកិច្ចអ្វីមួយឡើយ។ ប្រធានក្រុមការងារនេះជាអ្នកទទួលខុសត្រូវជារួមលើគំនិតយោបល់ និងទស្សនៈយល់ឃើញ ដែលត្រូវបានលើកឡើងក្នុងរបាយការណ៍នេះ។

**ក្រុមការងាររៀបចំរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល**

ប្រធានក្រុម៖ Manos Antoninis

ក្រុម៖ Daniel April, Bilal Barakat, Madeleine Barry, Nicole Bella, Erin Chemery, Anna Cristina D´Addio, Matthias Eck, Francesca Endrizzi, Glen Hertelendy, Priyadarshani Joshi, Katarzyna Kubacka, Milagros Lechleiter, Kate Linkins, Leila Loupis, Kassiani Lythrangomitis, Alasdair McWilliam, Anissa Mechtar, Claudine Mukizwa, Yuki Murakami, Carlos Alfonso Obregón Melgar, Judith Randrianatoavina, Kate Redman, Maria Rojnov, Anna Ewa Ruszkiewicz, Will Smith, Laura Stipanovic, Morgan Strecker, Rosa Vidarte និង Lema Zekrya.

សហការី៖ Madhuri Agarwal, Gabriel Badescu, Donny Baum and Enrique Valencia-Lopez

របាយការណ៍ពិនិត្យតាមដានការអប់រំជាសកលនេះ គឺជាឯកសារបោះពុម្ពផ្សាយឯករាជ្យប្រចាំឆ្នាំ។ របាយការណ៍ GEM នេះត្រូវបានរៀបចំឡើង ក្រោមការឧបត្ថម្ភថវិកាពីរដ្ឋាភិបាល ទីភ្នាក់ងារពហុភាគី និងមូលនិធិឯកជន និងមានការសម្របសម្រួល និងការគាំទ្រពីយូណេស្កូ។

ឯកសារបោះពុម្ពផ្សាយនេះត្រូវបានផ្សព្វផ្សាយឱ្យមានការប្រើប្រាស់ជាចំហ ក្រោមអាជ្ញាប័ណ្ណ Attribution-ShareAlike 3.0 IGO ( CC-BY-SA 3.0 IGO ) license ( http://creativecommons.org/licenses/by-sa/3.0/igo/ ) ។ តាមរយៈការដកស្រង់ខ្លឹមសារពីឯកសារបោះពុម្ពផ្សាយនេះទៅប្រើប្រាស់ អ្នកប្រើប្រាស់ទទួលថាខ្លួននឹងជាប់កាតព្វកិច្ចគោរពតាមលក្ខខណ្ឌនៃការប្រើប្រាស់ ដែលកំណត់ដោយបណ្ណាល័យដែលអាចចូលប្រើប្រាស់ដោយសេរីរបស់យូណេស្កូ ( http://www. unesco.org/open-access/terms-use-ccbysa-en ) ។

អាជ្ញាប័ណ្ណនេះអនុវត្តទាំងស្រុងចំពោះខ្លឹមសារអត្ថបទនៃឯកសារនេះ។ សម្រាប់ការប្រើប្រាស់ខ្លឹមសារទាំងឡាយដែលពុំត្រូវបានកំណត់ជាក់ច្បាស់ថាជារបស់យូណេស្កូ ចាំបាច់ត្រូវមានការស្នើសុំការអនុញ្ញាតជាមុនពី៖ publication.copyright@unesco.org ឬ UNESCO Publishing, 7, place de Fontenoy, 75352 Paris 07 SP France.

ចំណងជើងដើមជាភាសាអង់គ្លេស៖ Global Education Monitoring Report Summary 2020: Inclusion and education: All means all

ឈ្មោះឯកសារយោង នៃរបាយការណ៍នេះ៖ UNESCO. 2020. Global Education Monitoring Report Summary 2020: Inclusion and education: All means all. Paris, UNESCO.

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**

ក្រុមរៀបចំរបាយការណ៍ពិនិត្យតាមដានស្ថានភាពនៃការអប់រំទូទាំងសកលលោក
អង្គការយូណេស្កូ អាសយដ្ឋាន 7, place de Fontenoy
75352 Paris 07 SP, France
Email: gemreport@unesco.org
Tel.: +33 1 45 68 07 41
www.unesco.org/gemreport
https://gemreportunesco.wordpress.com

រាល់កំហុស ឬការខ្វះព័ត៌មាន ដែលរកឃើញក្រោយពេលបោះពុម្ពនឹងត្រូវកែតម្រូវ ក្នុងសំណៅអនឡាញនៃឯកសារនេះដែលអាចរកបានតាមរយៈគេហទំព័រ

www.unesco.org/gemreport

© UNESCO, 2020

First edition
Published in 2020 by the United Nations Educational, Scientific and Cultural Organization

7, Place de Fontenoy, 75352
Paris 07 SP, France

Typeset by UNESCO
Graphic design by FHI 360
Layout by UNESCO

**របាយការណ៍ពិនិត្យតាមដានស្ថានភាពនៃការអប់រំជាសកល៖**

- ២០២០ បរិយាប័ន្ន និងការអប់រំ៖ ទាំងអស់គ្នា មានន័យថាទាំងអស់គ្នា
- ២០១៩ ការធ្វើចំណាកស្រុក ការផ្លាស់ទីលំនៅដោយបង្ខំ និងការអប់រំ៖ សង់ស្ពានចម្លង មិនមែនសង់ជញ្ជាំងនោះទេ
- ២០១៧/៨ គណនេយ្យភាព ក្នុងវិស័យអប់រំ៖ គោរពតាមអ្វីដែលយើងបានសន្យា
- ២០១៦ ការអប់រំ សម្រាប់មនុស្ស និងផែនដី៖ បង្កើតអនាគតប្រកបដោយនិរន្តរភាព សម្រាប់ទាំងអស់គ្នា

**របាយការណ៍ពិនិត្យតាមដានទូទាំងសកលលោក សម្រាប់ការអប់រំសម្រាប់ទាំងអស់គ្នា**

- ២០១៥ ការអប់រំសម្រាប់ទាំងអស់គ្នា ២០០០-២០១៥៖ សមិទ្ធផលសម្រេចបាន និងបញ្ហាប្រឈម
- ២០១៣/៤ ការបង្រៀន និងរៀន៖ សម្រេចឲ្យបាននូវគុណភាព សម្រាប់ទាំងអស់គ្នា
- ២០១២ យុវជន និងជំនាញ៖ ប្រែក្លាយការអប់រំ ជាការបំពេញការងារ
- ២០១១ វិបត្តិលាក់មុខ៖ ជម្លោះប្រដាប់អាវុធ និងការអប់រំ
- ២០១០ ការផ្តល់សេវាដល់ក្រុមដែលពុំមានឱកាស
- ២០០៩ ការជំនះវិសមភាព៖ ហេតុអ្វីបានជាអភិបាលកិច្ចមានសារៈសំខាន់
- ២០០៨ ការអប់រំសម្រាប់ទាំងអស់គ្នាត្រឹមឆ្នាំ ២០១៥៖ តើយើងអាចសម្រេចវាបានដែរឬទេ ?
- ២០០៧ មូលដ្ឋានរឹងមាំ៖ ការគាំពារ និងអប់រំកុមារតូច
- ២០០៦ អក្ខរកម្ម ដើម្បីជីវិត
- ២០០៥ ការអប់រំសម្រាប់ទាំងអស់គ្នា៖ គុណភាពដែលចាំបាច់ត្រូវមាន
- ២០០៣/៤ យេនឌ័រ និងការអប់រំសម្រាប់ទាំងអស់គ្នា៖ ការបោះជំហានទៅរកសមភាព
- ២០០២ ការអប់រំសម្រាប់ទាំងអស់គ្នា៖ តើពិភពលោកស្ថិតតាមផែនការដែលបានគ្រោងទុកដែរឬទេ ?

របាយការណ៍សង្ខេប និងឯកសារពាក់ព័ន្ធនានា អាចដោនឡូតពី៖ http://bit.ly/2020gemreport

# អារម្ភកថា

ការធ្វើឱ្យការអប់រំក្លាយជាសិទ្ធិសកល និងក្លាយជាតថភាព សម្រាប់ទាំងអស់គ្នា សម្រាប់ពេលនេះ គឺសំខាន់ជាងពេលណាណាទាំងអស់។ ពិភពលោកដែលពោរពេញដោយដោយការផ្លាស់ប្តូរដ៏ឆាប់រហ័សរបស់យើង កំពុងជួបប្រទះនឹងបញ្ហាប្រឈមធំៗជាច្រើន ចាប់ពីការរំខានដោយសារបច្ចេកវិទ្យា រហូតដល់ការប្រែប្រួលអាកាសធាតុ ជម្លោះ ការផ្លាស់ទីរបស់មនុស្សដោយបង្ខំ ការមិនចេះយល់អាធ្យាស្រ័យដល់គ្នា និងការស្អប់ខ្ពើមគ្នា ធ្វើឱ្យវិសមភាពកាន់តែមានទំហំធំឡើងៗ និងបង្កផលប៉ះពាល់រាប់ទសវត្សរ៍ទៅមុខទៀត។

ចំពោះមុខបញ្ហាប្រឈមទាំងនេះ សារដែលត្រូវបានរំលេចក្នុងរបាយការណ៍ពិនិត្យតាមដានការអប់រំជាសកល ឆ្នាំ ២០២០ ក្រោមចំណងជើងបរិយាប័ន្ន ក្នុងការអប់រំ កាន់តែមានភាពមុតស្រួចទៅទៀត។ របាយការណ៍នេះលើកឡើងថា ឱកាសទទួលបានការអប់រំនៅតែពុំទាន់បានបែងចែកឱ្យស្មើភាពគ្នានៅឡើយ។ ឧបសគ្គដែលធ្វើឱ្យរាំងស្ទះដល់ការអប់រំប្រកបដោយគុណភាព នៅតែមានកម្រិតខ្ពស់ខ្លាំង សម្រាប់អ្នកសិក្សាជាច្រើននាក់។ សូម្បីតែមុនពេលមានវិបត្តិកូវីដ ១៩ ក្នុងចំណោមកុមារ ក្មេងជំទង់ និងយុវវ័យ ៥ នាក់ មាន ១ នាក់ដែលត្រូវបានផាត់ចេញទាំងស្រុងពីការអប់រំ។ ការមាក់ងាយ ការប្រកាន់ផ្នត់គំនិតអវិជ្ជមាន និងការរើសអើង ធ្វើឱ្យអ្នកសិក្សារាប់លាននាក់ទៀតត្រូវបានផាត់ចេញពីការរៀនសូត្រ បើទោះបីជាពួកគេនៅក្នុងថ្នាក់រៀនយ៉ាងណាក៏ដោយ។

វិបត្តិដែលកំពុងកើតមាននាពេលបច្ចុប្បន្ននេះ នឹងធ្វើឱ្យការផាត់ចេញក្នុងទម្រង់ទាំងនេះ កើតឡើងបន្តទៀត។ ជាមួយនឹងសិស្សក្នុងសកលលោក ជាង ៩០ ភាគរយ រងផលប៉ះពាល់ ដោយសារតែការបិទសាលារៀន ព្រោះតែជំងឺកូវីដ ១៩ ពិភពលោកកំពុងជួបប្រទះនឹងការរំខានដ៏ធំបំផុតមិនធ្លាប់មាន ក្នុងប្រវត្តិនៃការអប់រំ។ ការបែងចែកក្នុងសង្គម និងគម្លាតឌីជីថល ធ្វើឱ្យក្រុមដែលជួបការលំបាកជាងគេ ប្រឈមនឹងការបាត់បង់ការរៀនសូត្រ និងបោះបង់ចោលការសិក្សា។ មេរៀនពីអតីតកាល ដូចជា ពេលផ្ទុះជំងឺអេបូឡា ជាដើម បានបង្ហាញថា វិបត្តិសុខភាពអាចធ្វើឱ្យមនុស្សជាច្រើននាក់ត្រូវបានគេទុកចោល ជាពិសេស ក្មេងស្រីដែលមានជីវភាពក្រីក្រជាងគេ ដោយពួកគេជាច្រើននាក់អាចនឹងមិនវិលត្រលប់ទៅកាន់សាលារៀនវិញឡើយ។

អនុសាសន៍សំខាន់ៗក្នុងរបាយការណ៍នេះ ដែលស្នើឱ្យគ្រប់តួអង្គទាំងអស់ក្នុងវិស័យអប់រំពង្រីកវិសាលភាពការយល់ដឹងរបស់ពួកគេអំពីការអប់រំបរិយាប័ន្ន ដើម្បីបញ្ចូលអ្នកសិក្សាគ្រប់រូប ដោយមិនគិតពីអត្តសញ្ញាណ សាវតារ ឬសមត្ថភាពរបស់ពួកគេ ត្រូវបានផ្តល់ចំពេលដែលពិភពលោកខិតខំស្តារប្រព័ន្ធអប់រំឱ្យកាន់តែមានលក្ខណៈបរិយាប័ន្នជាងមុន។

របាយការណ៍នេះ បានបង្ហាញពីការផាត់ចេញក្នុងទម្រង់ជាច្រើនផ្សេងៗគ្នា មូលហេតុដែលនាំឱ្យមានការផាត់ចេញទាំងនោះ និងអ្វីដែលយើងអាចធ្វើបាន ដើម្បីដោះស្រាយបញ្ហាទាំងនេះ។ ដូច្នេះរបាយការណ៍នេះ គឺជាការអំពាវនាវឱ្យមានការយកចិត្តទុកដាក់ចំពោះសកម្មភាពមួយចំនួន ខណៈពេលដែលយើងកំពុងរិះរកវិធីកសាងភាពធន់ និងសមភាពក្នុងសង្គម នាពេលអនាគត។ របាយការណ៍នេះជាការការអំពាវនាវឱ្យមានការប្រមូលទិន្នន័យកាន់តែប្រសើរ ព្រោះថាប្រសិនបើពុំមានទិន្នន័យនោះទេ យើងមិនអាចយល់ និងវាស់វែងវិសាលភាពពិតប្រាកដនៃបញ្ហានេះឡើយ។ របាយការណ៍នេះជាការអំពាវនាវឱ្យមានការរៀបចំគោលនយោបាយសាធារណៈ ឱ្យកាន់តែមានបរិយាបន្នជាងពេលបច្ចុប្បន្ននេះ ដោយប្រើប្រាស់ឧទាហរណ៍អំពីគោលនយោបាយប្រកបដោយប្រសិទ្ធភាព ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ននេះ ធ្វើជា

គំរូ និងធ្វើការរួមគ្នា ដើម្បីឆ្លើយតបចំពោះបញ្ហាប្រសព្វគ្នាមួយចំនួន ដែលក្រសួងស្ថាប័ននានារបស់រដ្ឋាភិបាលអាចដោះស្រាយបាន ដូចដែលអ្វីដែលយើងបានមើលឃើញ ពីសមត្ថភាពដោះស្រាយរបស់ក្រសួងស្ថាប័នទាំងនេះ ក្នុងអំឡុងនៃវិបត្តិកូវីដ ១៩។

មានតែតាមរយៈការរៀនសូត្រពីរបាយការណ៍នេះតែប៉ុណ្ណោះ ដែលធ្វើឱ្យយើងអាចយល់ពីមាគ៌ាដែលយើងត្រូវដើរតាមនាពេលអនាគត។ យូណេស្កូត្រៀមខ្លួនរួចជាស្រេចដើម្បីជួយដល់បណ្តារដ្ឋនានា ក៏ដូចជាសហគមន៍អប់រំ ដើម្បីឱ្យយើងទាំងអស់គ្នាអាចអភិវឌ្ឍវិស័យអប់រំដែលពិភពលោកកំពុងត្រូវការជាចាំបាច់យ៉ាងខ្លាំង និងធានាថាការរៀនសូត្រនឹងនៅតែមានជាបន្តឥតឈប់។

ដើម្បីជម្នះបញ្ហាប្រឈមក្នុងជំនាន់របស់យើងនេះ ការបោះជំហានទៅរកការអប់រំដែលកាន់តែមានបរិយាបន្នគឺជាអ្វីដែលត្រូវធ្វើឱ្យខាងតែបាន។ ការខកខានពុំបានធ្វើសកម្មភាព លែងជាជម្រើសទៀតហើយ។

អូដ្រេយ អាហ្សូឡាយ (Audrey Azoulay)
អគ្គនាយកយូណេស្កូ



# អារម្ភកថា

ការអប់រំជាការរួមចំណែកដ៏សំខាន់ និងចាំបាច់ ក្នុងការកសាងសង្គមប្រជាធិបតេយ្យ ដែលមានលក្ខណៈបរិយាបន្ន ដែលក្នុងនោះអាចមានការបញ្ចេញមតិយោបល់ខុសៗគ្នាដោយសេរី ហើយអ្នកដែលមានសំឡេងខុសៗគ្នាអាចត្រូវបានគេស្តាប់ឮ ដើម្បីលើកកម្ពស់ភាពចុះសម្រុងគ្នាក្នុងសង្គម និងអបអរសាទរទទួលយកភាពចម្រុះ។

របាយការណ៍ពិនិត្យតាមដានការអប់រំជាសកល នៅឆ្នាំនេះរំឭកប្រាប់យើងថា ប្រព័ន្ធអប់រំអាចមានបរិយាបន្នតែត្រឹមកម្រិតដែលអ្នកបង្កើតប្រព័ន្ធអប់រំចង់ឱ្យមានតែប៉ុណ្ណោះ។ ប្រព័ន្ធបែបនេះ ព្រមទាំងបរិបទជុំវិញ គឺជាកត្តាដែលអាចធ្វើឱ្យអ្នកសិក្សាមួយចំនួនជួបការលំបាក។ ការលំបាកកើតឡើង នៅពេលដែលពុំមានការពិចារណាលើតម្រូវការរបស់អ្នកសិក្សា។

បរិយាបន្នក្នុងការអប់រំ សំដៅលើការធានាយ៉ាងណាឱ្យអ្នកសិក្សាគ្រប់រូបមានអារម្មណ៍ថាខ្លួនត្រូវបានគេឱ្យតម្លៃ និងគោរព និងអាចដឹងច្បាស់ថា ពួកគេក៏ជាសមាជិកនៅក្នុងសហគមន៍អប់រំផងដែរ។ ទោះជាយ៉ាងណាក៏ដោយ មានឧបសគ្គជាច្រើនដែលធ្វើឱ្យរាំងស្ទះដល់ការការសម្រេចបាននូវស្ថានភាពដែលល្អឥតខ្ចោះបែបនេះ។ ការរើសអើង ការប្រកាន់ផ្នត់គំនិត និងការចាត់ទុកក្រុមណាមួយថាជាក្រុមខុសប្លែកពីគេ អាចជាកត្តាដែលនាំឱ្យមានការផាត់ចេញមនុស្សជាច្រើននាក់។ យន្តការដែលនាំឱ្យមានការផាត់ចេញទាំងនេះសុទ្ធតែមានលក្ខណៈដូចគ្នាដោយមិនគិតថាតើការផាត់ចេញទាំងនេះធ្វើឡើងដោយសារយេនឌ័រ ទីតាំង ទ្រព្យធន ពិការភាព ជនជាតិភាគតិច ភាសា ការធ្វើចំណាកស្រុក ការបាត់បង់ទីលំនៅ និន្នាការភេទ ការជាប់ឃុំឃាំង សាសនា និងការប្រកាន់ជំនឿ និងឥរិយាបថដទៃទៀតនោះឡើយ។

របាយការណ៍នេះរំឭកប្រាប់យើងពីបញ្ហាវិសមភាពក្នុងការអប់រំ ដែលនៅតែបន្តកើតមាន និងពីការធានាឱ្យទាំងអស់គ្នាអាចចូលរៀន ដែលគួរជាមូលដ្ឋានគ្រឹះនៃបរិយាបន្ន។ ប៉ុន្តែគោលវិធីលើកកម្ពស់បរិយាបន្ន "ទាំងអស់គ្នា មានន័យថាទាំងអស់គ្នា" ក៏មានន័យថា គេត្រូវទម្លាក់ចោលនូវការដាក់ស្លាកសម្គាល់បែបមាក់ងាយមកលើកុមារមួយចំនួនផងដែរ។ ការអនុវត្តគោលវិធីសិក្សាដោយប្រើប្រាស់ស្លាកសម្គាល់បែបនេះ ជាកត្តាដាក់កំហិតលើសក្តានុពលរបស់កុមារទាំងនោះ និងជាការព្រងើយកន្តើយចំពោះអត្ថប្រយោជន៍ដែលគោលវិធីសិក្សាខុសៗគ្នាអាចផ្តល់ឱ្យកុមារគ្រប់រូប។

ដូច្នេះរបៀបរៀបចំប្រព័ន្ធអប់រំគឺជាកត្តាសំខាន់។ ប្រទេសនានាអាចជ្រើសរើសផ្តោតលើអ្វីដែលសំខាន់នៅពេលធ្វើការកំណត់ថាតើប្រព័ន្ធអប់រំរបស់ខ្លួនកំពុងដើរតាមផ្លូវត្រូវ ឬអត់។ ពួកគេអាចសម្រេចចិត្តឆ្លើយតបចំពោះរបៀបវារៈបរិយាបន្ន ដោយប្រើប្រាស់គោលវិធីម្តងដោះស្រាយបញ្ហានេះ ម្តងដោះស្រាយបញ្ហានោះ ឬពួកគេអាចឆ្លើយតបចំពោះបញ្ហាប្រឈមទាំងមូលតែម្តង។

មានការលំបាក និងភាពតានតឹងជាច្រើន ដែលត្រូវដោះស្រាយ ដើម្បីឈានទៅលើកកម្ពស់បរិយាបន្នឱ្យបានពេញលេញ។ ការផ្លាស់ទីចេញពីកន្លែងរបស់យើងបច្ចុប្បន្ន ទៅការបង្កើតនូវប្រព័ន្ធមួយ ដែលយកចិត្តទុកដាក់ចំពោះតម្រូវការរបស់អ្នកសិក្សាគ្រប់រូបរួមទាំងអ្នកសិក្សាដែលមានពិការភាពធ្ងន់ធ្ងរផងនោះ មិនមែនជារឿងតូចតាចនោះឡើយ ហើយអាចជារឿងដែលមិនអាចធ្វើបានទៀតបានផង។ ហើយរបាយការណ៍នេះពុំបានបដិសេធគំនិតដែលថា បរិយាបន្នពេញលេញ ក៏អាចមានគុណវិបត្តិផងដែរ នោះឡើយ។ កិច្ចខិតខំប្រឹងប្រែងដែលមានបំណងល្អ ដើម្បីបញ្ចូលអ្នកសិក្សា

គ្រប់រូបអាចក្លាយជាការបង្ខំឱ្យអនុលោមតាមការទទួលយកអត្តសញ្ញាណក្រុមដកចេញភាសាមួយចំនួនជាដើម។ ការទទួលស្គាល់ក្រុមដែលត្រូវបានផាត់ចេញ នឹងជួយពួកគេសម្រេចគោលបំណងបរិយាបន្ន អាចធ្វើឱ្យពួកគេកាន់តែមានឱកាសតិចតួច។ មានបញ្ហាប្រឈមជាក់ស្តែងដែលត្រូវដោះស្រាយផងដែរ ពេលធ្វើការកំណត់ពីល្បឿននៃការផ្លាស់ប្តូរ មិនថាសម្រាប់ប្រទេសអ្នកមានដែលចង់ដកឃ្លាចេញពីប្រព័ន្ធដែលដំបូងឡើយ ត្រូវបានបង្កើតឡើងផ្អែកតាមគោលការណ៍បែងចែកមនុស្សទៅតាមប្រភេទខុសៗគ្នា ឬសម្រាប់ប្រទេសក្រីក្រ ដែលចង់បង្កើតប្រព័ន្ធបរិយាបន្នពីទទេទៅ។

ដោយទទួលស្គាល់ពេញលេញពីបញ្ហាប្រឈមទាំងនេះ របាយការណ៍នេះចោទសួរថាតើការស្វែងរកហេតុផលសម្រាប់គាំទ្រឱ្យមានការអប់រំបរិយាបន្ន ជារឿងពិតជាចាំបាច់ដែរឬទេ។ របាយការណ៍នេះបានលើកឡើងថា ការជជែកវែកញែកអំពីអត្ថប្រយោជន៍នៃការអប់រំបរិយាបន្ន អាចមានសារៈសំខាន់ដូចគ្នានឹងការជជែកវែកញែកអំពីអត្ថប្រយោជន៍និងការលុបបំបាត់អំពើទាសភាព ឬសង្គមអាផាថេត (apartheid) ផងដែរ។ បរិយាបន្ននៅក្នុងការអប់រំគឺជាដំណើរការ មិនមែនជាគោលដៅចុងក្រោយនោះឡើយ ហើយនៅលើដំណើផ្លូវនេះ គេអាចធ្វើការផ្លាស់ប្តូរជាច្រើន ដោយមិនអស់ចំណាយ ដូចជា តាមរយៈការផ្លាស់ប្តូរវិធីសាស្រ្តរបស់គ្រូ គោលការណ៍ក្រមសីលធម៌ដែលអ្នកគ្រប់គ្រងសាលារៀនបង្កើត និងរបៀបដែលគ្រួសារធ្វើការសម្រេចចិត្តអំពីជម្រើសសាលារៀន និងអំពីអ្វីដែលយើងទាំងអស់គ្នាក្នុងនាមជាសង្គមទាំងមូលធ្វើការសម្រេចចិត្តពីអ្វីដែលយើងចង់បានសម្រាប់អនាគតរបស់យើង។

បរិយាបន្នមិនមែនត្រឹមតែជាការសម្រេចចិត្តរបស់ក្រុមអ្នកតាក់តែងគោលនយោបាយតែឯងនោះទេ។ ការកំណត់ពីអ្វីដែលត្រូវធ្វើពីខាងលើមក នឹងមិនមានប្រសិទ្ធភាពនោះឡើយ។ ដូច្នេះ សំណួរដែលសួរទៅកាន់អ្នកទាំងអស់គ្នាដែលជាអ្នកអានរបាយការណ៍នេះ គឺថាតើអ្នកទាំងអស់គ្នាបានត្រៀមខ្លួនដើម្បីតតាំងនឹងផ្នត់គំនិតបច្ចុប្បន្ននេះហើយឬនៅ និងថាតើអ្នកទាំងអស់គ្នាបានត្រៀមខ្លួនធ្វើការសម្រេចចិត្តថា ការអប់រំ គឺសម្រាប់ទាំងអស់គ្នា ហើយត្រូវតែខិតខំឱ្យមានបរិយាបន្នសម្រាប់ទាំងអស់គ្នា។

លោកជំទាវ Helen Clark<br>
ប្រធានក្រុមប្រឹក្សាភិបាលរៀបចំរបាយការណ៍<br>
ពិនិត្យតាមដានការអប់រំជាសកល



# សារគន្លឹះ

**អត្តសញ្ញាណ សាវតារ និងសមត្ថភាព ឥជាកត្តាកំណត់ពីឱកាសទទួលបានការអប់រំ**

នៅក្នុងប្រទេសទាំងអស់នៅអឺរ៉ុប និងអាមេរិកភាគខាងជើង លើកលែងតែប្រទេសដែលមានចំណូលខ្ពស់ក្នុងរៀងរាល់យុវជនមកពីគ្រួសារដែលមានជីវភាពធូរជាជាងគេ ១០០នាក់មានយុវជនមកពីគ្រួសារដែលមានជីវភាពក្រីក្រជាងគេតែ ១៨នាក់ប៉ុណ្ណោះដែលបានបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សា។ នៅក្នុងប្រទេសយ៉ាងហោចណាស់ចំនួន ២០ ភាគច្រើននៅអាហ្រ្វិកសាប់សាហារ៉ា កម្រមានស្រ្តីវ័យក្មេងក្រីក្ររស់នៅតាមតំបន់ជនបទណាបានបញ្ចប់ការអប់រំកម្រិតមធ្យមសិក្សាណាស់។

---

**យន្តការដែលនាំឱ្យមានការរើសអើង ការប្រកាន់ខ្ជាប់គំនិតអវិជ្ជមាន និងមាក់ងាយ មានលក្ខណៈស្រដៀងគ្នា សម្រាប់គ្រប់អ្នករៀនសូត្រទាំងអស់ដែលប្រឈមនឹងការផាត់ចេញពីសេវាអប់រំ**

ខណៈពេលដែលប្រទេស ៧៨% បានកំណត់និយមន័យការអប់រំបរិយាបន្ន មាននិយមន័យត្រឹមតែ ៥៧% នៃនិយមន័យទាំងនេះតែប៉ុណ្ណោះ ដែលគ្របដណ្តប់លើក្រុមដែលជួបប្រទះនឹងការលំបាកផ្សេងៗគ្នា។

---

**បើទោះបីជាមានការសម្រេចវឌ្ឍនភាពយ៉ាងណាក៏ដោយ ប្រទេសជាច្រើននៅពុំទាន់បានប្រមូលរាយការណ៍ ឬប្រើប្រាស់ទិន្នន័យអំពីអ្នកដែលត្រូវបានគេផាត់ចោលនៅឡើយ**

ចាប់តាំងពីឆ្នាំ ២០១៥ មក ប្រទេស ៤១% ដែលមានចំនួនប្រជាជនស្មើនឹង ១៣% នៃចំនួនប្រជាជនសរុបក្នុងសកលលោក ពុំបានធ្វើការអង្កេតតាមខ្នងផ្ទះជាសាធារណៈ ដើម្បីផ្តល់ទិន្នន័យបែងចែកតាមប្រភេទអំពីសូចនាករអប់រំសំខាន់ៗនោះឡើយ។ តំបន់ដែលបានធ្វើការអង្កេតបែបនេះតិចតួចជាងគេ គឺនៅអាហ្រ្វិកភាគខាងជើង និងអាស៊ីភាគខាងលិច។ ទិន្នន័យដែលប្រមូលបានកាលពីពេលថ្មីៗនេះក្នុងប្រទេសចំនួន ១៤ ដោយប្រើប្រាស់កម្រងសំណួរបំពេញស្តីពីពិការភាពរបស់ក្រុមវ៉ាស៊ីនតោនបង្ហាញថា ក្នុងចំណោមកុមារដែលឋិតនៅក្រៅសាលារៀន មាន ១៥% គឺជាកុមារមានពិការភាព។

---

**មនុស្សរាប់លាននាក់ ខកខានឱកាសរៀនសូត្រ**

ក្នុងប្រទេសដែលមានចំណូលមធ្យម បើទោះបីជាមានការកើនឡើង ២៥ ភាគរយចំណុច ក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយនេះក៏ដោយ មានកុមារត្រឹមតែ ៣ ភាគ ៤ ប៉ុណ្ណោះ ដែលបន្តរៀនក្នុងសាលា ដល់អាយុ ១៥ ឆ្នាំ។ ក្នុងចំណោមកុមារទាំងនេះ មានត្រឹមតែពាក់កណ្តាលប៉ុណ្ណោះដែលរៀនចេះត្រឹមកម្រិតមូលដ្ឋាន ជាអត្រាដែលនៅបន្តទ្រឹង រហូតដល់ពេលនេះ។ លើសពីនេះ ការវាយតម្លៃជាច្រើនប៉ាន់ប្រមាណពីលទ្ធផលសិក្សារបស់សិស្សលើសពីកម្រិតជាក់ស្តែង៖ នៅក្នុងការវាយតម្លៃថ្នាក់តំបន់មួយ ដែលធ្វើឡើងជាមួយប្រទេសចំនួន ១៥ នៅអាមេរិកឡាទីន សិស្ស ៣ ភាគ ៤ ដែលឆ្លើយសំណួរពហុចម្លើយ មិនទាំងបានល្អជាងការទាយចម្លើយផងនោះ ត្រូវបានគេចាត់ទុកថាចេះអានស្ទាត់ជំនាញ ។

---

**ឧបសគ្គដ៏សំខាន់មួយដែលធ្វើឱ្យរាំងស្ទះដល់ការលើកកម្ពស់បរិយាបន្នក្នុងការអប់រំ ឥការខ្វះការជឿជាក់ថា បរិយាបន្នឥជាអ្វីដែលអាចធ្វើបាន និងជាអ្វីដែលគួរឱ្យចង់បាន**

កាលពីឆ្នាំ ២០១៨ គ្រូ ១ នាក់ក្នុងចំណោមគ្រូ ៣ នាក់ នៅក្នុងប្រទេសចំនួន ៤៣ ដែលភាគច្រើនជាប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់ និងជាប្រទេសមានប្រាក់ចំណូលខ្ពស់ បានរាយការណ៍ថា ពួកគេពុំបានកែសម្រួលរបៀបបង្រៀន ឱ្យស្របតាមវប្បធម៌ចម្រុះរបស់សិស្សនោះឡើយ។

## ខណៈពេលដែលប្រទេសមួយចំនួនកំពុងឈ្មោះជំហានឆ្ពោះទៅរកបរិយាបន្ន ការបែងចែកសិស្សទៅតាមប្រភេទនៅតែជាអ្វីដែលកើតមានជាទូទៅ

ក្នុងករណីសិស្សមានពិការភាព ច្បាប់នៅក្នុងប្រទេស ២៥% (ប៉ុន្តែ ជាង ៤០% នៅអាស៊ី និងអាមេរិកឡាទីន និងការីបៀន) មានបញ្ញត្តិដែលចែងពីការអប់រំ សម្រាប់សិស្សប្រភេទខុសៗគ្នា, ១២% ចែងពីការអប់រំបែបរួមបញ្ចូលគ្នា និង ១៩% ចែងពីបរិយាបន្ន ហើយប្រទេសដែលនៅសេសសល់ចែងពីសេវាអប់រំ សម្រាប់សិស្សប្រភេទខុសៗគ្នា និងសេវាអប់រំសម្រាប់សិស្សភាគច្រើន។ ក្នុងប្រទេស OECD ជាងពីរភាគបីនៃសិស្សជាជនអន្តោប្រវេសន៍ រៀននៅសាលារៀន ដែលមានសិស្សយ៉ាងហោចណាស់ពាក់កណ្តាលជាជនអន្តោប្រវេសន៍។

---

## តម្រូវការហិរញ្ញប្បទាន ដើម្បីផ្តោតគោលដៅលើអ្នកដែលជួបការខ្វះខាតជាងគេ

ក្នុងប្រទេស OECD ចំនួន ៣២ សាលារៀន និងថ្នាក់រៀនដែលជួបការលំបាកខាងផ្នែកសង្គមសេដ្ឋកិច្ច ច្រើនតែមានគ្រូដែលមិនសូវមានសមត្ថភាព។ ការផ្ទេរសាច់ប្រាក់ដោយមានលក្ខខណ្ឌក្នុងប្រទេសអាមេរិកឡាទីន ចាប់តាំងពីទសវត្សរ៍ ១៩៩០ មក បានបង្កើនកម្រិតនៃការអប់រំចន្លោះពី ០,៥ ទៅ ១,៥ ឆ្នាំ។ ប្រទេសមួយក្នុងចំណោមប្រទេសចំនួន ៤ មានកម្មវិធីអនុវត្តវិធានការវិជ្ជមានក្នុងទម្រង់មួយចំនួន ដើម្បីជួយឱ្យសិស្សដែលមានឱកាសតិចតួច អាចទទួលបានការអប់រំកម្រិតឧត្តមសិក្សា។ ប្រទេសមានប្រាក់ចំណូលទាប និងប្រទេសមានប្រាក់ចំណូលមធ្យមកម្រិតទាបប្រមាណ ៤០% ពុំបានចាត់វិធានការអ្វីសោះ ដើម្បីជួយដល់អ្នកសិក្សាដែលប្រឈមនឹងការផាត់ចេញ ក្នុងអំឡុងវិបត្តិកូវីដ ១៩។

---

## គ្រូបង្រៀន សម្ភារបង្រៀន និងបរិយាកាសរៀនសូត្រ ច្រើនតែមិនយកចិត្តទុកដាក់ចំពោះអត្ថប្រយោជន៍ដែលបានពីការច្បាមយកភាពចម្រុះ

គ្រូប្រមាណ ២៥% ក្នុងប្រព័ន្ធអប់រំចំនួន ៤៨ បានលើកឡើងពីតម្រូវការខ្ពស់ចង់បានការអភិវឌ្ឍវិជ្ជាជីវៈ ផ្តោតលើការបង្រៀនសិស្សដែលមានតម្រូវការពិសេស។ មានប្រទេសត្រឹមតែ ៤១ ប៉ុណ្ណោះនៅក្នុងពិភពលោកដែលទទួលស្គាល់ថា ភាសាសញ្ញា គឺជាភាសាផ្លូវការ។ នៅអឺរ៉ុប ក្នុងចំណោមប្រទេសចំនួន ៤៩ មាន ២៣ ប្រទេសពុំបានបញ្ចូលនិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រឱ្យបានជាក់ច្បាស់ក្នុងកម្មវិធីសិក្សានោះឡើយ។

ការប្តេជ្ញាចិត្តនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ (គ.អ.ច ទី ៤) ដើម្បីធានានូវការអប់រំ "ប្រកបដោយបរិយាបន្ន សមធម៌ និងគុណភាព" និងលើកកម្ពស់ "ការរៀនសូត្រពេញមួយជីវិត សម្រាប់ទាំងអស់គ្នា" គឺជាផ្នែកមួយនៃរបៀបវារៈអភិវឌ្ឍន៍ដោយចីរភាពឆ្នាំ ២០៣០ របស់អង្គការសហប្រជាជាតិ ដែលសន្យាថានឹងមិនទុកនរណាម្នាក់ចោល។ របៀបវារៈនេះមានគោលបំណងបង្កើតនូវ "ពិភពលោកមួយដែលយុត្តិធម៌មានសមធម៌ មានការយោគយល់ អធ្យាស្រ័យគ្នា បើកចំហ និងមានលក្ខណៈបរិយាបន្នសង្គម ដែលក្នុងនោះមានការឆ្លើយតបចំពោះតម្រូវការរបស់ក្រុមងាយរងគ្រោះជាងគេ"។

កត្តាសង្គម សេដ្ឋកិច្ច និងវប្បធម៌ អាចបំពេញបន្ថែម ឬរារាំងការសម្រេចបាននូវសមធម៌ និងបរិយាបន្នក្នុងការអប់រំ។ ការអប់រំ គឺជាច្រកចូលមួយដ៏សំខាន់សម្រាប់កសាងសង្គមបរិយាបន្ន ប្រសិនបើនៅក្នុងប្រព័ន្ធអប់រំ គេមើលឃើញភាពចម្រុះគ្នានៃអ្នករៀនសូត្រ មិនមែនជាបញ្ហាចោទ ប៉ុន្តែជាបញ្ហាប្រឈមដែលត្រូវដោះស្រាយ៖ ពោល គឺត្រូវកំណត់អត្តសញ្ញាណអ្នកដែលមានទេពកោសល្យក្នុងគ្រប់រូបភាព និងគ្រប់ទម្រង់ទាំងអស់ និងកសាងនូវលក្ខខណ្ឌដើម្បីឱ្យពួកគេមានការរីកចម្រើន។ គួរឱ្យសោកស្តាយក្រុមងាយរងគ្រោះ ត្រូវបានគេផាត់ចេញពីប្រព័ន្ធអប់រំ តាមរយៈការសម្រេចចិត្តដែលគេធ្វើទាំងមិនដឹងខ្លួន នាំឱ្យមានការផាត់ចេញក្រុមទាំងនេះពីកម្មវិធីសិក្សា ការរៀបចំគោលដៅនៃការរៀនសូត្រដែលមិនឆ្លើយតប ការបញ្ចូលផ្នត់គំនិតអវិជ្ជមានក្នុងសៀវភៅសិក្សា ការរើសអើងក្នុងការបែងចែកធនធាន និងការវាយតម្លៃការអត់អោនឱ្យអំពើហិង្សា និងការមិនអើពើនឹងតម្រូវការផ្សេងៗជាដើម។

កត្តាបរិបទដូចជានយោបាយធនធាន និងវប្បធម៌ជាដើម អាចធ្វើឱ្យចំណោទបរិយាបន្នហាក់បីដូចជាមានការប្រែប្រួលខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ឬក្រុមមួយទៅក្រុមមួយទៀត។ ក្នុងតថភាពជាក់ស្តែង ចំណោទនេះគឺដូចគ្នា មិនថាបរិបទបែបណានោះឡើយ។ ប្រព័ន្ធអប់រំចាំបាច់ត្រូវប្រតិបត្តិចំពោះអ្នករៀនសូត្រទាំងអស់ដោយសេចក្តីថ្លៃថ្នូរទើបអាចជម្នះឧបសគ្គបង្កើនកម្រិតនៃការអប់រំ និងកែលំអលទ្ធផលសិក្សា។ ប្រព័ន្ធចាំបាច់ត្រូវឈប់ដាក់ស្លាកសម្គាល់អ្នករៀនសូត្រ ជាធ្វីដែលគេធ្វើឡើង ក្រោមលេសថាងាយស្រួលធ្វើផែនការ និងផ្តល់ការឆ្លើយតបក្នុងទម្រង់ជាសេវាអប់រំ។ បរិយាបន្នមិនអាចសម្រេចបានមួយក្រុមម្តងៗនោះឡើយ (រូបភាពទី ១)។ អ្នករៀនសូត្រមានអត្តសញ្ញាណចម្រុះខុសៗគ្នា និងមានចំណុចប្រសព្វគ្នាមួយចំនួន។ លើសពីនេះពុំមាន

**រូបភាពទី ១៖**
ចំណុចមួយដែលយើងមានដូចៗគ្នា គឺលក្ខណៈផ្សេងៗគ្នារបស់យើង



លក្ខណៈតែមួយណា ដែលកំណត់ទុកជាមុនពីសមត្ថភាពរៀនសូត្រនោះដែរ។

## បរិយាបន្នក្នុងសេវាអប់រំ ឥឡូវជាដំណើរការដំបូងដ៏សំខាន់ជាងគេ

បរិយាបន្ន គឺសម្រាប់ទាំងអស់គ្នា។ គេច្រើនគិតថា ការអប់រំបរិយាបន្ន គឺពាក់ព័ន្ធនឹងតម្រូវការរបស់ជនមានពិការភាព និងជាទំនាក់ទំនងរវាងការអប់រំពិសេសនិងការអប់រំទូទៅ។ចាប់តាំងពីឆ្នាំ១៩៩០មកការតស៊ូរបស់ជនមានពិការភាពបានសម្រេចការយល់ឃើញជាសកលអំពីបរិយាបន្នក្នុងសេវាអប់រំ ដែលនាំឱ្យមានការទទួលស្គាល់សិទ្ធិទទួលបានការអប់រំបរិយាបន្ន ក្នុងមាត្រា២៤ នៃអនុសញ្ញាស្តីពីសិទ្ធិជនមានពិការភាព (CRPD) របស់អង្គការសហប្រជាជាតិឆ្នាំ ២០១៦។ ទោះជាយ៉ាងណាក៏ដោយដូចលើកឡើងក្នុងយោបល់ទូទៅលេខ ៤ ស្តីពីមាត្រានេះ កាលពីឆ្នាំ ២០១៦ បរិយាបន្នមានវិសាលភាពទូលាយជាងនេះ។ យន្តការដែលនេះ ផាត់ចេញមិនត្រឹមតែជនមានពិការភាពប៉ុណ្ណោះនោះទេ ថែមទាំងអ្នកផ្សេងទៀត ព្រោះតែយេនឌ័រ អាយុ ទីតាំង ភាពក្រីក្រ ពិការភាព ជាតិពន្ធុ ជនជាតិដើមភាគតិចភាសាសាសនាស្ថានភាពទេសន្តប្រវេសន៍ឬស្ថានភាពបាត់បង់ទីលំនៅនិន្នាការភេទឬការសម្តែងចេញនូវអត្តសញ្ញាណយេនឌ័រ ការជាប់ឃុំឃាំង ជំនឿ និងឥរិយាបថរបស់ពួកគេ។ វាគឺជាប្រព័ន្ធ និងជាបរិបទដែលពុំបានពិចារណាពីភាពចម្រុះ និងតម្រូវការដែលមានលក្ខណៈផ្សេងៗគ្នា។ វាគឺជាសង្គម និងវប្បធម៌ ដែលធ្វើការកំណត់ពីវិធាន កំណត់និយមន័យអំពីអ្វីដែលគេចាត់ទុកថាប្រក្រតី និងចាត់ទុកការមានលក្ខណៈខុសប្លែកពីគេ ថាជាការងាកចេញពីអ្វីដែលគេចាត់ទុកថាប្រក្រតី។ ទស្សនទានស្តីពីឧបសគ្គដែលធ្វើឱ្យរាំងការចូលរួម និងការរៀនសូត្រ គួរជំនួសឱ្យទស្សនទានតម្រូវការពិសេស។

បរិយាបន្ន គឺជាដំណើរការ។ ការអប់រំបរិយាបន្ន គឺជាដំណើរការរួមចំណែកសម្រេចគោលដៅនៃបរិយាបន្នសង្គម។ ការកំណត់ពីការអប់រំប្រកបដោយសមធម៌ តម្រូវឱ្យមានការញែកភាពខុសប្លែកគ្នារវាង "សមភាព" និង "សមធម៌" ។ សមភាពគឺជាស្ថានភាព (អ្វី)៖ លទ្ធផលដែលគេសង្កេតឃើញក្នុងជាតុចូល លទ្ធផលរយៈពេលខ្លី ឬលទ្ធផលរយៈពេលមធ្យម។ ដោយឡែកសមធម៌គឺជាដំណើរការ (របៀប)៖ សកម្មភាពដែលធ្វើឡើងក្នុងគោលបំណងធានាឱ្យមានសមភាព។ ការកំណត់និយមន័យការអប់រំបរិយាបន្ន មានលក្ខណៈស្មុគស្មាញជាងនេះ ព្រោះថាដំណើរការ និងលទ្ធផលនៃការអប់រំបែបនេះត្រូវបានច្របាច់បញ្ចូលគ្នា។ របាយការណ៍នេះលើកជាអំណះអំណាងគាំទ្រឱ្យមានការចាត់ទុកបរិយាបន្នថាជាដំណើរការ៖ជាសកម្មភាពដែលទទួលយកភាពចម្រុះនិងកសាងស្មារតីជាសមាជិកក្រុមដែលចាក់ឫសលើជំនឿដែលថាមនុស្សម្នាក់ៗមានគុណតម្លៃ និងសក្តានុពលរៀងៗខ្លួន ដែលគួរទទួលបានការគោរព ដោយមិនប្រកាន់ពីសាវតារ សមត្ថភាព ឬអត្តសញ្ញាណរបស់ពួកគេនោះឡើយ។ ប៉ុន្តែ បរិយាបន្នក៏ជាស្ថានភាពផងដែរ ដូច្នេះទើបអនុសញ្ញាស្តីពីសិទ្ធិជនពិការ និងយោបល់លេខ ៤ ពុំបានធ្វើការកំណត់ឱ្យបានជាក់ច្បាស់ ទំនងជាដោយសារតែមានការយល់ឃើញខុសៗគ្នាអំពីលទ្ធផលដែលគួរសម្រេចឱ្យបានចេញពីដំណើរការនេះ។

## បរិយាបន្ន ក្នុងសេវាអប់រំ ក្នុងទម្រង់ជាលទ្ធផល៖ ចាប់ផ្តើមជាមួយនឹងការអប់រំសម្រាប់ទាំងអស់គ្នា

**ភាពក្រីក្រ និងវិសមភាព គឺជាឧបសគ្គចម្បង។** បើទោះបីជាមានការសម្រេចបានវឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រីក្រធ្ងន់ធ្ងរជាពិសេស នៅអាស៊ីយ៉ាងណាក៏ដោយ ភាពក្រីក្របង្កផលប៉ះពាល់លើមនុស្សពេញវ័យ ១ នាក់ក្នុងចំណោម ១០ នាក់ និងលើកុមារ ២ នាក់ក្នុងចំណោម ១០ នាក់ និងកុមារ ៥ នាក់ក្នុងចំណោមកុមារ ១០ នាក់ នៅអាហ្វ្រិកសាប់សាហារ៉ា។ វិសមភាពប្រាក់ចំណូលកំពុងមានការកើនឡើងនៅតាមតំបន់មួយចំនួននៅក្នុងពិភពលោក ឬប្រសិនបើវិសមភាពមានការថយចុះ វានៅបន្តមានកម្រិតខ្ពស់ដែលមិនអាចទទួលយកបានរវាងប្រទេសមួយ និងប្រទេសមួយទៀត និងរវាងក្រុមមួយ និងក្រុមមួយទៀត នៅក្នុងប្រទេសតែមួយ។ លទ្ធផលផ្នែកការអភិវឌ្ឍមនុស្សសំខាន់ៗ ក៏ពុំមានរបាយស្មើគ្នានោះដែរ។ ប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យមចំនួន ៣០ ៤០% នៃកុមារអាយុក្រោម ៥ ឆ្នាំមកពីគ្រួសារក្រីក្រជាងគេ ២០% ជួបប្រទះនឹងបញ្ហាអាហារូបត្ថម្ភ ពោលគឺខ្ពស់ជាង ២ ដងនៃអត្រាសម្រាប់កុមារមកពីគ្រួសារដែលមានជីវភាពធូរធាជាងគេ ២០% ដែលធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ឱកាសរបស់ពួកគេក្នុងការទទួលបានប្រយោជន៍ពីការអប់រំ។

**វឌ្ឍនភាពក្នុងការទទួលបានសេវាអប់រំនៅបន្តទ្រឹង។** កុមារមនុស្សពេញវ័យនិងយុវជនប្រមាណ២៥៨លាននាក់ឬស្មើនឹង១៧% នៃចំនួនកុមារ ក្មេងជំទង់ និងយុវជនសរុប ពុំបិតនៅក្នុងសាលាឡើយ (**រូបភាពទី ២**)។ គម្លាតនៃអត្រាចូលរៀនបែងចែកតាមទ្រព្យធនមានទំហំធំ៖ ក្នុងចំណោមប្រទេសមានប្រាក់ចំណូលទាប និងចំណូលមធ្យមចំនួន ៦៥ គម្លាតគិតជាមធ្យមនៃអត្រាចូលរៀន រវាងគ្រួសារដែលមានជីវភាពក្រីក្រជាងគេ ២០% និងគ្រួសារដែលមានជីវភាពធូរជាង ២០% គឺ ៩ ភាគរយចំណុចសម្រាប់កុមារដែលដល់អាយុចូលរៀននៅសាលាបឋមសិក្សា, ១៣ ភាគរយចំណុចសម្រាប់ក្មេងជំទង់ដែលដល់អាយុចូលរៀននៅសាលាមធ្យមសិក្សាបឋមភូមិ និង ២៧ ភាគរយសម្រាប់យុវជនដែលដល់អាយុចូលរៀននៅសាលាមធ្យមសិក្សាទុតិយភូមិ។ ដោយសារតែកុមារដែលមានជីវភាពក្រីក្រជាងគេ ច្រើនតែរៀនត្រួតថ្នាក់ ឬធ្លាប់បោះបង់ចោលការសិក្សា គម្លាតនៃអត្រាបញ្ចប់ការសិក្សា បែងចែកតាមទ្រព្យធន រឹតតែមានកម្រិតខ្ពស់ទៅទៀត ពោលគឺ ៣០ ភាគរយចំណុចសម្រាប់ការបញ្ចប់បឋមសិក្សា, ៤៥ ភាគរយចំណុច សម្រាប់ការបញ្ចប់មធ្យមសិក្សាបឋមភូមិ និង ៤០ ភាគរយ សម្រាប់ការបញ្ចប់មធ្យមសិក្សាទុតិយភូមិ។

**រូបភាពទី ២៖ កុមារ ក្មេងជំទង់ និងយុវជន ២៥០ លាននាក់ ពុំបិតនៅក្នុងសាលា**




GEM StatLink: http://bitly/GEM2020_Summary_fig2
ប្រភព៖ ប្រព័ន្ធទិន្នន័យ UIS

**ភាពក្រីក្របង្កផលប៉ះពាល់ដល់ឱកាសចូលរៀន ការបញ្ចប់ការសិក្សា និងការរៀនសូត្រ។** នៅក្នុងគ្រប់តំបន់ទាំងអស់ លើកលែងតែអឺរ៉ុប និងអាមេរិកភាគខាងជើងចេញ រៀងរាល់ក្មេងជំទង់ ១០០ នាក់មកពីគ្រួសារដែលមានជីវភាពធូរធាជាងគេ ២០% មានក្មេងជំទង់ ៨៧ នាក់មកពីគ្រួសារដែលមានជីវភាពក្រីក្រជាងគេ ២០% បានចូលរៀននៅសាលាមធ្យមសិក្សាបឋមភូមិ និង ៣៧ ភាគរយ បានបញ្ចប់កម្រិតសិក្សានេះ។ ក្នុងចំណោមកុមារដែលបានបញ្ចប់ការសិក្សានៅកម្រិតនេះរៀងរាល់ក្មេងជំទង់ ១០០ នាក់មកពីគ្រួសារដែលមានជីវភាពធូរធាជាងគេ ២០% មានប្រមាណ ៥០ នាក់ដែលសម្រេចបាននូវភាពស្ទាត់ជំនាញខាងអំណាន និងគណិតវិទ្យាកម្រិតអប្បបរមា (**រូបភាពទី ៣**)។ ជារឿយៗ ការលំបាកជួបប្រសព្វគ្នា។ កុមារដែលទំនងជាត្រូវបានផាត់ចេញពីការអប់រំជាងគេ ក៏ជាកុមារដែលជួបការលំបាកដោយសារភាសាទីតាំងយេនឌ័រនិងជាតិពន្ធផងដែរ។ នៅក្នុងប្រទេសយ៉ាងហោចណាស់ ២០ ដែលមានទិន្នន័យកម្រមានស្ត្រីវ័យក្មេងដែលមានជីវភាពក្រីក្ររស់នៅជនបទណាដែលបានបញ្ចប់ការសិក្សាកម្រិតមធ្យមសិក្សាទុតិយភូមិណាស់។

**រូបភាពទី ៣៖**

**គម្លាតនៃការចូលរៀន ការបញ្ចប់ការសិក្សា និងការរៀនសូត្រ បែងចែកតាមទ្រព្យធន មានទំហំធំ**

សន្ទស្សន៍យុត្តភាពបែងចែកតាមទ្រព្យធន នៃការចូលរៀន ការបញ្ចប់ការសិក្សា និងការចេះអាន និងគណិតវិទ្យា ត្រឹមកម្រិតអប្បបរមា តាមកម្រិតអប់រំ ក្នុងប្រទេសមួយចំនួន ២០១៣-២០១៧




GEM StatLink: http://bitly/GEM2020_Summary_fig3

កំណត់សម្គាល់៖ សំណាកនេះមិនរាប់បញ្ចូលប្រទេសមានចំណូលខ្ពស់នៅអឺរ៉ុប និងអាមេរិកខាងជើងឡើយ

ប្រភព៖ ការវិភាគដែលធ្វើឡើងដោយក្រុមរៀបចំរបាយការណ៍ GEM ដោយប្រើប្រាស់ការអង្កេតតាមខ្នងផ្ទះ (លើការចូលរៀន និងការបញ្ចប់ការសិក្សា) និងប្រព័ន្ធទិន្នន័យ UIS (ការរៀនសូត្រ)។

## លទ្ធផលនៃបរិយាបន្នក្នុងការអប់រំ អាចជាអ្វីដែលគេពិបាកនឹងសម្រេចឱ្យបាន ប៉ុន្តែវាជាការពិត មិនមែនជាអ្វីដែលគេចេះតែប្រឌិតនោះឡើយ

ខណៈពេលដែលសិទ្ធិទទួលបានសេវាអប់រំជាសកល គឺជាបុរេលក្ខខណ្ឌសម្រាប់បរិយាបន្ន មិនសូវមានការឯកភាពគ្នាជារួមលើអត្ថន័យផ្សេងទៀត នៃការសម្រេចបាននូវបរិយាបន្នក្នុងការអប់រំ សម្រាប់អ្នករៀនសូត្រដែលមានពិការភាព និងក្រុមងាយរងគ្រោះដទៃទៀតដែលប្រឈមនឹងការផាត់ចេញពីសេវាអប់រំ។

**បរិយាបន្នសម្រាប់សិស្សមានពិការភាព មានន័យលើសពីត្រឹមការដាក់ឱ្យពួកគេចូលរៀន។** ការផ្តោតការយកចិត្តទុកដាក់ក្នុងអនុសញ្ញាស្តីពីសិទ្ធិជនពិការ លើការដាក់កុមារមានពិការភាពឱ្យចូលរៀន គឺជាការងាកចេញមិនត្រឹមតែពីនិន្នាការក្នុងប្រវត្តិសាស្ត្រកន្លងមក ដែលផាត់កុមារមានពិការភាពចេញពីការអប់រំ ឬដាក់ពួកគេឱ្យរៀននៅដោយឡែក នៅសាលារៀនពិសេសប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាការងាកចេញពីការអនុវត្តដែលដាក់ពួកគេឱ្យរៀននៅក្នុងថ្នាក់ដោយឡែកក្នុងរយៈពេលមួយយូរ ឬរយៈពេលភាគច្រើនផងដែរ។ ទោះជាយ៉ាងណាក៏ដោយ បរិយាបន្នទាមទារឱ្យមានការផ្លាស់ប្តូរច្រើនជាងនេះ ជុំវិញការគាំទ្ររបស់សាលារៀន និងគោលការណ៍របស់សាលារៀន។ អនុសញ្ញាស្តីពីសិទ្ធិជនពិការ ពុំបានលើកឡើងថា សាលារៀនពិសេសបានបំពានអនុសញ្ញានេះឡើយ ប៉ុន្តែរបាយការណ៍កាលពីពេលថ្មីៗដែលចេញដោយគណៈកម្មាធិការទទួលបន្ទុកសិទ្ធិជនមានពិការភាព កាន់តែលើកឡើងពីចំណុចនេះ។ គណៈកម្មាធិការនេះបានផ្តល់សិទ្ធិឱ្យរដ្ឋាភិបាលជ្រើសរើសទម្រង់នៃការអប់រំបរិយាបន្ន ជាការទទួលស្គាល់ បើទោះបីមិនការបញ្ជាក់ច្បាស់ ពីឧបសគ្គដែលរាំងស្ទះមិនឱ្យមានការសម្រេចបានបរិយាបន្នពេញលេញ។ ខណៈពេលដែលគួរមានបង្ហាញឱ្យឃើញពីការអនុវត្តរបស់រដ្ឋាភិបាលជាច្រើន នាំឱ្យមានការផាត់កុមារមានពិការភាពចេញ ដែលជាការផ្ទុយទៅនឹងការប្តេជ្ញាចិត្តនិងអនុសញ្ញាស្តីពីសិទ្ធិជនពិការយ៉ាងណាក៏ដោយ គួរមានការទទួលស្គាល់ពីដែនកំណត់នៃភាពបត់បែនរបស់សាលារៀនទូទៅ និងប្រព័ន្ធអប់រំទូទៅផងដែរ។

**ការអប់រំបរិយាបន្ន ជួយសម្រេចគោលដៅច្រើន។** អាចមានភាពតានតឹងរវាងគោលដៅដែលគេចង់សម្រេច ដូចជាការបង្កើនទំនាក់ទំនងឱ្យបានច្រើនបំផុតជាមួយនឹងកុមារផ្សេងទៀត (កុមារទាំងអស់ដែលឋិតនៅក្រោមដំបូលតែមួយ) ជាមួយនឹងការសម្រេចសក្តានុពលនៃការរៀនសូត្រ (នៅទីកន្លែងដែលសិស្សអាចរៀនបានល្អបំផុត)។ កត្តាដែលត្រូវលើកយកមកធ្វើការពិចារណាផ្សេងទៀតរួមមាន ល្បឿនដែលប្រព័ន្ធអាចសម្រេចលទ្ធផលល្អបំផុត និងអ្វីដែលកើតមានក្នុងរយៈពេលអន្តរកាល ព្រមទាំងជម្រើសដែលត្រូវជ្រើសរើសរវាងការកំណត់ពីតម្រូវការឱ្យបានឆាប់រហ័ស និងហានិភ័យ ដែលកើតឡើងដោយសារការដាក់ឈ្មោះសម្រាប់ហៅកុមារមានពិការភាព និងការមាក់ងាយដល់ពួកគេ។

**ការសម្រេចគោលដៅផ្សេងៗគ្នាក្នុងពេលជាមួយគ្នា អាចជាការបំពេញបន្ថែមឱ្យគ្នា ឬអាចនាំឱ្យមានភាពប្រទាំងប្រទើសជាមួយគ្នា។** អ្នកតាក់តែងគោលនយោបាយ អ្នកតាក់តែងច្បាប់ និងអ្នកអប់រំប្រឈមនឹងសំណួរសំខាន់ៗមួយចំនួន ពាក់ព័ន្ធនឹងបរិយាបន្នអាស្រ័យតាមបរិបទរបស់ពួកគេ។ ពួកគេចាំបាច់ត្រូវដឹងពីការជំទាស់ពីសំណាក់អ្នកដែលបានវិនិយោគ ដើម្បីឱ្យនៅតែមានការបែងចែកក្រុមមួយ និងក្រុមមួយទៀតក្នុងការផ្តល់សេវាក៏ដូចជាដឹងពីការពុំអាចរក្សាការផ្លាស់ប្តូរដ៏ឆាប់រហ័សបែបនេះឱ្យនៅគង់វង្សបានយូរដែលអាចបង្កគ្រោះថ្នាក់ដល់សុខុមាលភាពរបស់អ្នកដែលត្រូវទទួលសេវា។ ការបញ្ចូលកុមារមានពិការភាពទៅក្នុងសាលារៀនទូទៅ ដែលពុំបានត្រៀមរៀបចំខ្លួន ពុំបានទទួលការគាំទ្រ ឬមិនទទួលខុសត្រូវក្នុងករណីដែលមិនបានសម្រេចបរិយាបន្ន អាចឱ្យកុមារកាន់តែទទួលរងការផាត់ចេញពីសេវាអប់រំ និងបង្កផលវិបាកត្រឡប់មកលើកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើឱ្យសាលារៀន និងប្រព័ន្ធកាន់តែមានបរិយាបន្នវិញ។

**បរិយាបន្នពេញលេញអាចមានគុណវិបត្តិ។** ក្នុងបរិបទមួយចំនួន បរិយាបន្នអាចបង្កើនសម្ពាធឱ្យធ្វើតាមទាំងមិនដឹងខ្លួន។ អត្តសញ្ញាណ ការអនុវត្តភាសា និងជំនឿរបស់ក្រុមអាចមិនត្រូវបានគេឱ្យតម្លៃធ្វើឱ្យខូចឬត្រូវបានគេលុបបំបាត់ចោលដែលធ្វើឱ្យគេលែងដឹងថាអ្នកណាស្ថិតនៅក្នុងក្រុមណា។ សិទ្ធិរបស់ក្រុមណាមួយ ដើម្បីការពារវប្បធម៌របស់ខ្លួន និងសិទ្ធិស្វ័យសម្រេច ក៏ដូចជាសិទ្ធិតំណាងឱ្យខ្លួនឯង កាន់តែត្រូវបានទទួលស្គាល់ខ្លាំងឡើងៗ។ បរិយាបន្នអាចត្រូវបានគេមិនទទួលយក ដោយសារបុរេវិនិច្ឆ័យ និងដោយសារតែមានការទទួលស្គាល់ថា គេអាចនៅតែរក្សាអត្តសញ្ញាណ និងសម្រេចបាននូវការផ្តល់ភាពអង់អាច តែប្រសិនបើក្រុមភាគតិច គឺជាក្រុមភាគច្រើននៅក្នុងតំបន់ណាមួយតែប៉ុណ្ណោះ។ ជាជាងសម្រេចឱ្យបាននូវការចូលរួមជាវិជ្ជមានក្នុងសង្គម នៅក្នុងកាលៈទេសៈមួយចំនួនគោលនយោបាយស្តីពីបរិយាបន្នបែរជាបង្កើនការផាត់ចេញពីសង្គមទៅវិញ។ ការឋិតនៅក្នុងក្រុមភាគច្រើន អាចពង្រឹងបុរេវិនិច្ឆ័យដែលមានលក្ខណៈគ្របលុប ធ្វើឱ្យក្រុមភាគតិចកាន់តែជួបការលំបាកបន្ថែមទៀត។ ការផ្តល់ជំនួយឱ្យចំគោលដៅ ក៏អាចនាំឱ្យមានការមាក់ងាយ ការដាក់ឈ្មោះ ឬនាំឱ្យមានបរិយាបន្នក្នុងទម្រង់ដែលគេមិនស្វាគមន៍។

**ការដោះស្រាយបញ្ហាដែលពិបាកដោះស្រាយបែបនេះ ទាមទារឱ្យមានការចូលរួមពិតប្រាកដ។** ការអប់រំបរិយាបន្ន ត្រូវរៀបចំឡើងផ្អែកតាមកិច្ចពិគ្រោះយោបល់ ការចូលរួម និងការបើកចំហ។ ខណៈពេលដែលអ្នកតាក់តែងគោលនយោបាយ និងអ្នកអប់រំ មិនគួរធ្វើឱ្យខូចបន្ទាបតម្លៃឬងាកចេញពីបរិយាបន្នដែលល្អបំផុតនៅក្នុងរយៈពេលវែងពួកគេមិនទុកចោលតម្រូវការនិងការចង់បានរបស់អ្នកដែលរងផលប៉ះពាល់នោះឡើយ។ សិទ្ធិមនុស្ស និងគោលការណ៍ជាមូលដ្ឋាន កំណត់ពីទិសដៅក្រមសីលធម៌ និងទិសដៅនយោបាយ សម្រាប់ការធ្វើសេចក្តីសម្រេចចិត្តក្នុងវិស័យអប់រំ ប៉ុន្តែការសម្រេចឱ្យបាននូវស្ថានភាពបរិយាបន្នដែលល្អបំផុត មិនមែនជារឿងតូចតាចនោះឡើយ។ ការផ្តល់ការគាំទ្រឱ្យបានគ្រប់គ្រាន់ទៅតាមស្ថានភាពផ្សេងៗគ្នារបស់បុគ្គលម្នាក់ៗ ទាមទារឱ្យមានការអត់ធ្មត់ ការអត់ធន់ និងការប្រកាន់ទស្សនៈវែងឆ្ងាយ។ ការមិនរៀបចំប្រព័ន្ធអប់រំឱ្យត្រូវនឹងស្ថានភាពរបស់កុមារមួយចំនួន ហើយតម្រូវឱ្យកុមារផ្សេងទៀតសម្របខ្លួន មិនងាយនឹងកើតឡើង តែតាមរយៈការដាក់ឱ្យអនុវត្តច្បាប់នោះឡើយ។ ចាំបាច់ត្រូវមានការឆ្លើយតបចំពោះឥរិយាបថ និងផ្នត់គំនិតដែលកើតមានជាទូទៅ។ ការអប់រំបរិយាបន្ន អាចជាអ្វីដែលគេពិបាកគ្រប់គ្រង បើទោះបីជាមានឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់បំផុតក៏ដោយ។ ដូច្នេះ មនុស្សមួយចំនួនលើកឡើងថា ចង់ឱ្យមានការកំហិតលើគោលបំណងនៃការអប់រំបរិយាបន្ន ប៉ុន្តែជំហានបន្ទាប់គឺត្រូវទទួលស្គាល់ពីឧបសគ្គ និងធ្វើការឆ្លើយតបចំពោះឧបសគ្គទាំងនេះសិន។

**បរិយាបន្ននាំមកនូវអត្ថប្រយោជន៍។** ការធ្វើផែនការដោយប្រុងប្រយ័ត្ន និងការផ្តល់ការអប់រំបរិយាបន្ន អាចនាំឱ្យមានការបង្កើនលទ្ធផលសិក្សា ការអភិវឌ្ឍចិត្តសង្គម ការផ្តល់តម្លៃដល់ខ្លួនឯង និងការទទួលយកគ្នាទៅវិញទៅមក។ ការបញ្ចូលសិស្សដែលមានសាវតារចម្រុះទៅក្នុងថ្នាក់រៀននិងសាលារៀនទូទៅអាចបង្ការការមាក់ងាយការប្រកាន់ផ្នត់គំនិតអវិជ្ជមានការរើសអើងនិងការនៅឯកោ។ លើសពីនេះគេក៏អាចសន្សំសំចៃនិងបង្កើនប្រសិទ្ធភាពតាមរយៈការលុបបំបាត់រចនាសម្ព័ន្ធផ្តល់សេវាអប់រំស្របគ្នានិងប្រើប្រាស់ធនធានកាន់តែស័ក្តិសិទ្ធិក្នុងប្រព័ន្ធ អប់រំទូទៅតែមួយដែលមានលក្ខណៈបរិយាបន្ន។ ហេតុផលសេដ្ឋកិច្ចដែលគាំទ្រដល់ការអប់រំបរិយាបន្ន គឺមិនទាន់គ្រប់គ្រាន់នៅឡើយ បើទោះវាជាអ្វីដែលមានតម្លៃសម្រាប់ការធ្វើផែនការក៏ដោយ។ ប្រព័ន្ធមួយចំនួនតូចអាចមកកៀកនឹងស្ថានភាពល្អបំផុត ដែលផ្តល់លទ្ធភាពឱ្យគេអាចធ្វើការប៉ាន់ប្រមាណដឹងពីចំណាយពេញលេញ ប៉ុន្តែគេពិបាកនឹងធ្វើការប៉ាន់ប្រមាណពីអត្ថប្រយោជន៍ដែលទទួលបាន ព្រោះថាអត្ថប្រយោជន៍ទាំងនេះកើតមានបន្តគ្នារាប់ជំនាន់។

**បរិយាបន្នគឺជាលក្ខខណ្ឌតម្រូវខាងក្រមសីលធម៌។** ការជជែកវែកញែកអំពីអត្ថប្រយោជន៍នៃការអប់រំបរិយាបន្ន ប្រៀបបីដូចជាការជជែកវែកញែកអំពីអត្ថប្រយោជន៍នៃសិទ្ធិមនុស្សដែរ។បរិយាបន្នគឺជាបុរេលក្ខខណ្ឌដើម្បីសម្រេចឱ្យបាននូវសង្គមដែលមាននិរន្តរភាព។ វាក៏ជាបុរេលក្ខខណ្ឌសម្រាប់ផ្តល់ការអប់រំនៅក្នុងសង្គមប្រជាធិបតេយ្យ និងសម្រាប់លិទ្ធិប្រជាធិបតេយ្យ ផ្អែកតាមគោលការណ៍នៃភាពត្រឹមត្រូវយុត្តិធម៌និងសមធម៌។បរិយាបន្នផ្តល់នូវក្រេបខ័ណ្ឌដែលមានលក្ខណៈជាប្រព័ន្ធដើម្បីលុបបំបាត់ចោលនូវឧបសគ្គនានាស្របតាមគោលការណ៍ "អ្នករៀនសូត្រគ្រប់រូបសុទ្ធតែសំខាន់ និងមានសារៈសំខាន់ស្មើគ្នា"។ បរិយាបន្នក៏មានលក្ខណៈផ្ទុយទៅនឹងនិន្នាការនៅក្នុងប្រព័ន្ធអប់រំដែលអនុញ្ញាតឱ្យមានការលើកលែង និងការផាត់ចេញសិស្សមួយចំនួនៅពេលដែលគេធ្វើការវាយតម្លៃសាលារៀន ផ្តោតតែលើទិដ្ឋភាពតែមួយមុខ និងមានការផ្សារភ្ជាប់ទំនាក់ទំនងការវិភាជធនធានទៅនឹងលទ្ធផលដែលសម្រេចបានដោយសាលារៀន។

**បរិយាបន្នលើកកម្ពស់ការរៀនសូត្រសម្រាប់សិស្សទាំងអស់។** នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅថ្មីៗនេះ ការលើកឡើងពីវិបត្តិជុំវិញការរៀនសូត្រ នាំឱ្យមានការយកចិត្តទុកដាក់ចំពោះសិស្សដល់វ័យចូលរៀនភាគច្រើន ក្នុងប្រទេសដែលមានប្រាក់ចំណូលទាប និងចំណូលមធ្យមដែលពុំបានទទួលជំនាញជាមូលដ្ឋាន ដល់កម្រិតអប្បបរមា។ទោះជាយ៉ាងណាក៏ដោយ ការអត្ថាធិប្បាយបែបនេះអាចមើលរំលងការបំពេញមុខងារមិនបានល្អក្នុងលក្ខណៈជាប្រព័ន្ធនៃប្រព័ន្ធអប់រំនៅក្នុងប្រទេសដែលជឿនលឿនជាងគេដូចជាការផាត់ចេញអ្នករៀនសូត្រមួយចំនួន ការផ្តល់អាទិភាពដល់សិស្សមកពីក្រុមដែលមានអំណាច និងអសមធម៌ជាដើម។វាមិនមែនជារឿងចៃដន្យនោះទេ ដែលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ តម្រូវយ៉ាងជាក់ច្បាស់ឱ្យប្រទេសនានាធានានូវការអប់រំបរិយាបន្ននោះ។ ដំណោះស្រាយសើៗ ដែលមិនយកចិត្តទុកដាក់ចំពោះឧបសគ្គជ្រៅៗ ដែលនាំឱ្យមានការផាត់ចេញ អាចបានត្រឹមតែកែលម្អលទ្ធផលសិក្សាប៉ុណ្ណោះ។ បរិយាបន្នត្រូវតែជាមូលដ្ឋានគ្រឹះនៃគោលវិធីបង្រៀន និងរៀន។

របាយការណ៍ពិនិត្យតាមដានការអប់រំជាសកល ឆ្នាំ ២០២០ នេះ សួរសំណួរជុំវិញដំណោះស្រាយសំខាន់ៗនៅកម្រិតគោលនយោបាយ ឧបសគ្គដែលធ្វើឱ្យរាំងស្ទះដល់ការអនុវត្ត យន្តការសម្របសម្រួល ប្រភពផ្តល់ហិរញ្ញប្បទាន និងការពិនិត្យតាមដានការអប់រំបរិយាបន្ន។ ក្នុងកម្រិតដែលអាចធ្វើទៅបាន របាយការណ៍នេះធ្វើការពិនិត្យលើសំណួរទាំងនេះ ដោយពិចារណាពីការផ្លាស់ប្តូរដែលកើតមានកន្លងមក។ ទោះជាយ៉ាងណាក៏ដោយ បញ្ហាដែលមានលក្ខណៈស្មុគស្មាញ ដូចជា បញ្ហាបរិយាបន្ននេះ នៅមិនទាន់មានការប្រមូលចងក្រងព័ត៌មានទុកជាឯកសារនៅកម្រិតសកលឱ្យបានល្អនៅឡើយ។ របាយការណ៍នេះធ្វើការប្រមូលព័ត៌មានអំពីរបៀបដែលប្រទេសនីមួយៗចាប់ពីប្រទេសអាហ្វហ្គានីស្ថាន រហូតដល់ហ្ស៊ីមបាវ៉េ ធ្វើការឆ្លើយតបចំពោះបញ្ហាបរិយាបន្ននៅក្នុងការអប់រំ។ ព័ត៌មាននេះអាចរកបាននៅលើគេហទំព័រ Education Profiles ជាគេហទំព័រថ្មីដែលប្រទេសនានាអាចប្រើប្រាស់ ដើម្បីចែករំលែកបទពិសោធន៍និងរៀនសូត្រពីគ្នាទៅវិញទៅមក ជាពិសេសនៅថ្នាក់តំបន់ ដែលមានបរិបទស្រដៀងគ្នា។ ព័ត៌មានជាសាវតារទាំងនេះអាចប្រើប្រាស់ជាទិន្នន័យគោល ដើម្បីពិនិត្យលើវឌ្ឍនភាពផ្នែកគុណវិស័យដែលសម្រេចបានរហូតដល់ឆ្នាំ ២០៣០។

របាយការណ៍នេះទទួលស្គាល់ពីបរិបទ និងបញ្ហាប្រឈមខុសៗគ្នា ដែលប្រទេសទាំងឡាយកំពុងជួបប្រទះ ក្នុងការផ្តល់សេវាអប់រំបរិយាបន្ន, ក្រុមផ្សេងៗគ្នាដែលប្រឈមនឹងការផាត់ចេញពីសេវាអប់រំ និងឧបសគ្គដែលអ្នករៀនសូត្រម្នាក់ៗជួបប្រទះ ជាពិសេសនៅពេលដែលលក្ខណៈរបស់ពួកគេជួបប្រសព្វគ្នា, និងបង្ហាញផងដែរថា បរិយាបន្នអាចមានលក្ខណៈរូបវន្ត សង្គម (ទំនាក់ទំនងអន្តរបុគ្គល និងទំនាក់ទំនងក្រុម) ផ្លូវចិត្ត និងក្នុងរូបភាពជាប្រព័ន្ធ។ របាយការណ៍នេះឆ្លើយតបចំពោះបញ្ហាប្រឈមទាំងនេះ តាមរយៈសមាសភាគចំនួន ៧ ក្នុងជំពូកដូចតទៅ។

# ជំពូកទី ២៖ ច្បាប់ និងគោលនយោបាយ

**លិខិតុបករណ៍គតិយុត្តដែលមានលក្ខណៈចងកាតព្វកិច្ច និងសេចក្តីប្រកាសដែលមិនចងកាតព្វកិច្ច បង្ហាញឱ្យឃើញពីបំណងប្រាថ្នាចង់បានបរិយាបន្នជាអន្តរជាតិ។** អនុសញ្ញាប្រឆាំងនឹងការរើសអើងក្នុងការអប់រំរបស់យូណេស្កូឆ្នាំ ១៩៦០ និងសេចក្តីប្រកាសពិភពលោកស្តីពីការអប់រំសម្រាប់ទាំងអស់គ្នាដែលត្រូវបានអនុម័តក្នុងទីក្រុងចុមទៀន ប្រទេសថៃ បានអំពាវនាវឱ្យប្រទេសនានាចាត់វិធានការជានាឱ្យមាន "សមភាពនៃការប្រតិបត្តិក្នុងការអប់រំ" និងពុំមាន "ការរើសអើងនៅក្នុងការទទួលបានឱកាសរៀនសូត្រ" សម្រាប់ "ក្រុមដែលពុំទាន់បានទទួលបានសេវាគ្រប់គ្រាន់"។ សេចក្តីប្រកាស និងក្របខ័ណ្ឌសកម្មភាពឆ្នាំ ១៩៩៤ ដែលត្រូវបានអនុម័តក្នុងទីក្រុងសាលាម៉ង់កា ប្រទេសអេស្ប៉ាញ ដាក់ចេញនូវគោលការណ៍ដែលបញ្ជាក់ថា កុមារគ្រប់រូបគួរ "ទៅរៀនក្នុងសាលារៀន ដែលកុមារត្រូវទៅរៀនប្រសិនបើកុមារនេះពុំមានពិការភាព"ដែលត្រូវបានអនុម័តជាសិទ្ធិក្នុងឆ្នាំ២០០៦។អត្ថបទទាំងនេះមានឥទ្ធិពលលើច្បាប់និងគោលនយោបាយជាតិ ដែលជាមូលដ្ឋាន ដើម្បីសម្រេចវឌ្ឍនភាពឈានទៅសម្រេចបរិយាបន្ន។

**និយមន័យថ្នាក់ជាតិស្តីពីការអប់រំបរិយាបន្ន ច្រើនតែមានវិសាលភាពទូលំទូលាយ។** ការវិភាគដែលធ្វើឡើងសម្រាប់របាយការណ៍នេះ បង្ហាញថា ក្នុងចំណោម ១៧៩ ប្រទេស មានប្រទេសចំនួន ១៣២ បានកំណត់និយមន័យបរិយាបន្ននៅក្នុងច្បាប់ គោលនយោបាយ ផែនការ ឬយុទ្ធសាស្ត្រ។ និយមន័យដែលគ្របដណ្តប់លើក្រុមដែលមានឱកាសតិចតួចទាំងអស់ ត្រូវបានរកឃើញក្នុងប្រទេសចំនួន ៥៨%។ ក្នុងប្រទេស ២៦% និយមន័យការអប់រំបរិយាបន្នគ្របដណ្តប់តែចំពោះជនមានពិការភាព ឬជនដែលមានតម្រូវការពិសេសតែប៉ុណ្ណោះ។

**ច្បាប់ច្រើនផ្តោតគោលដៅលើក្រុមជាក់លាក់ ដែលប្រឈមនឹងការផាត់ចេញពីសេវាអប់រំ។** ចក្ខុវិស័យដែលមានលក្ខណៈទូលំទូលាយដែលបញ្ចូលអ្នករៀនសូត្រទៅក្នុងសេវាអប់រំភាគច្រើនមិនមាននៅក្នុងច្បាប់ជាតិនោះឡើយ។មានប្រទេសតែ១០%តែប៉ុណ្ណោះដែលមានបញ្ញត្តិច្បាប់ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយផ្តោតលើអ្នករៀនសូត្រទាំងអស់ នៅក្នុងច្បាប់ស្តីពីការអប់រំទូទៅ ឬច្បាប់ស្តីពីការអប់រំបរិយាបន្នរបស់ខ្លួន។ ច្បាប់ដែលមានប្រភពពីក្រសួងអប់រំ ច្រើនផ្តោតលើក្រុមជាក់លាក់។ ក្នុងចំណោមប្រទេសទាំងអស់ ៧៩% មានច្បាប់ដែលលើកឡើងពីការអប់រំសម្រាប់ជនមានពិការភាព ៦០% សម្រាប់ក្រុមភាគតិចខាងភាសា, ៥០% សម្រាប់ជនជាតិភាគតិច និងជនជាតិដើមភាគតិច, និង ៤៩% សម្រាប់ក្មេងស្រី និងស្ត្រី។

**គោលនយោបាយច្រើនតែមានចក្ខុវិស័យទូលំទូលាយស្តីពីបរិយាបន្នក្នុងការអប់រំ។** ប្រទេសប្រមាណ ១៧% មានគោលនយោបាយដែលមានខ្លឹមសារគ្រប់ជ្រុងជ្រោយផ្តោតលើអ្នករៀនសូត្រគ្រប់រូប។ ការសរសេរមិនសូវចងកាតព្វកិច្ច មាននិន្នាការច្រើនជាង ដោយផែនការ និងយុទ្ធសាស្ត្រជាតិវិស័យអប់រំ ៧៥% ប្រកាសពីបំណងបញ្ចូលក្រុមដែលងាយរងគ្រោះទាំងអស់។ ប្រទេសប្រមាណ ៦៧% មានគោលនយោបាយស្តីពីបរិយាបន្នសម្រាប់បញ្ចូលអ្នករៀនសូត្រដែលមានពិការភាព ដោយការទទួលខុសត្រូវលើការអនុវត្តគោលនយោបាយនេះត្រូវបានបែងចែកស្មើតែស្មើគ្នារវាងក្រសួងអប់រំ និងក្រសួងផ្សេងទៀត។

**ច្បាប់ និងគោលនយោបាយចែងខុសគ្នាអំពីថាតើសិស្សមានពិការភាព គួររៀននៅក្នុងសាលារៀនទូទៅដែរឬទេ។** ច្បាប់នៅក្នុងប្រទេសចំនួន២៥%ចែងពីការផ្តល់ការអប់រំក្នុងកន្លែងដាច់ដោយឡែកពីគ្នាដែលភាគរយនេះកើនឡើងដល់៤០%នៅអាស៊ីអាមេរិកឡាទីន និងការីបៀន។ ប្រទេសប្រមាណ ១០% តម្រូវឱ្យមានការអប់រំបែបសមាហរណកម្ម និង ១៧% តម្រូវឱ្យមានការអប់រំបរិយាបន្ន។ ប្រទេសដែលនៅសល់ជ្រើសរើសយកការផ្តល់ការអប់រំដាច់ដោយឡែកពីគ្នាផង និងផ្តល់ការអប់រំក្នុងសាលារៀនទូទៅជាមួយគ្នាផង។ គោលនយោបាយនានា រំកិលខ្លួនទៅកាន់តែកៀកនឹងបរិយាបន្នះ ប្រទេស ៥% មានគោលនយោបាយស្តីពីការផ្តល់សេវាអប់រំ នៅក្នុងស្ថានភាពដាច់ដោយឡែកពីគ្នា ខណៈពេលដែល ១២% ជ្រើសរើសយកការអប់រំបែបសមាហរណគម្ម និង ៣៨% ជ្រើសរើសយកការអប់រំបែបបរិយាបន្ន។ បើទោះបីជាច្បាប់ និងគោលនយោបាយមានឆន្ទៈល្អក៏ដោយ ជារឿយៗរដ្ឋាភិបាលពុំបានធានាឱ្យមានការអនុវត្តនោះឡើយ។

**គោលនយោបាយចាំបាច់ត្រូវមានសង្គតិភាព និងមានភាពស៊ីសង្វាក់គ្នា សម្រាប់គ្រប់ក្រុមអាយុ និងកម្រិតអប់រំ។** ការទទួលបានសេវាគាំពារ និងអប់រំកុមារតូច នៅមានបញ្ហាអសមធម៌ក្នុងកម្រិតមួយខ្ពស់ ទៅតាមទីតាំង និងស្ថានភាពសង្គមសេដ្ឋកិច្ច។ គុណភាព ជាពិសេស ទំនាក់ទំនង និងការប្រើប្រាស់គោលវិធីកុមារមជ្ឈមណ្ឌលផ្អែកតាមការលេង ក៏ជាកត្តាកំណត់ពីបរិយាបន្នផងដែរ។ការកំណត់ឱ្យបានទាន់ពេលវេលានូវតម្រូវការរបស់កុមារ គឺជាចំណុចមួយដ៏សំខាន់នៅក្នុងការរៀបចំការឆ្លើយតបឱ្យបានសមស្របប៉ុន្តែការដាក់ឈ្មោះឱ្យកុមារដែលមានលក្ខណៈផ្សេងៗពីគ្នាក្នុងគោលបំណងបញ្ចូលពួកគេទៅក្នុងសេវាអប់រំអាចបង្កឱ្យមានផលវិបាកទៅវិញ។ការបែងចែកក្រុមដែលមានឱកាសតិចតួចមួយចំនួនឱ្យចូលទៅក្នុងប្រភេទក្រុមដែលមានតម្រូវការពិសេស អាចបង្ហាញឱ្យឃើញពីនីតិវិធីដែលមានលក្ខណៈរើសអើង ដូចដែលបង្ហាញតាមរយៈការជំទាស់ផ្នែកច្បាប់ប្រកបដោយជោគជ័យលើសិទ្ធិទទួលបានការអប់រំរបស់សិស្សជនជាតិរ៉ូម៉ា ជាដើម។

**ការទប់ស្កាត់ការឆាប់បោះបង់ចោលការសិក្សា ទាមទារឱ្យមានការដាក់ចេញគោលនយោបាយច្រើនយ៉ាង។** ប្រព័ន្ធអប់រំប្រឈមនឹងបញ្ហាចំនួន ២ ទន្ទឹមគ្នាដែលពិបាកធ្វើការដោះស្រាយ។ ការរៀនត្រួតថ្នាក់ហាក់បីដូចជាធ្វើឱ្យការបោះបង់ចោលការសិក្សាមានការកើនឡើងប៉ុន្តែការឡើងថ្នាក់ដោយស្វ័យប្រវត្តិតម្រូវឱ្យមានការប្រើប្រាស់វិធីសាស្ត្រក្នុងលក្ខណៈជាប្រព័ន្ធដើម្បីផ្តល់ការបំប៉នបន្ថែមដែលប្រទេសជាច្រើនធ្វើការប្រកាស ប៉ុន្តែខកខានពុំបានអនុវត្ត។ ច្បាប់ និងគោលនយោបាយនានា អាចពុំមានសង្គតិភាពជាមួយនឹងគោលការណ៍បរិយាបន្ន ឧទាហរណ៍ក្នុងប្រទេសដែលកំណត់អាយុកម្រិតទាបសម្រាប់ពលកម្មកុមារ ឬការរៀបអាពាហ៍ពិពាហ៍។ បង់ក្លាដែសគឺជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួនតូច ដែលបានវិនិយោគយ៉ាងច្រើន លើកម្មវិធីផ្តល់ឱកាសទី ២ ដែលចាំបាច់ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤។

**រដ្ឋាភិបាលកំពុងខិតខំធ្វើយ៉ាងណាឱ្យគោលនយោបាយអប់រំ ក្រោយកម្រិតអប់រំកាតព្វកិច្ច និងគោលនយោបាយអប់រំសម្រាប់មនុស្សពេញវ័យកាន់ តែមានលក្ខណៈបរិយាបន្ន។** ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ អាចជួយសម្រួលឱ្យក្រុមងាយរងគ្រោះបានចូលរួមនៅក្នុងទីផ្សារការងារ ជាពិសេសស្ត្រីវ័យក្មេង និងជនមានពិការភាព។ ដើម្បីប្រើប្រាស់ការអប់រំបច្ចេកទេស និងវិជ្ជាជីវៈឱ្យអស់សក្តានុពល ទាមទារឱ្យមានការរៀបចំបរិយាកាសរៀនសូត្រឱ្យកាន់តែមានសុវត្ថិភាព និងផ្តល់ភាពងាយស្រួលដូចនៅក្នុងប្រទេសម៉ាឡាវីជាដើម។អន្តរាគមន៍អប់រំកម្រិតឧត្តមសិក្សា ដែលផ្តោតលើបរិយាបន្ន ច្រើនផ្តោតការយកចិត្តទុកដាក់លើការលើកទឹកចិត្តឱ្យក្រុមងាយរងគ្រោះបានចូលរៀនតាមរយៈការកំណត់កូតា ឬការអនុវត្តវិធានការសម្រួលចំណាយជាដើម។ ទោះជាយ៉ាងណាក៏ដោយ ក្នុងចំណោមប្រទេសចំនួន ៧១ មានត្រឹមតែ ១១% ប៉ុណ្ណោះ ដែលមានយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយសម្រាប់លើកកម្ពស់សមធម៌, ១១% ទៀត បានត្រឹមតែដាក់ចេញអភិក្រមសម្រាប់ក្រុមជាក់លាក់តែប៉ុណ្ណោះ។ បរិយាបន្នឌីជីថល ជាពិសេសសម្រាប់មនុស្សចាស់ គឺជាបញ្ហាប្រឈមដ៏ធំមួយសម្រាប់បណ្តាប្រទេសដែលកាន់តែពឹងអាស្រ័យលើបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។

**ការឆ្លើយតបចំពោះវិបត្តិកូវីដ ១៩ ដែលបង្កផលប៉ះពាល់ដល់អ្នកសិក្សាចំនួន ១,៦ ប៊ីលាននាក់ ពុំបានយកចិត្តទុកដាក់គ្រប់គ្រាន់លើការបញ្ចូលគ្រប់អ្នកសិក្សាឡើយ។** ខណៈពេលដែលប្រទេសមានប្រាក់ចំណូលទាប ៥៥% ជ្រើសរើសយកការរៀនសូត្រពីចំងាយតាមប្រព័ន្ធអនឡាញសម្រាប់ការអប់រំកម្រិតបឋមសិក្សានិងមធ្យមសិក្សាក្នុងប្រទេសដែលមានការអភិវឌ្ឍតិចតួចមានគ្រួសារតែ១២%ប៉ុណ្ណោះមានអ៊ីនធឺណិតប្រើប្រាស់ក្នុងផ្ទះ។ សូម្បីតែគោលវិធីបង្រៀន ដែលប្រើប្រាស់បច្ចេកវិទ្យាកម្រិតទាបក៏ដោយ ក៏មិនអាចធានាឱ្យមានការរៀនសូត្រជាប់បន្តនោះដែរ។ ក្នុងចំណោមគ្រួសារក្រីក្រជាងគេ ២០% មានតែ ៧% ប៉ុណ្ណោះ ដែលមានវិទ្យុប្រើប្រាស់ ក្នុងប្រទេសអេត្យូពី និងពួកគេពុំមានទូរទស្សន៍តែម្តង។ ជារួមមានប្រទេសមានចំណូលទាប និងប្រទេសមានចំណូលមធ្យមកម្រិតទាបប្រហែល ៤០% ពុំបានផ្តល់ការគាំទ្រដល់អ្នកសិក្សា ដែលប្រឈមនឹងការផាត់ចេញ។ ក្នុងប្រទេសបារាំង មានសិស្សរហូតដល់ ៨% ដែលលែងទាក់ទងជាមួយគ្រូ ក្រោយពេលបិទប្រទេសរយៈពេល ៣ សប្តាហ៍រួចមក។

# ជំពូកទី ៣៖ ទិន្នន័យ

**ទិន្នន័យស្តីពីបរិយាបន្នក្នុងវិស័យអប់រំ និងទិន្នន័យសម្រាប់លើកកម្ពស់បរិយាបន្នក្នុងការអប់រំ សុទ្ធតែជាទិន្នន័យដែលមានសារៈសំខាន់។** ទិន្នន័យស្តីពីបរិយាបន្ន អាចបង្ហាញឱ្យឃើញពីគម្លាតឱកាសអប់រំ និងលទ្ធផលនៃការអប់រំក្នុងចំណោមក្រុមអ្នករៀនសូត្រ ជួយកំណត់ពីអ្នកប្រឈមនឹងត្រូវបានគេទុកចោល និងភាពធ្ងន់ធ្ងរនៃឧបសគ្គដែលពួកគេជួបប្រទះ។ តាមរយៈប្រើប្រាស់ព័ត៌មានបែបនេះ រដ្ឋាភិបាលអាចរៀបចំគោលនយោបាយលើកកម្ពស់បរិយាបន្ន និងអាចប្រមូលព័ត៌មានបន្ថែមទៀតអំពីការអនុវត្ត និងអំពីលទ្ធផលផ្នែកគុណវិស័យដែលគេមិនសូវមើលឃើញ។

**ការបង្កើតសំណួរឱ្យបានសមស្របអំពីលក្ខណៈនានាដែលពាក់ព័ន្ធនឹងភាពងាយរងគ្រោះ អាចជារឿងដែលមានលក្ខណៈរសើប។** ទិន្នន័យអំពីគម្លាតផ្នែកអប់រំនៅកម្រិតប្រជាជនទូទៅ ដែលត្រូវបានប្រមូលតាមរយៈជំរឿន និងការអង្កេត ធ្វើឱ្យក្រសួងអប់រំដឹងពីបញ្ហាគម្លាតបែបនេះ។ ទោះជាយ៉ាងណាក៏ដោយ អាស្រ័យទៅតាមការរៀបចំសំណួរ សំណួរស្តីពីលក្ខណៈមួយចំនួន ដូចជា សញ្ជាតិ ជាតិពន្ធុ សាសនា និន្នាការភេទ និងអត្តសញ្ញាណយេនឌ័រ ជាដើម អាចធ្វើឱ្យប៉ះពាល់ដល់អត្តសញ្ញាណបុគ្គលដែលមានលក្ខណៈរសើប មានលក្ខណៈឈ្លានពានលើភាពជាឯកជន និងនាំឱ្យមានការភ័យខ្លាចត្រូវបានគេធ្វើបាបជាដើម។

**ការរៀបចំសំណួរផ្តោតលើពិការភាព មានលក្ខណៈល្អប្រសើរជាងមុន។** ការឯកភាពគ្នាលើរង្វាស់ពិការភាព ដែលមានសុពលភាពអាចប្រើប្រាស់បាន បានឆ្លងកាត់ដំណើរការមួយដ៏យូរ។ ក្រុមវ៉ាស៊ីងតោនដែលទទួលបន្ទុកលើស្ថិតិពិការភាព នៃគណៈកម្មការស្ថិតិរបស់អង្គការសហប្រជាជាតិ បានលើកស្នើឱ្យមានការប្រើប្រាស់សំណួរបំព្រួញខ្លីសម្រាប់ធ្វើជំរឿន ឬការអង្កេតក្នុងឆ្នាំ ២០០៦ ដែលគ្របដណ្តប់លើមុខងារ និងសកម្មភាពសំខាន់ៗរបស់មនុស្សពេញវ័យ។ បន្ទាប់មក ម៉ូឌុលផ្តោតលើកុមារត្រូវបានរៀបចំឡើង រួមជាមួយនឹងយូនីសេហ្វ។ សំណួរទាំងនេះ ធ្វើឱ្យស្ថិតិពិការភាពមានលក្ខណៈស្របគ្នាជាមួយនឹងម៉ូដែលសង្គមនៃពិការភាព និងដោះស្រាយបញ្ហាដ៏ធ្ងន់ធ្ងរពាក់ព័ន្ធនឹងភាពអាចប្រៀបធៀបគ្នាបាននៃទិន្នន័យ។ ការប្រើប្រាស់កម្រងសំណួរទាំងនេះកំពុងមានការកើនឡើងជាបណ្តើរៗ។

**ភស្តុតាងថ្មីៗអំពីពិការភាព គាន់តែមានគុណភាពខ្ពស់ជាងមុន ប៉ុន្តែនៅមានលក្ខណៈរដេបរដុបនៅឡើយ។** ការវិភាគលើប្រទេសចំនួន ១៤ ដែលចូលរួមនៅក្នុងការអង្កេតសំណុំសូចនាករចម្រុះ (MICS) ក្នុងឆ្នាំ ២០១៧-២០១៩ ដោយប្រើប្រាស់ម៉ូឌុលផ្តោតលើកុមារ បានបង្ហាញឱ្យឃើញពីប្រេវ៉ាឡង់ពិការភាព ១២% ចន្លោះពី ៦% ទៅ ២៤% ដោយសារតែអត្រាភាពអន្ទះអន្ទែងក្នុងចិត្ត និងអត្រាធ្លាក់ទឹកចិត្តមានកម្រិតខ្ពស់។ នៅក្នុងប្រទេសទាំងនេះ ក្រុមអ្នកដែលនៅក្រៅសាលា ១៥% គឺជាកុមារ ក្មេងជំទង់ និងយុវជនដែលមានពិការភាព។ បើធៀបនឹងក្រុមដែលមានអាយុប្រហាក់ប្រហែលគ្នាដែលកំពុងរៀននៅក្នុងសាលាបឋមសិក្សា មធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិវិញ ក្រុមដែលមានពិការភាពច្រើនតែនៅក្រៅសាលាក្នុងកម្រិត ១ ភាគរយចំណុច (សម្រាប់កុមារ) ៤ ភាគរយ

ចំណុច(សម្រាប់ក្មេងជំទង់)និង៦ភាគរយចំណុច(សម្រាប់យុវជន)បើធៀបនឹងអ្នកដែលមិនពិការ។ហើយសម្រាប់អ្នកដែលមានពិការភាពផ្នែកញាណដឹង កាយសម្បទា ឬបញ្ញាវិញ ភាគរយចំណុចគឺ ៤ ភាគរយចំណុច (សម្រាប់កុមារ) ៧ ភាគរយចំណុច (សម្រាប់ក្មេងជំទង់) និង ១១ ភាគរយចំណុច (សម្រាប់យុវជន)។

**ការអង្កេតសាលារៀនមួយចំនួន ផ្តល់ព័ត៌មានកាន់តែស៊ីជម្រៅបន្ថែមទៀត អំពីបរិយាបន្ន។** ក្នុងកម្មវិធីវាយតម្លៃសិស្សជាលក្ខណៈអន្តរជាតិ(PISA)ឆ្នាំ២០១៨ក្នុងចំណោមសិស្សអាយុ១៥ឆ្នាំចំនួន៥នាក់មាន១នាក់រាយការណ៍ថាមានអារម្មណ៍ដូចនៅក្រៅសាលាដែរ ប៉ុន្តែភាគរយនេះកើនឡើងលើសពី ៣០% ក្នុងប្រទេសប្រ៊ុយណេដារូសាឡឹម សាធារណរដ្ឋដូមីនី និងសហរដ្ឋអាមេរិក។ ក្នុងគ្រប់ប្រព័ន្ធអប់រំដែលចូលរួមនៅក្នុងការវាយតម្លៃនេះ សិស្សដែលមានស្ថានភាពសង្គមសេដ្ឋកិច្ចកាន់តែទាប កាន់តែមានអារម្មណ៍ថា ខ្លួនជាសមាជិកសាលារៀនកាន់តែតិចដែរ។ គេអាចប្រើប្រាស់ទិន្នន័យរដ្ឋបាល ដើម្បីប្រមូលភស្តុតាងគុណវិស័យអំពីបរិយាបន្ន។ ប្រទេសនូវែសេឡង់ធ្វើការពិនិត្យតាមដានសូចនាករទន់ (soft indicator) ក្នុងលក្ខណៈជាប្រព័ន្ធនៅថ្នាក់ជាតិ ដូចជា ថាតើសិស្សមានអារម្មណ៍ថាតើមានគេយកចិត្តទុកដាក់ចំពោះពួកគេមានសុវត្ថិភាពនិងមានសន្តិសុខដែរឬទេនិងអំពីលទ្ធភាពរបស់ពួកគេក្នុងការបង្កើតនិងរក្សាទំនាក់ទំនងជាវិជ្ជមាន គោរពតម្រូវការរបស់អ្នកដទៃ និងបង្ហាញពីការយល់ចិត្តជាដើម។ ប្រទេសដែលមានប្រាក់ចំណូលទាប និងមធ្យមជិតពាក់កណ្តាល ពុំបានប្រមូលទិន្នន័យរដ្ឋបាលអំពីសិស្សមានពិការភាពនោះឡើយ។

**ទិន្នន័យបង្ហាញពីប្រទេសដែលនៅតែបែងចែកសិស្សទៅតាមប្រភេទផ្សេងៗគ្នា។** នៅក្នុងប្រទេសប្រេស៊ីលការផ្លាស់ប្តូរគោលនយោបាយនាំឱ្យភាគរយសិស្សមានពិការភាពដែលរៀននៅសាលារៀនទូទៅ កើនឡើងពី ២៣% ក្នុងឆ្នាំ ២០០៣ ដល់ ៨១% ក្នុងឆ្នាំ ២០១៥។ នៅអាស៊ីប៉ាស៊ីហ្វិកវិញកុមារមានពិការភាពជិត៨០%រៀននៅក្នុងសាលារៀនទូទៅចាប់ពី៣%ក្នុងប្រទេសគីហ្សៀកស្ថានរហូតដល់១០០%ក្នុងប្រទេសទីម័រខាងកើត និងប្រទេសថៃ។ ទិន្នន័យដែលនៅរប៉ាត់រប៉ាយជាច្រើន បង្ហាញពីសាលារៀនដែលផ្តោតការយកចិត្តទុកដាក់លើក្រុមជាក់លាក់ ដូចជា កុមារី ក្រុមដែលប្រើប្រាស់ភាសាភាគតិច និងសហគមន៍សាសនាជាច្រើន។ ការរួមចំណែករបស់សហគមន៍ទាំងនេះក្នុងបរិយាបន្ននៅពុំទាន់មានភាពច្បាស់លាស់នៅឡើយ៖ ឧទាហរណ៍ សាលាជនជាតិដើមភាគតិចអាចផ្តល់នូវបរិយាកាសដែលមានការគោរពប្រពៃណី វប្បធម៌ និងបទពិសោធន៍របស់ជនជាតិដើមភាគតិច ប៉ុន្តែក៏អាចធ្វើឱ្យកុមារបាត់បង់ឱកាសផងដែរ។ ការអង្កេតសាលារៀន ដូចជា PISA ជាដើម បង្ហាញឱ្យឃើញពីការបែងចែកសិស្សទៅតាមស្ថានភាពសង្គមសេដ្ឋកិច្ចក្នុងកម្រិតមួយខ្ពស់នៅតាមបណ្តាប្រទេសនានា ដូចជាប្រទេសឈីលី និងម៉ិចស៊ីកូជាដើម ដែលក្នុងនោះសិស្សពាក់កណ្តាលត្រូវបានបែងចែកសាលារៀនឡើងវិញ ដើម្បីឱ្យមានសិស្សក្នុងភាគរយដូចៗគ្នា ដែលមានស្ថានភាពសង្គមសេដ្ឋកិច្ចចម្រុះ។ ការបែងចែកសាលារៀនប្រភេទនេះ ហាក់បីដូចជាពុំមានការប្រែប្រួលនោះឡើយ ពីឆ្នាំ ២០០០-២០១៥។

**ការកំណត់ពីតម្រូវការអប់រំពិសេសអាចមានភាពចម្រូងចម្រាស់។** ការកំណត់ពីតម្រូវការអប់រំពិសេសអាចផ្តល់ជាព័ត៌មានដល់គ្រូអំពីតម្រូវការរបស់សិស្ស ដើម្បីឱ្យពួកគេអាចផ្តល់ការគាំទ្រ និងការសម្របសម្រួលឱ្យចំនួនអ្វីដែលសិស្សត្រូវការ។ ទោះជាយ៉ាងណាក៏ដោយកុមារអាចត្រូវបានមិត្តភក្តិគ្រូនិងអ្នកគ្រប់គ្រងសាលាដាក់ឈ្មោះហៅក្រៅឱ្យដែលអាចជំរុញឱ្យមានឥរិយាបថប្រកាន់គំនិតអវិជ្ជមានចំពោះសិស្សដែលត្រូវបានគេដាក់ស្លាកសម្គាល់ និងលើកទឹកចិត្តឱ្យមានការអនុវត្តគោលវិធីវេជ្ជសាស្ត្រ។ កាលពីពេលថ្មីៗនេះ ប្រទេសព័រទុយហ្គាល់ បានដាក់ឱ្យអនុវត្តច្បាប់មួយដែលតម្រូវឱ្យមានការប្រើប្រាស់វិធីសាស្ត្រមិនបែងចែកប្រភេទ ដើម្បីកំណត់ពីតម្រូវការពិសេស។ការរំពឹងទុកទាបដោយសារការដាក់ស្លាកសម្គាល់ដូចជាកុមារមានការលំបាកក្នុងការរៀនសូត្រជាដើមអាចធ្វើឱ្យកុមារទាំងនេះធ្វើបានត្រឹមតែការរំពឹងទុក។ នៅអឺរ៉ុប ភាគរយសិស្សដែលត្រូវបានកំណត់ថាមានតម្រូវការអប់រំពិសេស មានចាប់ពី ១% ក្នុងប្រទេសស៊ុយអែត រហូតដល់ ២០% នៅក្នុងប្រទេសស្កុតលែន។ ពិការភាពខាងការរៀនសូត្រ គឺជាប្រភេទតម្រូវការពិសេសធំជាងគេនៅសហរដ្ឋអាមេរិក ប៉ុន្តែជាអ្វីដែលគេមិនដឹងនៅប្រទេសជប៉ុនឡើយ។ គេអាចពន្យល់ពីការប្រែប្រួលខុសៗគ្នាបែបនេះ តាមរយៈភាពខុសប្លែកគ្នានៃរបៀបដែលប្រទេសកំណត់ពីប្រភេទនៃការអប់រំ នៅពេលដែលលក្ខខណ្ឌតម្រូវខាងស្ថាប័ន ការផ្តល់ថវិកាគាំទ្រ និងការបណ្តុះបណ្តាលមានការប្រែប្រួលខុសៗគ្នា បច្ច័យគោលនយោបាយក៏មានការប្រែប្រួលខុសៗគ្នាទៅតាមនោះដែរ។

# ជំពូកទី ៤៖ អភិបាលកិច្ច និងហិរញ្ញប្បទាន

**ការធានានូវការអប់រំបរិយាបន្នមិនមែនជាការទទួលខុសត្រូវរបស់អ្នកតាក់តែងគោលនយោបាយអប់រំតែឯងនោះឡើយ។** ការផ្តល់សេវារួមបញ្ចូលគ្នា អាចកែលម្អរបៀបដែលគេគិតពីតម្រូវការរបស់កុមារ ក៏ដូចជាជួយបង្កើនគុណភាព និងប្រសិទ្ធភាពចំណាយនៃសេវានានា។ ការផ្តល់សេវារួមបញ្ចូលគ្នាបែបនេះអាចសម្រេចទៅបាននៅពេលដែលអ្នកផ្តល់សេវាមួយធ្វើជាទីកន្លែង សម្រាប់បញ្ជូនទៅកាន់អ្នកផ្តល់សេវាមួយផ្សេងទៀត។ ផែនទីដែលបង្ហាញពីការផ្តល់សេវាអប់រំបរិយាបន្ននៅក្នុងប្រទេសអឺរ៉ុបចំនួន ១៨ ដែលភាគច្រើនលើកឡើងពីសិស្សដែលមានពិការភាព បានបង្ហាញថា ក្រសួងអប់រំ គឺជាក្រសួងដែលទទួលខុសត្រូវលើគ្រូបង្រៀន ការគ្រប់គ្រងរដ្ឋបាលសាលារៀន និងឯកសាររៀន, ក្រសួងសុខាភិបាលទទួលបន្ទុកលើការផ្តល់សេវាពិនិត្យបឋមវាយតម្លៃ និងស្តារនីតិសម្បទា, ហើយក្រសួងគាំពារសង្គមទទួលបន្ទុកលើជំនួយហិរញ្ញវត្ថុ។

**ការបែងចែកការទទួលខុសត្រូវ មិនធានាឱ្យមានការសហការ កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលតាមខ្សែទទឹងនោះឡើយ។** បទដ្ឋានប្រពៃណី វប្បធម៌ ការងារបែបការិយាធិបតេយ្យ ដែលចាក់ឫសយ៉ាងជ្រៅ រារាំងមិនឱ្យមានការធ្វើអន្តរកាលយ៉ាងរលូនពីទម្រង់នៃការផ្តល់សេវាដាច់ដោយឡែកពីគ្នានោះឡើយ។ ការពុំមានធនធានគ្រប់គ្រាន់ ក៏អាចជាកត្តាមួយផងដែរ៖ នៅក្នុងប្រទេសកេនយ៉ា ១ ភាគ ៣ នៃមជ្ឈមណ្ឌលធនធានសម្រាប់វាយតម្លៃការអប់រំ ដែលត្រូវបានបង្កើតឡើង ដើម្បីពង្រីកការផ្តល់សេវាអប់រំដល់កុមារមានពិការភាព មានមន្ត្រីតែម្នាក់ប៉ុណ្ណោះ ផ្ទុយពីគំនិតចង់បានក្រុមពហុជំនាញដែលគ្រោងបង្កើតពីដំបូង។ ចាំបាច់ត្រូវមានការកំណត់ស្តង់ដារឱ្យបានច្បាស់លាស់ និងអាចវាស់វែងបាន ដែលរៀបរាប់ពីការទទួលខុសត្រូវរបស់ភាគីនានា។ ប្រទេសវ៉ាន់ដាបានរៀបចំស្តង់ដារដែលជួយឱ្យមន្ត្រីអធិការធ្វើការវាយតម្លៃពីបរិយាបន្ននៅក្នុងថ្នាក់រៀន។ នៅក្នុងប្រទេសចរដង់ តួអង្គផ្សេងៗគ្នាប្រើប្រាស់ស្តង់ដារខុសៗគ្នា ដើម្បីផ្តល់អាជ្ញាប័ណ្ណ និងទទួលស្គាល់គុណភាពមជ្ឈមណ្ឌលអប់រំពិសេស។ យុទ្ធសាស្ត្ររយៈពេល ១០ ឆ្នាំ ដែលជាយុទ្ធសាស្ត្រថ្មី នឹងឆ្លើយតបចំពោះបញ្ហានេះ។

**ចាំបាច់ត្រូវមានការធ្វើសមាហរណកម្មតាមខ្សែបណ្តោយ នៅតាមកម្រិតនានារបស់រដ្ឋាភិបាល និងការគាំទ្រដល់អាជ្ញាធរមូលដ្ឋាន។** រដ្ឋាភិបាលថ្នាក់ជាតិ ត្រូវផ្តល់ថវិកាគាំទ្រដល់អាជ្ញាធរឱ្យបានពេញលេញ និងធ្វើការអភិវឌ្ឍសមត្ថភាពរបស់ពួកគេ។ កំណែទម្រង់របស់សាធារណរដ្ឋម៉ុលដូវ៉ា ដើម្បីដកកុមារចេញពីសាលារៀនរដ្ឋភាគច្រើនដែលតម្រូវឱ្យកុមារស្នាក់នៅក្នុងសាលារៀន ត្រូវជាប់គាំង ដោយសារតែពុំមានការផ្ទេរថវិកាទៅឱ្យស្ថាប័នរបស់អាជ្ញាធរមូលដ្ឋាន និងដល់សាលារៀនដែលស្រូបយកកុមារទាំងនេះ។ នៅប្រទេសនេប៉ាល់ ការវាយតម្លៃពាក់កណ្តាលអាណត្តិលើកម្មវិធីសាលារៀន និងក្នុងសិក្ខាសាលាលើកទី ១ ស្តីពីការអប់រំបរិយាបន្ន បានបង្ហាញថា ខណៈពេលដែលមុខតំណែងមួយចំនួននៅរដ្ឋបាលថ្នាក់កណ្តាល ត្រូវបានផ្លាស់ប្តូរ ជាផ្នែកមួយនៃការធ្វើវិមជ្ឈការ សមត្ថភាពរបស់អាជ្ញាធរមូលដ្ឋានក្នុងការគាំទ្រដល់ការផ្តល់សេវាអប់រំ នៅមានកម្រិតខ្សោយនៅឡើយ។

**ការផ្តល់ថវិកាគាំទ្រចំនួន ៣ ប្រភេទ មានសារៈសំខាន់ ដើម្បីសម្រេចឱ្យបាននូវសមធម៌ និងបរិយាបន្នក្នុងការអប់រំ។** ទី ១ រដ្ឋាភិបាលអាច ឬមិនអាចបំពេញបន្ថែមលើការទទួលបានថវិកាតិចតួច នៅពេលធ្វើការវិភាជន៍ធនធានដល់អាជ្ញាមូលដ្ឋាន ឬសាលារៀន តាមរយៈឥណទានរាប់តាមចំនួនសិស្សនោះឡើយ។ រដ្ឋាភិបាលសហព័ន្ធរបស់ប្រទេសអាហ្សង់ទីន វិភាជន៍ឥណទានថវិ (block grant) ទៅឱ្យរដ្ឋបាលខេត្ត ដោយធ្វើការពិចារណាពីចំនួនប្រជាជននៅជនបទ និងចំនួនសិស្សក្រៅសាលា។ ខេត្តចូលរួមបដិភាគគាំទ្រដល់វិស័យអប់រំដោយយកថវិកាចេញពីចំណូលរបស់ខ្លួន ដែលកម្រិតមានការប្រែប្រួលខុសៗគ្នា ពីខេត្តមួយទៅខេត្តមួយទៀត ដែលជាកត្តាធ្វើឱ្យមានបញ្ហាវិសមភាព។ ទី ២ គោលនយោបាយ និងកម្មវិធីផ្តល់ហិរញ្ញប្បទានដល់វិស័យអប់រំ អាចផ្តោតលើសិស្ស និងគ្រួសាររបស់ពួកគេ ក្នុងទម្រង់ជាការផ្តល់សាច់ប្រាក់ (ឧទាហរណ៍ អាហារូបករណ៍) និងការលើកលែងការបង់ថ្លៃ (ឧទាហរណ៍ ថ្លៃសេវា) ជាដើម។ ក្នុងចំណោម

ប្រទេសចំនួន ៤ មានប្រទេសប្រហែល ១ ដែលមានកម្មវិធីអនុវត្តន៍វិធានការជាវិជ្ជមាន ដើម្បីបង្កើនការទទួលបានសេវាអប់រំនៅកម្រិតទុតិយភូមិ។ទី៣គោលនយោបាយនិងកម្មវិធីផ្តល់ហិរញ្ញប្បទានដែលមិនផ្តោតជាក់លាក់លើការអប់រំអាចមានឥទ្ធិពលជំផងលើការអប់រំ។ នៅក្នុងរយៈពេលវែង ការឧបត្ថម្ភសាច់ប្រាក់ដែលមានលក្ខខណ្ឌ នៅអាមេរិកឡាទីនបានបង្កើនកម្រិតនៃការអប់រំចន្លោះពី ០,៥ ទៅ ១,៥ ឆ្នាំ។

**ការផ្តល់ហិរញ្ញប្បទានដល់ការអប់រំបរិយាបន្នដែលផ្តោតលើកុមារមានពិការភាព ទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀត។** គួរមានការប្រើប្រាស់អភិក្រមភ្លោះ (twin-track approach) សម្រាប់ផ្តល់ហិរញ្ញប្បទាន ដោយមានការបំពេញបន្ថែមដល់យន្តការទូទៅ តាមរយៈកម្មវិធីដែលផ្តោតចំគោលដៅ។ អ្នកតាក់តែងគោលនយោបាយចាំបាច់ត្រូវធ្វើការកំណត់ពីស្តង់ដារ សម្រាប់សេវាដែលត្រូវផ្តល់ និងចំណាយដែលត្រូវរ៉ាប់រង។ អ្នកតាក់តែងគោលនយោបាយ ចាំបាច់ត្រូវឆ្លើយតបចំពោះបញ្ហាប្រឈមដែលកើតឡើងដោយសារការប៉ោងចំណាយ នៅពេលដែលអត្រារកឃើញអ្នកដែលមានតម្រូវការពិសេសមានការកើនឡើង និងរៀបចំវិធីសាស្ត្រ ដើម្បីផ្តល់អាទិភាពហិរញ្ញប្បទាននិងផ្តល់សេវាដើម្បីឆ្លើយតបទៅនឹងតម្រូវការផ្សេងៗគ្នា។អ្នកតាក់តែងគោលនយោបាយក៏ចាំបាច់ត្រូវធ្វើការកំណត់ពីលទ្ធផលដែលនៅតែបន្តការដាក់សម្ពាធលើអាជ្ញាធរមូលដ្ឋាន និងសាលារៀន ដើម្បីបញ្ចៀសមិនឱ្យមានការផ្តល់សេវាដាច់ដោយឡែកដល់កុមារដែលត្រូវបានកំណត់ថាមានតម្រូវការពិសេស និងរៀបចំកន្លែងផ្តល់សេវាដោយឡែកសម្រាប់ពួកគេ ដោយធ្វើឱ្យប៉ះពាល់ដល់ក្រុមដទៃទៀត ឬប៉ះពាល់ដល់តម្រូវការហិរញ្ញប្បទានជាទូទៅ។ ប្រទេសហ្វាំងឡង់ កំពុងធ្វើដំណើរក្នុងទិសដៅនេះ។

**សូម្បីតែប្រទេសអ្នកមាន ក៏ខ្វះព័ត៌មានអំពីការផ្តល់ហិរញ្ញប្បទានដល់ការអប់រំសិស្សមានពិការភាពផងដែរ។** គម្រោងមួយដែលរៀបចំផែនទីបង្ហាញពីការផ្តល់ហិរញ្ញប្បទានដល់ការអប់រំបរិយាបន្ននៅប្រទេសអឺរ៉ុបបានរកឃើញថាក្នុងចំណោមប្រទេសចំនួន១៨មានត្រឹមតែ ៥ ប៉ុណ្ណោះដែលមានព័ត៌មានពាក់ព័ន្ធ។ ពុំមានយន្តការផ្តល់ហិរញ្ញប្បទានដែលល្អឥតខ្ចោះនោះឡើយ ព្រោះថាប្រទេសនីមួយៗមានប្រវត្តិខុសៗគ្នា មានការយល់ដឹងអំពីការអប់រំបរិយាបន្ន និងកម្រិតវិមជ្ឈការផ្សេងៗពីគ្នា។ ប្រទេសមួយចំនួនតូច កំពុងងាកចេញពីការប្រើប្រាស់មេគុណចម្រុះ (ឧទាហរណ៍ ប្រភេទភាពខ្សោយ) ដែលអាចបំប៉ោងចំនួនសិស្សដែលត្រូវបានកំណត់ថាមានតម្រូវការពិសេស ទៅប្រើប្រាស់រូបមន្តផ្តល់ថវិកាបែបសាមញ្ញទៅឱ្យសាលារៀនទូទៅវិញ។ ប្រទេសជាច្រើនបង្កើតបណ្តាញ ដើម្បីឱ្យមានការចែករំលែកធនធានបរិក្ខារ និងឱកាសអភិវឌ្ឍន៍សមត្ថភាព។

**ប្រទេសក្រីក្រច្រើនជួបការលំបាកក្នុងការផ្តល់ថវិកាគាំទ្រ ដើម្បីឱ្យមានការផ្លាស់ប្តូរចេញពីការអប់រំពិសេស ទៅជាការអប់រំបរិយាបន្ន។** ប្រទេសមួយចំនួន បានបង្កើនថវិការបស់ខ្លួន ដើម្បីលើកកម្ពស់បរិយាបន្នសម្រាប់សិស្សមានពិការភាព។ ថវិកាសម្រាប់ឆ្នាំ ២០១៨/១៩ របស់ប្រទេសម៉ោរីទីស បានបង្កើន ៤ ដង នូវថវិកាប្រចាំឆ្នាំក្នុងសិស្ស ១ នាក់ សម្រាប់ចំណាយលើសម្ភារឧបទេស ទឹកភ្លើង សង្ហារឹម និងសម្ភារសម្រាប់សិស្សដែលមានតម្រូវការពិសេស។

## កម្មវិធីសិក្សា សៀវភៅសិក្សា និងការវាយតម្លៃ

**ជម្រើសកម្មវិធីសិក្សា អាចជាកត្តាជំរុញ ឬរារាំងដល់ការសម្រេចបាននូវបរិយាបន្ន និងប្រជាធិបតេយ្យនៅក្នុងសង្គម។** កម្មវិធីសិក្សាចាំបាច់ត្រូវផ្តល់ការធានាដល់ក្រុមដែលប្រឈមនឹងការផាត់ចេញទាំងអស់ថា ត្រូវមានការបញ្ចូលពួកគេទៅក្នុងគម្រោងអប់រំ ទាំងក្នុងខ្លឹមសារ ទាំងក្នុងការអនុវត្ត។ ការប្រើប្រាស់កម្មវិធីសិក្សាផ្សេងៗគ្នា ដែលមានស្តង់ដារខុសៗគ្នាសម្រាប់ក្រុមមួយចំនួន អាចរារាំងមិនឱ្យមានការសម្រេចបាននូវបរិយាបន្ន និងនាំឱ្យមានការមាក់ងាយ។ ទោះជាយ៉ាងណាក៏ដោយ ប្រទេសជាច្រើននៅប្រើប្រាស់កម្មវិធីសិក្សា

ពិសេសសម្រាប់បង្រៀនសិស្សមានពិការភាព ផ្តល់ឱ្យសិស្សដែលជាជនភៀសខ្លួននៅតែកម្មវិធីសិក្សាដែលយកមកពីប្រទេសកំណើតរបស់ពួកគេប៉ុណ្ណោះ ដើម្បីលើកទឹកចិត្តឱ្យពួកគេធ្វើមាតុភូមិនិវត្តន៍វិញ និងច្រើនតែរុញច្រានសិស្សដែលសម្រេចបានលទ្ធផលសិក្សាទាបឱ្យទៅរៀនក្នុងកម្មវិធីអប់រំដែលមានល្បឿនយឺត។ បញ្ហាប្រឈមកើតមានឡើងនៅក្នុងបរិបទជាច្រើន៖ ក្រុមប្រជាជនដែលបាត់បង់ទីលំនៅក្នុងប្រទេសបូស្នានិងហេហ្សេហ្គូវីណា, បញ្ហាយេនឌ័រនៅប្រទេសប៉េរូ, ក្រុមដែលប្រើភាសាភាគតិចនៅប្រទេសថៃ, ជនភៀសខ្លួនជនជាតិប៊ូរុនឌី និងកុងហ្គោ ដែលកំពុងឋិតនៅក្នុងសាធារណរដ្ឋតង់ហ្សានី, ជនជាតិដើមភាគតិចនៅកាណាដា។ នៅអឺរ៉ុប ក្នុងចំណោមប្រទេសចំនួន ៤៩ មានប្រទេសចំនួន ២៣ ពុំបានឆ្លើយតបឱ្យបានច្បាស់លាស់ចំពោះបញ្ហានិន្នាការភេទ និងអត្តសញ្ញាណយេនឌ័រនោះឡើយ។

**កម្មវិធីសិក្សាបរិយាបន្នចាំបាច់ត្រូវតែមានភាពពាក់ព័ន្ធ មានភាពទន់ភ្លន់ និងឆ្លើយតបចំពោះតម្រូវការ។** កស្តុតាងដែលទទួលបានពីការវាយតម្លៃ ដឹកនាំដោយប្រជាពលរដ្ឋនៅអាស៊ីខាងត្បូង និងអាហ្វ្រិកសាប់សាហារ៉ា បានរំលេចឱ្យឃើញពីគម្លាតដ៏ធំ រវាងគោលដៅនៃកម្មវិធីសិក្សា និងលទ្ធផលនៃការសិក្សា។ នៅពេលដែលកម្មវិធីសិក្សាផ្តោតតែលើសិស្សដែលមានបុព្វសិទ្ធិ និងផ្តោតតែលើចំណេះដឹងតែមួយចំនួនវិសមភាពក្នុងការអនុវត្តនឹងកើតមានឡើងរវាងតំបន់ជនបទនិងតំបន់ប្រជុំជនដូចដែលបានបង្ហាញក្នុងការសិក្សាវាយតម្លៃលើកម្មវិធីសិក្សាគណិតវិទ្យាថ្នាក់បឋមសិក្សានៅប្រទេសអ៊ូហ្គង់ដា។ការរៀនសូត្រដោយប្រើប្រាស់ភាសាកំណើតមានសារៈសំខាន់យ៉ាងខ្លាំងជាពិសេសនៅសាលាបឋមសិក្សា ដើម្បីបង្ការមិនឱ្យមានគម្លាតចំណេះដឹងខុសៗគ្នា និងបង្កើនល្បឿននៃការសិក្សា និងការយល់ដឹង។ នៅក្នុងរដ្ឋអូឌីស្សា នៃប្រទេសឥណ្ឌា ការអប់រំពហុភាសា មាននៅក្នុងសាលាបឋមសិក្សាប្រមាណ ១.៥០០ កន្លែង និងមានការបង្រៀនដោយប្រើប្រាស់កុលសម្ព័ន្ធចំនួន ២១ ភាសា។ នៅទូទាំងសកលលោក មានប្រទេសត្រឹមតែ ៤១ ប៉ុណ្ណោះដែលទទួលស្គាល់ភាសាសញ្ញាជាភាសាផ្លូវការ ក្នុងនោះ ២១ ប្រទេសឋិតនៅក្នុងសហភាពអឺរ៉ុប។ នៅក្នុងប្រទេសអូស្ត្រាលី សិស្ស ១៩% ទទួលបានការកែសម្រួលក្នុងកម្មវិធីសិក្សា។ កម្មវិធីសិក្សាមិនគួរនាំទៅរកភាពទាល់ច្រកក្នុងការអប់រំនោះឡើយ ប៉ុន្តែត្រូវផ្តល់នូវគន្លងផ្លូវសម្រាប់ទទួលបានឱកាសអប់រំបន្ត។

**សៀវភៅសិក្សាអាចនាំឱ្យមានការប្រកាន់ផ្នត់គំនិតអវិជ្ជមាន។** ការបង្ហាញពីជនជាតិភាគតិច ភាសាភាគតិច សាសនា និងជនជាតិដើមភាគតិចនៅក្នុងសៀវភៅសិក្សា អាស្រ័យយ៉ាងច្រើនលើបរិបទប្រវត្តិសាស្ត្រ និងបរិបទរបស់ជាតិ។ កត្តាដែលមានឥទ្ធិពលលើការប្រតិបត្តិចំពោះក្រុមភាគតិចនៅក្នុងប្រទេស រួមមាន វត្តមានរបស់ជនជាតិដើមភាគតិច ការគ្របលុបផ្នែកប្រជាសាស្ត្រ នយោបាយ ឬសេដ្ឋកិច្ចរបស់ក្រុមជាតិពន្ធមួយ ឬច្រើន ប្រវត្តិនៃការបែងចែកជាក្រុម ឬប្រវត្តិនៃការមានជម្លោះ និងការប្រកាន់គំនិតជាតិនិយមន័យ ព្រមទាំងតួនាទីនៃការធ្វើអន្តោប្រវេសន៍។ សៀវភៅសិក្សាអាចទទួលស្គាល់ក្រុមជនជាតិភាគតិច តាមបែបផែនដែលនាំឱ្យមានការកាត់បន្ថយ ឬបង្កើនកម្រិតនៃការយល់ឃើញរបស់ពួកគេផ្ទាល់ ឬរបស់អ្នកដទៃចំពោះពួកគេថាជាមនុស្សផ្សេងទៀត។ ការប្រើរូបភាពនិងការពិពណ៌នាមិនសមស្រប ដែលភ្ជាប់ទំនាក់ទំនងលក្ខណៈមួយចំនួនជាមួយនឹងក្រុមប្រជាជនខ្លះ អាចធ្វើឱ្យសិស្សមកពីក្រុមដែលមិនមានលក្ខណៈគ្របលុបនៅក្នុងសង្គម មានអារម្មណ៍ថា មានការបង្ហាញព័ត៌មានអំពីពួកគេខុសពីការពិត មានការយល់ច្រឡំពីពួកគេ ធ្វើឱ្យពួកគេមិនសប្បាយចិត្ត មានអារម្មណ៍ថា ជាអ្នកនៅខាងក្រៅក្រុមទូទៅ។ នៅតាមប្រទេសជាច្រើន ជារឿយៗ ពុំមានការបង្ហាញព័ត៌មានឱ្យបានគ្រប់គ្រាន់ពីស្ត្រីនោះឡើយ ហើយស្ត្រីតែងទទួលរងការប្រកាន់ផ្នត់គំនិតអវិជ្ជមាន។ ភាគរយនៃការបង្ហាញពីស្ត្រីនៅក្នុងអត្ថបទ និងរូបភាពក្នុងសៀវភៅសិក្សាភាសាអង់គ្លេសដែលប្រើនៅថ្នាក់មធ្យមសិក្សា គឺ ៤០% ក្នុងប្រទេសឥណ្ឌូនេស៊ី, ៣៧% ក្នុងប្រទេសបង់ក្លាដែស, និង ២៤% ក្នុងខេត្តប៉ុនចាប ប្រទេសប៉ាគីស្ថាន។ ស្ត្រីធ្វើការងារនៅក្នុងមុខរបរដែលមិនសូវផ្តល់ឱ្យពួកគេនូវបុព្វសិទ្ធិ និងជាអ្នកដែលស្រគត់ស្រគំមិនសូវចូលចិត្តនិយាយស្តីច្រើន។

**ការវាយតម្លៃដែលមានគុណភាពល្អ គឺជាផ្នែកមួយដ៏សំខាន់នៃប្រព័ន្ធអប់រំបរិយាបន្ន។** ជារឿយៗ ការវាយតម្លៃត្រូវបានរៀបចំឡើងបែបចង្អៀតសម្រាប់ធ្វើការកំណត់ពីលទ្ធភាពចុះឈ្មោះចូលរៀននៅតាមសាលារៀនមួយចំនួនឬដាក់ឱ្យចូលរៀននៅក្នុងសាលារៀនផ្សេង ឬជាការបញ្ជូនសញ្ញាប្រទាំងប្រទើសគ្នាអំពីការប្តេជ្ញាចិត្តលើកកម្ពស់បរិយាបន្នរបស់រដ្ឋាភិបាល។ឧទាហរណ៍ការវាយតម្លៃលទ្ធផលសិក្សាទ្រង់ទ្រាយធំទូទាំងប្រទេស ច្រើនតែផាត់សិស្សដែលមានពិការភាព ឬសិស្សដែលមានការលំបាកក្នុងការរៀនសូត្រចេញ។ ការវាយតម្លៃគួរផ្តោតការយកចិត្តទុកដាក់លើកិច្ចការរបស់សិស្ស៖ តើពួកគេធ្វើកិច្ចការទាំងនោះដោយរបៀបណា តើកិច្ចការណាខ្លះដែលពិបាក និងពីការកែសម្រួលចំណុចមួយចំនួន ដើម្បីជួយឱ្យពួកគេទទួលបានជោគជ័យ។ ការផ្លាស់ប្តូរការយកចិត្តទុកដាក់ពីការវាយតម្លៃលើលទ្ធផលសិក្សានៅចុងភូមិសិក្សា ដែលជាការវាយតម្លៃទ្រង់ទ្រាយធំ ទៅជាការវាយតម្លៃដំណើរការរៀនសូត្របណ្តើរៗ គឺជាកិច្ចខិតខំប្រឹងប្រែងដ៏សំខាន់ ដើម្បីឱ្យការវាយតម្លៃមានភាពសមស្របសម្រាប់គោលបំណងនៃការអប់រំបរិយាបន្ន។ ការជួយសម្រួលពេលធ្វើតេស្ត គឺជាអ្វីដែលសំខាន់ និងចាំបាច់ ប៉ុន្តែគេអាចចោទសួរសុពលភាពនៃតេស្តទាំងនេះ ព្រោះថាតេស្តទាំងនេះហាក់បីដូចជាធ្វើឡើងសម្របទៅតាមស្ថានភាពរបស់សិស្ស។ ផ្ទុយទៅវិញ គួរមានការយកចិត្តទុកដាក់លើរបៀបដែលការវាយតម្លៃអាចជួយឱ្យសិស្សដែលមានភាពខ្សោយអាចបង្ហាញពីអ្វីដែលពួកគេបានរៀន។ នៅក្នុងប្រទេសសាប់សាហារ៉ាចំនួន ៧ ពុំមានគ្រូបង្រៀនណាមានចំណេះដឹងកម្រិតអប្បបរមាអំពីការវាយតម្លៃសិស្សនោះឡើយ។

**ចាំបាច់ត្រូវមានការបន្សុីកគ្នាជាច្រើន ដើម្បីឱ្យកម្មវិធីសិក្សា សៀវភៅសិក្សា និងកំណែទម្រង់វាយតម្លៃមានលក្ខណៈមានលក្ខណៈបរិយាបន្ន។** ចាំបាច់ត្រូវមានការអភិវឌ្ឍសមត្ថភាព ដើម្បីឱ្យអ្នកពាក់ព័ន្ធអាចសហការធ្វើការងារជាមួយគ្នា និងគិតពិចារណាជាលក្ខណៈយុទ្ធសាស្ត្រ។ ចាំបាច់ត្រូវមានការបង្កើតភាពជាដៃគូ ដើម្បីផ្តល់លទ្ធភាពឱ្យភាគទាំងអស់ធ្វើជាម្ចាស់លើដំណើរការ និងធ្វើការងារដើម្បីឈានទៅសម្រេចគោលដៅតែមួយ។ កិច្ចខិតខំប្រឹងប្រែងប្រកបដោយជោគជ័យ ដើម្បីធ្វើយ៉ាងណាឱ្យកម្មវិធីសិក្សា សៀវភៅសិក្សា និងការវាយតម្លៃមានលក្ខណៈបរិយាបន្ន ទាមទារឱ្យមានដំណើរការដែលមានការចូលរួមក្នុងអំឡុងពេលរៀបចំ អភិវឌ្ឍន៍ និងអនុវត្តន៍។

# គ្រូ និងបុគ្គលិកគាំទ្រការអប់រំ

**ក្នុងការអប់រំបរិយាបន្ន គួរមានការរៀបចំបណ្តុះបណ្តាលគ្រូទាំងអស់ឱ្យចេះបង្រៀនសិស្សទាំងអស់។** បរិយាបន្នមិនអាចសម្រេចទៅបានឡើយ លុះត្រាតែគ្រូបង្រៀនក្លាយជាភ្នាក់ងារដែលនាំមកនូវការផ្លាស់ប្តូរ និងមានគុណតម្លៃ ចំណេះដឹង ព្រមទាំងឥរិយាបថ ដែលជួយឱ្យសិស្សគ្រប់រូបទទួលបានជោគជ័យ។ជារឿយៗឥរិយាបថរបស់គ្រូរួមមានការប្តេជ្ញាចិត្តគោរពតាមគោលការណ៍បរិយាបន្នដោយពួកគេត្រូវមានមន្ទិលអំពីការត្រៀមខ្លួនរបស់ពួកគេនិងថាតើប្រព័ន្ធអប់រំបានត្រៀមរួចរាល់កម្រិតណាដើម្បីផ្តល់ការគាំទ្រដល់ពួកគេ។គ្រូបង្រៀនមិនអាចចៀសផុតពីការលម្អៀង និងការប្រកាន់ផ្នត់គំនិតក្នុងសង្គមបានឡើយ។ ការបង្រៀនដែលមានលក្ខណៈបរិយាបន្ន តម្រូវឱ្យគ្រូបើកចំហទទួលយកភាពចម្រុះ និងត្រូវដឹងថាសិស្សទាំងអស់រៀនចេះតាមរយៈការផ្សារភ្ជាប់ទំនាក់ទំនងរវាងថ្នាក់រៀន ជាមួយបទពិសោធន៍ក្នុងជីវិត។ខណៈពេលដែលឱកាសអប់រំនិងរៀនសូត្រជាលក្ខណៈវិជ្ជាជីវៈជាច្រើនសម្រាប់គ្រូត្រូវបានរៀបចំឡើងជាមួយនឹងការយល់ឃើញថាសិស្សមួយចំនួនមានភាពខ្វះខាត មិនអាចរៀនបាន ឬពុំមានសមត្ថភាព មានន័យថាគ្រូអាចមានការលំបាកក្នុងការបើកចំហចិត្តមើលឃើញពីសមត្ថភាពរៀនសូត្ររបស់សិស្សម្នាក់ៗ។

**ការខ្វះការត្រៀមខ្លួន ដើម្បីធ្វើការបង្រៀនប្រកបដោយបរិយាបន្ន អាចកើតឡើងដោយសារការខ្វះចំណេះដឹងគរុកោសល្យ។** ក្នុងការអង្កេតជាអន្តរជាតិលើការបង្រៀន និងរៀនឆ្នាំ២០១៨គ្រូប្រមាណ២៥%បានលើកឡើងពីតម្រូវការខ្ពស់ចង់បានការអភិវឌ្ឍវិជ្ជាជីវៈផ្តោតលើការបង្រៀនសិស្សដែលមានតម្រូវការពិសេស។ ក្នុងប្រទេសអាហ្វ្រិកសាប់សាហារ៉ា ដែលនិយាយភាសាបារាំងចំនួន ១០ គ្រូបង្រៀនថ្នាក់ទី ២ និងថ្នាក់ទី ៦ ៨% បានទទួលការបណ្តុះបណ្តាលវិក្រឹតការអំពីការអប់រំបរិយាបន្ន។ ការដោះស្រាយបញ្ហាដែលកើតមានកន្លងមកក្នុងការរៀបចំគ្រូប្រភេទផ្សេងៗគ្នាឱ្យចេះបង្រៀនសិស្សប្រភេទខុសៗគ្នាក្នុងបរិបទដាច់ដោយឡែកពីគ្នាគឺជារឿងមួយដ៏សំខាន់។ ដើម្បីឱ្យមានគុណភាពល្អ ការអប់រំគ្រូត្រូវផ្តោតលើទិដ្ឋភាពជាច្រើននៃការអប់រំបរិយាបន្ន សម្រាប់អ្នករៀនសូត្រគ្រប់រូប ចាប់ពីបច្ចេកទេសបង្រៀន និងការគ្រប់គ្រងថ្នាក់រៀន រហូតដល់ក្រុមពហុជំនាញ និងវិធីសាស្ត្រវាយតម្លៃលើការរៀនសូត្រ និងគួរមានបញ្ចូលការតាមដាន និងការគាំទ្រ ដើម្បីជួយឱ្យគ្រូអាចយកជំនាញដែលពួកគេទើបរៀនចេះថ្មីបញ្ចូលទៅក្នុងការអនុវត្តនៅក្នុងថ្នាក់រៀន។ ក្នុងខេត្តញូប្រ៊ុនស្វិករបស់កាណាដា គោលនយោបាយស្តីពីការអប់រំបរិយាបន្នដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ បានផ្តល់ឱកាសបណ្តុះបណ្តាលដល់គ្រូដើម្បីឱ្យពួកគេចេះបង្រៀនសិស្សអូទីសឹម។

**គ្រូត្រូវការលក្ខខណ្ឌការងារ និងការគាំទ្រឱ្យបានសមស្រប ដើម្បីឱ្យពួកគេអាចសម្របសម្រួលការបង្រៀនរបស់ពួកគេឱ្យស្រប តាមតម្រូវការរបស់សិស្ស។** នៅក្នុងប្រទេសកម្ពុជា គ្រូបង្រៀនចោទជាសំណួរលើលទ្ធភាពក្នុងការយកគោលវិធីគរុកោសល្យបែបកុមារមជ្ឈមណ្ឌលទៅប្រើប្រាស់ក្នុងបរិបទថ្នាក់រៀនដែលមានសិស្សច្រើនកកកុញ និងដែលមានធនធានបង្រៀនតិចតួច និងកម្មវិធីសិក្សាដែលមានមហិច្ឆតាខ្ពស់។ ការបង្រៀនតាមខ្លឹមសារស្តង់ដារដែលជាលក្ខខណ្ឌតម្រូវសម្រាប់ការវាយតម្លៃលើការសិក្សា អាចធ្វើឱ្យគ្រូកាន់តែមានការពិបាកក្នុងការកែសម្រួលការបង្រៀនរបស់ពួកគេ។ កិច្ចសហប្រតិបត្តិការរវាងគ្រូ និងគ្រូនៅតាមសាលាផ្សេងៗគ្នា អាចជួយឱ្យពួកគេឆ្លើយតបចំពោះបញ្ហាប្រឈមដែលកើតឡើងដោយសារភាពចម្រុះរបស់សិស្ស ជាពិសេសនៅក្នុងប្រព័ន្ធដែលងាកចេញពីការបែងចែកសិស្សទៅតាមប្រភេទទៅជាប្រព័ន្ធបរិយាបន្ន។ ពេលខ្លះការសហការបែបនេះពុំមានឡើយ សូម្បីតែរវាងគ្រូ និងគ្រូក្នុងសាលារៀនតែមួយ។ ក្នុងប្រទេសស្រីលង្កា មានគ្រូបង្រៀនតិចអ្នកដែលបង្រៀនក្នុងថ្នាក់រៀនទូទៅប៉ុណ្ណោះដែលសហការជាមួយនឹងគ្រូបង្រៀនដទៃទៀតដែលបង្រៀនសិស្សមានតម្រូវការពិសេសដូចគ្នា។

**ការកើនឡើងនូវចំនួនបុគ្គលិកផ្តល់ការគាំទ្រ កើតឡើងទន្ទឹមគ្នានឹងការដាក់កុមារដែលមានតម្រូវការពិសេសឱ្យរៀននៅក្នុងសាលារៀនទូទៅ។** ទោះជាយ៉ាងណាក៏ដោយ នៅក្នុងសកលលោកទាំងមូល ការផ្តល់បុគ្គលិកគាំទ្របែបនេះនៅមិនទាន់គ្រប់គ្រាន់នៅឡើយ។ អ្នកឆ្លើយតបចំពោះការអង្កេត ដែលធ្វើឡើងដោយសហព័ន្ធគ្រូបង្រៀន បានលើកឡើងថា បុគ្គលិកគាំទ្រភាគច្រើនអវត្តមាន ឬពុំមាននៅក្នុងប្រទេសយ៉ាងហោចណាស់ ១៥%។ ជំនួយការរៀន ឬបង្រៀនក្នុងថ្នាក់រៀនអាចជួយបានច្រើន។ ទោះជាយ៉ាងណាក៏ដោយ ខណៈពេលដែលពួកគេត្រូវបំពេញតួនាទីបំពេញបន្ថែមឱ្យការងាររបស់គ្រូជារឿយៗពួកគេត្រូវធ្វើការងារច្រើនជាងអ្វីដែលពួកគេត្រូវធ្វើ។ការកើនឡើងនូវការរំពឹងទុកផ្នែកវិជ្ជាជីវៈអមនឹងការផ្តល់ការអភិវឌ្ឍវិជ្ជាជីវៈក្នុងកម្រិតទាបអាចធ្វើឱ្យការរៀនសូត្រមានគុណភាពទាបបង្កការរំខានដល់ការប្រាស្រ័យទាក់ទងរវាងសិស្ស និងសិស្ស កាត់បន្ថយការទទួលបានការបង្រៀនដែលមានគុណភាព និងនាំឱ្យមានការមាក់ងាយ។ នៅក្នុងប្រទេសអូស្ត្រាលី លទ្ធភាពរបស់សិស្សមានពិការភាព ដើម្បីរៀនជាមួយគ្រូដែលមានសមត្ថភាព ត្រូវទទួលរងការបន្ទុចបង្អាក់ខ្លះ ដោយសារតែប្រព័ន្ធនេះពឹងអាស្រ័យខ្លាំងពេកលើបុគ្គលិកគាំទ្រដែលពុំមានសមត្ថភាព។

**ភាពចម្រុះរបស់គ្រូនៅតាមមិនទាន់ភាពចម្រុះរបស់ប្រជាជនទូទៅ។** ពេលខ្លះបញ្ហានេះកើតឡើងដោយសារបញ្ហាមួយចំនួនដែលរារាំងសមាជិកមកពីក្រុមដែលមានឱកាសតិចតួច មិនឱ្យទទួលបានគុណវុឌ្ឍិ អាចបង្រៀននៅតាមសាលារៀននៅពេលដែលពួកគេមានសមត្ថភាព និងបន្តបំពេញវិជ្ជាជីវៈរបស់ពួកគេ។ ប្រព័ន្ធនានាគួរទទួលស្គាល់ថា គ្រូបង្រៀនទាំងនេះអាចជួយលើកកម្ពស់បរិយាបន្ន តាមរយៈការផ្តល់ជាគំនិតពិសេសៗរបស់ពួកគេ និងធ្វើជាគំរូដល់សិស្សគ្រប់រូប។ នៅក្នុងប្រទេសឥណ្ឌា ភាគរយគ្រូមកពីវណ្ណៈផ្សេងៗស្មើនឹង ១៦% នៃប្រជាជនទាំងមូល និងមានការកើនឡើងពី ៩% ទៅ ១៣% ក្នុងចន្លោះពីឆ្នាំ ២០០៥ និង ២០១៣។

# សាលារៀន

**បរិយាបន្ននៅក្នុងការអប់រំ តម្រូវឱ្យមានសាលារៀនបរិយាបន្ន។** គោលការណ៍របស់សាលារៀនដែលសំដៅលើគុណតម្លៃ និងជំនឿដែលត្រូវបានបង្ហាញឱ្យគេឃើញច្បាស់ និងអាចដឹងតាមរយៈការកាត់យល់ ព្រមទាំងទំនាក់ទំនងអន្តរបុគ្គល ដែលជាកត្តាកំណត់ពីបរិយាកាសរបស់សាលារៀន មានទំនាក់ទំនងជាមួយនឹងការអភិវឌ្ឍចិត្តសង្គម និងសុខុមាលភាពរបស់សិស្ស។ ភាគរយរបស់សិស្សនៅក្នុងប្រទេសដែលជាសមាជិករបស់អង្គការសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (OECD) ដែលគិតថាពួកគេ "ជាសមាជិក" នៅក្នុងសាលារៀន ថយចុះពី ៨២% ក្នុងឆ្នាំ ២០០៣ ដល់ ៧៣% ក្នុងឆ្នាំ ២០១៥ ដោយសារតែកំណើនភាគរយសិស្សជនអន្តោប្រវេសន៍ និងការថយចុះនូវការគិតថាខ្លួនជាសមាជិកសាលារៀន ក្នុងចំណោមសិស្សជនជាតិដើមរបស់ប្រទេស។

**នាយកសាលាអាចលើកកម្ពស់បរិយាបន្ន ជាចក្ខុវិស័យរួម ។** នាយកសាលាអាចផ្តល់ការណែនាំអំពីគោលវិធីគរុកោសល្យបែបបរិយាបន្ននិងរៀបចំផែនការអនុវត្តន៍សកម្មភាពអភិវឌ្ឍន៍វិជ្ជាជីវៈ។ការសិក្សាឆ្លងប្រទេសលើគ្រូដែលបង្រៀនសិស្សមានតម្រូវការពិសេសនៅក្នុងសាលារៀនទូទៅ រកឃើញថា អ្នកដែលបានទទួលការបណ្តុះបណ្តាលអំពីការដឹកនាំបង្រៀនកាន់តែច្រើន រាយការណ៍ពីតម្រូវការអភិវឌ្ឍវិជ្ជាជីវៈកាន់តែតិច។ ខណៈពេលដែលភារកិច្ចរបស់នាយកសាលាកាន់តែមានលក្ខណៈស្មុគស្មាញ នាយកសាលា ១ ភាគ ៥ កើនឡើងដល់ពាក់កណ្តាលក្នុងប្រទេសក្រូអាត ពុំបានទទួលការបណ្តុះបណ្តាលអំពីការដឹកនាំការងារបង្រៀននោះឡើយ។ នៅក្នុងប្រព័ន្ធអប់រំចំនួន ៤៧ នាយកសាលា ១៥% (កើនឡើងដល់ជាង ៦០% ក្នុងប្រទេសវៀតណាម) លើកឡើងពីតម្រូវការខ្ពស់ចង់បានការអភិវឌ្ឍវិជ្ជាជីវៈ ដើម្បីឱ្យពួកគេអាចលើកកម្ពស់សមធម៌ និងភាពចម្រុះបាន។

**ការរករឿងរំខាន និងអំពើហិង្សានៅក្នុងសាលារៀន នាំឱ្យមានការផាត់ចេញ។** សិស្សអាយុពី ១១ ទៅ ១៥ ឆ្នាំ ១ ភាគ ៣ ទទួលរងការអុកឡុករករឿងរំខានក្នុងសាលារៀន។ អ្នកដែលត្រូវបានគេយល់ឃើញថាមានលក្ខណៈផ្សេងពីបទដ្ឋានសង្គម ឬអ្វីដែលគេចាត់ទុកថាជាអ្នកលក្ខណៈល្អបំផុតនោះ គឺជាអ្នកដែលទទួលរងគ្រោះច្រើនជាងគេ ដូចជា ក្រុមភេទភាគតិច ក្រុមជនជាតិភាគតិច និងក្រុមកាន់សាសនាភាគតិចកុមារក្រីក្រ និងកុមារដែលមានតម្រូវការពិសេសជាដើម។សិស្សដែលស្រឡាញ់ភេទដូចគ្នានៅប្រទេសនូវែសេឡង់ច្រើនតែទទួលរងការរករឿងរំខានដល់ទៅ ៣ ដង បើធៀបនឹងសិស្សដែលពុំមានលក្ខណៈបែបនេះ។ នៅក្នុងប្រទេសអ៊ូហ្កង់ដា កុមារមានពិការភាព ៨៤% ទទួលរងអំពើហិង្សាពីមិត្តភក្តិឬបុគ្គលិករបស់សាលារៀនបើធៀបនឹង ៥៣% នៃកុមារដែលពុំមានពិការភាព។ការគ្រប់គ្រងថ្នាក់រៀន ការផ្តល់ការណែនាំ និងគោលនយោបាយ គួរកំណត់ពីការទទួលខុសត្រូវនិងសកម្មភាពដែលបុគ្គលិកត្រូវធ្វើ ដើម្បីទប់ស្កាត់និងឆ្លើយតបចំពោះករណីអុកឡុករករឿងរំខាន និងអំពើហិង្សា។ ការដាក់វិន័យ មិនគួរធ្វើឱ្យប៉ះពាល់ដល់ការគាំទ្រដល់សិស្ស និងការបណ្តុះបរិយាកាសដែលមានការគោរពគ្នាទៅវិញទៅមកនោះឡើយ។

**សាលារៀនត្រូវតែជាកន្លែងដែលមានសុវត្ថិភាព និងងាយស្រួលចេញចូល។** ប្រកចូលទៅក្នុងសាលារៀន ការរៀបចំអគារ និងបន្ទប់អនាម័យច្រើនតែបំពានគោលការណ៍ស្តីពីការផ្តល់ភាពងាយស្រួលដល់ការចេញភាពអាចទទួលយកបាននិងភាពអាចកែសម្រួលបាន។ ក្មេងស្រីជាង ១ ភាគ ៤ នៅក្នុងប្រទេសអាហ្វ្រិកអាស៊ី និងអាហ្វ្រិកឡាទីនចំនួន ១១ បានរាយការណ៍ថា មិនដែល ឬកម្រមានអារម្មណ៍សុវត្ថិភាពនៅតាមផ្លូវទៅ ឬមកសាលារៀនណាស់។ ពុំមានសាលារៀនណាមួយនៅក្នុងប្រទេសប៊ូរុនឌី នីហ្សេរីយ៉ា និងសាម័រ បាន "កែសម្រួលហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារឱ្យស្របតាមតម្រូវការរបស់សិស្សមានពិការភាព"។ នៅក្នុងប្រទេសស្លូវ៉ាគី សាលាបឋមសិក្សា ១៥% និងសាលាមធ្យមសិក្សាបឋមភូមិ ២១% បានបំពេញតាមស្តង់ដារទាំងនេះ។ភស្តុតាងប្រហាក់ប្រហែលគ្នាដែលអាចជឿទុកចិត្តបាននៅតែពិបាករកបាន ព្រោះស្តង់ដារប្រទេសនានាមានការប្រែប្រួលខុសៗគ្នា ហើយសាលារៀនពុំបានបំពេញទៅតាមគ្រប់សមាសភាគទាំងអស់របស់ស្តង់ដារឡើយ។ លើសពីនេះ សមត្ថភាពពិនិត្យតាមដាននៅមានកម្រិតខ្សោយ ហើយនៅមិនទាន់មានការពិនិត្យផ្ទៀងផ្ទាត់ទិន្នន័យដោយឯករាជ្យនៅឡើយ។

**ជារឿយៗ ហេដ្ឋារចនាសម្ព័ន្ធដែលផ្តល់ភាពងាយស្រួល ពុំបានផ្តល់ការគាំទ្រដល់ទាំងអស់គ្នានោះឡើយ។** អនុសញ្ញាស្តីពីសិទ្ធិជនពិការអំពាវនាវឱ្យមានការប្រើប្រាស់ការរៀបចំជាសកល ដែលផ្តល់ភាពងាយស្រួលសម្រាប់ទាំងអស់គ្នា (universal design) ដើម្បីជួយសម្រួលដល់ការធ្វើសកម្មភាព និងបំពេញតម្រូវការរបស់គ្រប់គ្នា ដោយមិនគិតពីអាយុ ទំហំ ឬពិការភាពនោះឡើយ។ ការបញ្ចូលសម្ភារូបវន្តដែលអាចឱ្យទាំងអស់គ្នាប្រើប្រាស់បានចាប់ពីដើមដំបូង បង្កើនចំណាយ ១% បើធៀបនឹងចាប់ពី ៥% ក្រោយពេលដែលសម្ភារូបវន្តទាំងនេះត្រូវបានសាងសង់រួចរាល់។កម្មវិធីផ្តល់ជំនួយនានាជួយផ្សព្វផ្សាយពីគោលការណ៍ស្តីពីការរៀបចំប្លង់ជាសកលបែប។ សាលារៀននៅឥណ្ឌូនេស៊ី ដែលសាងសង់ដោយមានការគាំទ្រពីប្រទេសអូស្ត្រាលី មានបញ្ចូលបង្គន់ដែលផ្តល់ភាពងាយស្រួលដល់កុមារមានពិការភាព បង្កាន់ដៃ និងជម្រាល។ រដ្ឋាភិបាលបានប្រើប្រាស់វិធានការស្រដៀងគ្នានេះ សម្រាប់គ្រប់សាលារៀនទាំងអស់។

**បច្ចេកវិទ្យាផ្តល់ជំនួយ អាចកំណត់ពីការចូលរួម ឬការបាត់បង់ឱកាស។** ឧបករណ៍ជំនួយសំដៅលើបច្ចេកវិទ្យាដែលផ្តល់នូវជាតុចូល (ក្តារចុចដែលត្រូវបានកែសម្រួល និងឧបករណ៍ប្រើប្រាស់កុំព្យូទ័រ ការបញ្ចូលសម្តីនិយាយ សុហ្វវៀរសម្រាប់សរសេរតាមអាន) និងបច្ចេកវិទ្យា (សុហ្វវៀរសម្រាប់ជួយសម្រួលដល់ការអានតាមអេក្រង់ និងពង្រីកអក្សរ, ម៉ាស៊ីនបោះពុម្ព 3-D, សុហ្វវៀរកត់ត្រាជាអក្សរប្រេល ជាដើម)។ ប្រព័ន្ធទំនាក់ទំនងបំពេញបន្ថែមជាជម្រើស អាចប្រើប្រាស់ជំនួយសឱ្យការនិយាយស្តី។ ប្រព័ន្ធជួយដល់ការស្តាប់បង្កើនភាពច្បាស់នៃសំឡេង និងកាត់បន្ថយសម្លេងរំខាន។ បច្ចេកវិទ្យាទាំងនេះ ជួយបង្កើនអត្រាបញ្ចប់ការសិក្សា បង្កើនការផ្តល់តម្លៃដល់ខ្លួនឯង និងសុទិដ្ឋិនិយម ប៉ុន្តែជារឿយៗ មិនអាចរកបាននោះឡើយ ដោយសារតែខ្វះធនធាន ឬមិនត្រូវបានគេប្រើមានប្រសិទ្ធភាពដោយការខ្វះការអប់រំគ្រូ។

## សិស្ស មាតាបិតា និងសហគមន៍

**ពិចារណាពីបទពិសោធន៍របស់សិស្សដែលមានឱកាសតិចតួច។** ការប្រមូលចងក្រងទុកជាឯកសារនូវការយល់ឃើញរបស់សិស្សដែលងាយរងគ្រោះ ដោយពុំបង្ហាញពីអត្តសញ្ញាណរបស់ពួកគេ គឺជារឿងដែលពិបាក។ ការផ្តល់អាទិភាពឱ្យពួកគេចូលរួម គឺអាស្រ័យទៅតាមភាពងាយរងគ្រោះរបស់ពួកគេ ប្រភេទសាលាដែលពួកគេទៅរៀន បទពិសោធន៍នៅតាមសាលាប្រភេទផ្សេងៗគ្នា និងកម្រិតនិងភាពជាក់លាក់នៃការគាំទ្រឯកទេស។ សិស្សងាយរងគ្រោះដែលរៀននៅតាមសាលារៀនទូទៅ អាចយល់ពីតម្លៃនៃការរៀននៅក្នុងសាលារៀនផ្សេង ដូចជាការបង្កើនការយកចិត្តទុកដាក់ ឬកាត់បន្ថយសំឡេងរំខានជាដើម។ ការផ្គូផ្គងសិស្សឱ្យរៀនជាមួយមិត្តភក្តិដែលមានពិការភាព អាចបង្កើនការទទួលយក និងការយល់ពីស្ថានភាពរបស់អ្នកដទៃ បើទោះបីជាការធ្វើបែបនេះមិនធានាឱ្យមានបរិយាបន្ននៅខាងក្រៅសាលារៀនយ៉ាងណាក៏ដោយ។

**ក្រុមប្រជាជនភាគច្រើន ច្រើនតែប្រកាន់ផ្នត់គំនិតអវិជ្ជមានចំពោះសិស្សភាគតិច និងសិស្សដែលមានឱកាសតិចតួច។** ឥរិយាបថអវិជ្ជមាននាំឱ្យមានការកាត់បន្ថយការទទួលយក ការដាក់ឱ្យនៅដាច់ដោយឡែកពីគេ និងការរករឿងរំខាន។ ជនជាតិកៀសខ្លួនជនជាតិស៊ីរីនៅក្នុងប្រទេសទួគី ដែលទទួលរងការប្រកាន់ផ្នត់គំនិតអវិជ្ជមាន កើតជំងឺធ្លាក់ទឹកចិត្ត ទទួលរងការមាក់ងាយ និងការចាត់ទុកថាជាមនុស្សដែលមានលក្ខណៈផ្សេងពីគេនៅក្នុងសាលារៀន។ ការប្រកាន់ផ្នត់គំនិតអវិជ្ជមានធ្វើឱ្យថយចុះការរំពឹងទុក និងការផ្តល់តម្លៃឱ្យខ្លួនឯងរបស់សិស្ស។នៅក្នុងប្រទេសស្វីស កុមារីប្រកាន់គំនិតថាពួកគេមិនសមនឹងរៀនមុខវិជ្ជាវិទ្យាសាស្ត្របច្ចេកវិទ្យាវិស្វកម្មនិងគណិតវិទ្យាដូចកុមារានោះឡើយ ដែលជាកត្តាមិនលើកទឹកចិត្តឱ្យពួកគេបន្តការអប់រំក្នុងជំនាញទាំងនេះនោះឡើយ។ គ្រូអាចអាចតស៊ូប្រឆាំងនឹងការរើសអើង ប៉ុន្តែក៏ជាអ្នកដែលនាំឱ្យមានការរើសអើងក្នុងការអប់រំផងដែរ។ គ្រូបង្រៀនគណិតវិទ្យា នៅទីក្រុងសៅប៉ាឡូ ប្រទេសប្រេស៊ីល ច្រើនតែឱ្យសិស្សស្បែកសជាប់ បើធៀបនឹងសិស្សស្បែកខ្មៅដែលចេះស្ទាត់ជំនាញ និងមានឥរិយាបថល្អដូចគ្នា។ គ្រូនៅប្រទេសចិន មានការយល់ឃើញមិនសូវជាល្អចំពោះសិស្សចំណាកស្រុកមកពីជនបទឡើយ បើធៀបនឹងសិស្សដែលជាអ្នកទីក្រុង។

**ឪពុកម្តាយជំរុញឱ្យមានការអប់រំបរិយាបន្ន ប៉ុន្តែក៏ជាអ្នកដែលមិនចង់ឱ្យមានការអប់រំបរិយាបន្នដែរ។** ឪពុកម្តាយអាចមានជំនឿដែលមានការរើសអើងអំពីយេនឌ័រ ពិការភាព ជាតិពន្ធុ ពូជសាសន៍ សាសនា ឬពិការភាព។ ឪពុកម្តាយប្រមាណជា ១៥% ភាគរយនៅអាល្លឺម៉ង់ និង ៥៩% នៅហុងកុង ប្រទេសចិន ក្លាយថាកុមារមានពិការភាពបង្កការរំខានដល់ការរៀនសូត្ររបស់កុមារផ្សេងទៀត។ ប្រសិនបើមានជម្រើស ឪពុកម្តាយចង់បញ្ជូនកូនដែលងាយរងគ្រោះរបស់ពួកគេទៅសាលារៀន ដែលអាចធានាបាននូវសុខុមាលភាពរបស់ពួកគេ។ ពួកគេចាំបាច់ត្រូវជឿទុកចិត្តលើសាលារៀនទូទៅថាអាចឆ្លើយតបចំពោះតម្រូវការរបស់កូនៗពួកគេបាន។ នៅពេលដែលកិច្ចការសាលាកាន់តែពិបាក នៅពេលដែលកុមារមានអាយុកាន់តែច្រើន ឪពុកម្តាយដែលមានកូនអូទីសឹមប្រហែលជាត្រូវរកសាលារៀនទាំងឡាយណាអាចបំពេញតាមតម្រូវការកូនៗរបស់ពួកគេបានកាន់តែល្អ។នៅរដ្ឋឃ្វីនស្លែន ប្រទេសអូស្ត្រាលី សិស្ស៣៧%ដែលរៀននៅសាលាពិសេស គឺជាសិស្សដែលបានផ្លាស់ចេញពីសាលារៀនទូទៅ។

**ការសម្រេចចិត្តជ្រើសរើសសាលារៀនរបស់ឪពុកម្តាយ ប៉ះពាល់ដល់បរិយាបន្ន និងការបែងចែកសិស្សជាប្រភេទផ្សេងៗគ្នា។** គ្រួសារដែលមានជម្រើស អាចចៀសវាងមិនជ្រើសរើសយកសាលាដែលជួបការលំបាក នោះឡើយ។ នៅតាមទីក្រុងក្នុងប្រទេសដាណាម៉ាក ការកើនឡើង ៧ ភាគរយចំណុចនៃភាគរយសិស្សដែលជាជនទេសន្តរប្រវេសន៍ មានទំនាក់ទំនងជាមួយនឹងការកើនឡើង ១ ភាគរយចំណុចនៃភាគរយសិស្សជនជាតិដើម ដែលរៀននៅសាលាឯកជន។ នៅក្នុងប្រទេសលីបង់ ឪពុកម្តាយភាគច្រើនផ្តល់អាទិភាពដល់សាលាឯកជនដែលកាន់សាសនាដូចពួកគេ។ នៅក្នុងប្រទេសម៉ាឡេស៊ី សាលារៀនឯកជនត្រូវបានរៀបចំទៅតាមជាតិពន្ធុ និងបែងចែកទៅតាមគុណភាពដែលនាំឱ្យមានការបែងចែកចំណាត់ថ្នាក់សាលារៀនឯកជន បើទោះបីជារដ្ឋាភិបាលមានវិធានការមិនធ្វើការបែងចែកសាលារៀនជាប្រភេទៗក៏ដោយ។ បើទោះបីជាការអប់រំទូទៅដែលធ្វើពីចម្ងាយ និងតាមប្រព័ន្ធអនឡាញមានសក្តានុពលលើកកម្ពស់បរិយាបន្នយ៉ាងណាក៏ដោយ បំណងផ្ទាល់ខ្លួនរបស់ឪពុកម្តាយដែលសុខចិត្តបែងចែកខ្លួនឯងឱ្យនៅដាច់ពីគេ តាមរយៈការបង្រៀនកូននៅផ្ទះ ជាការធ្វើតេស្តលើដែនកំណត់នៃការអប់រំបរិយាបន្ន។

**ជារឿយៗ ឪពុកម្តាយដែលមានកូនមានពិការភាព ច្រើនស្ថិតនៅក្នុងស្ថានភាពដែលធ្វើឱ្យពួកគេមានការពិបាក។** ឪពុកម្តាយត្រូវការការគាំទ្រ ដើម្បីកំណត់បញ្ហាឱ្យបានទាន់ពេលវេលា និងចេះគ្រប់គ្រងបញ្ហាពាក់ព័ន្ធនឹងការគេងឥរិយាបថ ការមើលថែ ការផ្តល់ភាពកក់ក្តៅ និងការថែទាំដល់កូនរបស់ពួកគេ។ កម្មវិធីកំណត់អត្តសញ្ញាណទាន់ពេលវេលា អាចជួយឱ្យពួកគេមានទំនុកចិត្ត ចេះប្រើប្រាស់សេវាគាំទ្រផ្សេងទៀត និងចុះឈ្មោះកូនរបស់ពួកគេឱ្យរៀននៅក្នុងសាលារៀនទូទៅ។ កម្មវិធីផ្តល់ការគាំទ្រដល់គ្នាទៅវិញទៅមក អាចបង្កើនសាមគ្គីភាព ទំនុកចិត្ត និងព័ត៌មាន។ ឪពុកម្តាយដែលមានពិការភាព ច្រើនតែមានជីវភាពក្រីក្រ មិនសូវទទួលបានការអប់រំ និងប្រឈមនឹងឧបសគ្គក្នុងការមកសាលារៀន ឬធ្វើការងារជាមួយនឹងគ្រូ។ នៅក្នុងប្រទេសវៀតណាម កូនដែលមានឪពុកម្តាយដែលមានពិការភាពមានអត្រាចូលរៀនទាបជាងកុមារដែលឪពុកម្តាយមិនមានពិការភាព ១៦%។

**សង្គមស៊ីវិលគឺជាអ្នកស្វែងរកការគាំទ្រ និងជាអ្នកឃ្លាំមើលសិទ្ធិទទួលបានការអប់រំបរិយាបន្ន។** អង្គការតំណាងឱ្យជនមានពិការភាព អង្គការជនពិការ សមាគមមាតាបិតា ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ដែលកំពុងធ្វើសកម្មភាពក្នុងវិស័យអភិវឌ្ឍន៍ និងអប់រំ ពិនិត្យតាមដានការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាល រៀបចំយុទ្ធនាការ ដើម្បីជំរុញឱ្យមានការបំពេញសិទ្ធិ និងការពារការរំលោភបំពានសិទ្ធិក្នុងការទទួលបានការអប់រំបរិយាបន្ន។ នៅក្នុងប្រទេសអាមេនី យុទ្ធនាការដែលរៀបចំដោយអង្គការក្រៅរដ្ឋាភិបាលមួយ នាំឱ្យមានការបង្កើតក្របខ័ណ្ឌច្បាប់ និងក្របខ័ណ្ឌថវិកា ដើម្បីពង្រីកការអប់រំបរិយាបន្ននៅទូទាំងប្រទេសត្រឹមឆ្នាំ ២០២៥។

**ក្រុមសង្គមស៊ីវិល ផ្តល់សេវាអប់រំ តាមរយៈការកិច្ចសន្យាជាមួយរដ្ឋាភិបាល ឬតាមរយៈការផ្តើមគំនិតខ្លួនឯង។** សេវាទាំងនេះ អាចផ្តល់ការគាំទ្រដល់ក្រុមដែលសេវារបស់រដ្ឋាភិបាលមិនបានទៅដល់ (ឧទាហរណ៍ កុមារអនាថា) ឬផ្តល់នូវជម្រើសផ្សេង បន្ថែមលើសេវាដែលផ្តល់ដោយរដ្ឋាភិបាល។ គោលនយោបាយស្តីពីការអប់រំបរិយាបន្នរបស់ប្រទេសហ្គាណា អំពាវនាវឱ្យអង្គការក្រៅរដ្ឋាភិបាលធ្វើការកៀរគរធនធានស្វែងរកការគាំទ្រ ដើម្បីឱ្យមានការបង្កើនថវិកា រួមចំណែកដល់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងចូលរួមនៅក្នុងការពិនិត្យតាមដាន និងវាយតម្លៃ។ រដ្ឋាភិបាលរបស់អាហ្វហ្កានីស្ថាន គាំទ្រដល់ការអប់រំតាមសហគមន៍ ដែលត្រូវពឹងអាស្រ័យលើប្រជាពលរដ្ឋនៅនឹងមូលដ្ឋាន។ទោះជាយ៉ាងណាក៏ដោយ សាលារៀនរបស់អង្គការក្រៅរដ្ឋាភិបាលដែលបង្កើតឡើងសម្រាប់ក្រុមជាក់លាក់អាចនាំឱ្យមានការបែងចែកកុមារតាមប្រភេទទៅវិញ ជាជាងជំរុញឱ្យមានបរិយាបន្នក្នុងការអប់រំ។ អង្គការទាំងនេះគួរបន្ស៊ីខ្លួនឱ្យស្របតាមគោលនយោបាយ និងមិនត្រូវផ្តល់សេវាដដែលៗ ឬប្រជែងគ្នា ដើម្បីទទួលបានថវិកាដែលមានចំនួនតិចតួចទៅហើយនោះឡើយ។



# អនុសាសន៍

**ទាំងអស់គ្នាមានន័យថាទាំងអស់គ្នា៖ ភាពចម្រុះរបស់អ្នករៀនសូត្រ គឺជាចំណុចខ្លាំងដែលត្រូវអបអរសាទរ**

ពិភពលោកប្តេជ្ញាសម្រេចឱ្យបាននូវការអប់រំបរិយាបន្ន មិនមែនជាការចៃដន្យនោះឡើយ ដោយសារតែការអប់រំបរិយាបន្ន គឺជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធអប់រំដែលមានគុណភាពល្អដែលជួយឱ្យកុមារ យុវជននិងមនុស្សពេញវ័យគ្រប់រូបរៀនសូត្រនិងបំពេញសក្តានុពលរបស់ពួកគេ។ យេនឌ័រ អាយុ ទីតាំង ភាពក្រីក្រ ពិការភាព ជាតិពន្ធុ ជនជាតិដើមភាគតិច ភាសា សាសនា ទេសន្តរប្រវេសន៍ ឬការបាត់បង់ទីលំនៅ និន្នាការភេទ ឬការសម្តែងចេញនូវអត្តសញ្ញាណយេនឌ័រ ការជាប់ឃុំឃាំង ជំនឿ និងឥរិយាបថ មិនគួរជាមូលដ្ឋានសម្រាប់រើសអើងចំពោះនរណាម្នាក់ក្នុងការចូលរួម និងទទួលបានការអប់រំនោះឡើយ។ លក្ខខណ្ឌដែលសំខាន់គឺគេត្រូវចាត់ទុកភាពចម្រុះរបស់អ្នករៀនសូត្រមិនមែនជាបញ្ហាឡើយ ប៉ុន្តែជាឱកាស។ បរិយាបន្នមិនអាចសម្រេចទៅបានឡើយ ប្រសិនបើគេចាត់ទុកភាពចម្រុះរបស់អ្នករៀនសូត្រថាជាកត្តាដែលនាំឱ្យមានភាពមិនងាយស្រួល ឬប្រសិនបើមនុស្សប្រកាន់ជំនឿថា កម្រិតសមត្ថភាពរបស់អ្នករៀនសូត្រ គឺជាអ្វីដែលមិនអាចកែប្រែបាន។ ប្រព័ន្ធអប់រំចាំបាច់ត្រូវឆ្លើយតបចំពោះតម្រូវការរបស់អ្នករៀនសូត្រទាំងអស់។

អនុសាសន៍ខាងក្រោម បានធ្វើការពិចារណាពីឫសគល់ដ៏សែនជ្រៅនៃឧបសគ្គនានា និងវិសាលភាពដ៏ធំនៃបញ្ហាដែលពាក់ព័ន្ធនឹងបរិយាបន្ន ដែលគំរាមកំហែងដល់ឱកាសរបស់ពិភពលោកក្នុងការសម្រេចតាមចំណុចដៅឆ្នាំ ២០៣០។

## ១. ពង្រីកការយល់ដឹងអំពីការអប់រំបរិយាបន្ន៖ ការអប់រំបរិយាបន្នគួរបញ្ចូលអ្នករៀនសូត្រគ្រប់រូប ដោយមិនប្រកាន់អត្តសញ្ញាណ សាវតារ ឬសមត្ថភាពរបស់ពួកគេឡើយ

បើទោះបីជាសិទ្ធិទទួលបានការអប់រំបរិយាបន្ន គ្របដណ្តប់លើអ្នករៀនសូត្រទាំងអស់គ្នាយ៉ាងណាក៏ដោយ រដ្ឋាភិបាលនៅមិនទាន់រៀបចំច្បាប់ គោលនយោបាយ និងការអនុវត្ត ដោយឈរលើគោលការណ៍ទាំងនេះនៅឡើយ។ ប្រព័ន្ធអប់រំដែលអបអរសាទរភាពចម្រុះ និងជឿថាមនុស្សគ្រប់រូបអាចជួយផ្តល់នូវគុណតម្លៃបន្ថែម មានសក្តានុពល និងគួរទទួលបានការប្រតិបត្តិប្រកបដោយសេចក្តីថ្លៃថ្នូរ ជួយឱ្យគ្រប់គ្នាអាចរៀនចេះ មិនត្រឹមតែចំណេះដឹងមូលដ្ឋានប៉ុណ្ណោះនោះទេ ថែមទាំងជំនាញទូលំទូលាយដែលពិភពលោកត្រូវការ ដើម្បីកសាងសង្គមប្រកបដោយចីរភាពផងដែរ។ នេះមិនមែនពាក់ព័ន្ធនឹងការបង្កើតនាយកដ្ឋានអប់រំបរិយាបន្នឡើយ ផ្ទុយទៅវិញវាមិនមែនជាការរើសអើងចំពោះនរណានោះឡើយ មិនមែនជាការបដិសេធចោលនរណានោះឡើយ ប៉ុន្តែជាការសម្របសម្រួលគ្រប់បែបយ៉ាង ដើម្បីឆ្លើយតបចំពោះតម្រូវការផ្សេងៗគ្នា និងខិតខំធ្វើការងារ ដើម្បីឈានទៅសម្រេចសមភាពយេនឌ័រ។ អន្តរាគមន៍នានា គួរមានភាពស៊ីសង្វាក់គ្នាចាប់ពីកម្រិតកុមារតូច ទៅការអប់រំមនុស្សពេញវ័យ ដើម្បីជួយសម្រួលឱ្យមានការរៀនសូត្រពេញមួយជីវិត។ ដូច្នេះទស្សនៈបរិយាបន្ននេះគួរជាអ្វី ដែលត្រូវយកមកធ្វើការពិចារណា នៅពេលដែលគេរៀបចំផែនការវិស័យអប់រំ។

## ២. ផ្តល់ហិរញ្ញប្បទានឱ្យចំអ្នកដែលត្រូវបានគេទុកចោល៖ ពុំមានបរិយាបន្ននោះឡើយ នៅពេលដែលមនុស្សរាប់លាននាក់ខ្វះលទ្ធភាពទទួលបានការអប់រំ។

នៅពេលដែលលិខិតុករណ៍គតិយុត្តត្រូវបានដាក់ឱ្យអនុវត្តដើម្បីឆ្លើយតបចំពោះឧបសគ្គដែលរារាំងដល់ការទទួលបានសេវាអប់រំដូចជា ពលកម្មកុមារ ការរៀបអាពាហ៍ពិពាហ៍របស់កុមារ និងការមានផ្ទៃពោះរបស់ក្មេងជំទង់ រដ្ឋាភិបាលត្រូវការអភិក្រមភ្លោះ ពោលគឺត្រូវវិភាជនថវិកាទូទៅ ដើម្បីលើកកម្ពស់បរិយាកាសរៀនសូត្របរិយាបន្នសម្រាប់ទាំងអស់គ្នាផង និងការផ្តល់ថវិកាឱ្យចំគោលដៅ ដើម្បី

អាចផ្តល់សេវាដល់អ្នកដែលត្រូវបានគេទុកចោលឱ្យបានឆាប់ តាមដែលអាចធ្វើទៅបានផង។ ក្រោយពេលពួកគេបានចូលរៀនរួច អន្តរាគមន៍ទាន់ពេលវេលា អាចជួយកាត់បន្ថយផលប៉ះពាល់ដែលពិការភាពអាចបង្កឡើងលើការបន្តការរៀនសូត្រ និងការរៀនសូត្រ។

## ៣. ចែករំលែកជំនាញឯកទេស និងធនធាន៖ នេះគឺជាវិធីតែមួយគត់ ដើម្បីរក្សានិរន្តរភាពនៃការធ្វើអន្តរកាលទៅរកបរិយាបន្ន។

ការសម្រេចបរិយាបន្ន គឺជាបញ្ហាប្រឈមនៅក្នុងការគ្រប់គ្រង។ ធនធានមនុស្ស និងធនធានសម្ភារ ដើម្បីឆ្លើយតបចំពោះភាពចម្រុះ នៅខ្វះខាតនៅឡើយ។ កន្លងមក ធនធានទាំងនេះប្រមូលផ្តុំនៅតាមកន្លែងមួយចំនួនតូច ដោយសារតែមានការផ្តល់សេវាបែងចែកតាមប្រភេទខុសៗគ្នា និងពុំមានការបែងចែកឱ្យបានស្មើភាពគ្នានោះឡើយ។ ចាំបាច់ត្រូវមានយន្តការ និងការលើកទឹកចិត្ត ដើម្បីផ្តល់ធនធានទាំងនេះប្រកបដោយភាពទន់ភ្លន់ សំដៅធានាយ៉ាងណាឱ្យមានអ្នកឯកទេសអាចជួយផ្តល់ការគាំទ្រដល់សាលារៀនទូទៅ និងដល់ការអប់រំក្រៅប្រព័ន្ធ។

## ៤. ចូលរួមនៅក្នុងកិច្ចពិគ្រោះយោបល់ប្រកបដោយអត្ថន័យជាមួយនឹងសហគមន៍ និងមាតាបិតា៖ បរិយាបន្នមិនអាចអនុវត្តពីខាងលើទៅនោះឡើយ។

រដ្ឋាភិបាលគួរបើកចំហឱកាសឱ្យសហគមន៍លើកឡើងពីអ្វីដែលពួកគេចង់បាន នៅក្នុងការរៀបចំគោលនយោបាយស្តីពីបរិយាបន្ននៅក្នុងការអប់រំ។ សាលារៀនគួរបង្កើនទំនាក់ទំនងជាមួយនឹងអ្នកនៅខាងក្នុង និងខាងក្រៅបរិវេណសាលារៀន ក្នុងការរៀបចំ និងអនុវត្តន៍សកម្មភាពរបស់សាលារៀន តាមរយៈសមាគមមាតាបិតាសិស្ស និងប្រព័ន្ធផ្គូផ្គងសិស្ស។ គួរមានការផ្តល់តម្លៃដល់ទស្សនៈយល់ឃើញរបស់មនុស្សគ្រប់គ្នា។

## ៥. ធានាឱ្យមានការសហការគ្នារវាងក្រសួង វិស័យ និងកម្រិតផ្សេងៗគ្នារបស់រដ្ឋាភិបាល៖ បរិយាបន្ននៅក្នុងការអប់រំ គឺជាផ្នែកតូចមួយនៃបរិយាបន្នសង្គម

ក្រសួងដែលទទួលខុសត្រូវរួមគ្នាលើការគ្រប់គ្រងចាត់ចែងការអប់រំបរិយាបន្ន ត្រូវសហការគ្នា ដើម្បីកំណត់ពីតម្រូវការ ធ្វើការចែករំលែកព័ត៌មាន និងរៀបចំកម្មវិធីនានា។ រដ្ឋបាលនៅថ្នាក់ជាតិ ចាំបាច់ត្រូវធានាឱ្យមានធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ សម្រាប់គាំទ្រដល់អាជ្ញាធរមូលដ្ឋាន ក្នុងតួនាទីភារកិច្ចផ្តល់សេវាអប់រំបរិយាបន្ន ដូចដែលត្រូវបានកំណត់។

## ៦. ផ្តល់ឱកាសឱ្យតួអង្គក្រៅរដ្ឋាភិបាលជួយបំពេញចំណុចខ្វះខាត៖ ប៉ុន្តែក៏ត្រូវធានាយ៉ាងណាឱ្យពួកគេធ្វើការងារ ដើម្បីឈានទៅសម្រេចគោលដៅបរិយាបន្នដូចគ្នាផងដែរ

រដ្ឋាភិបាលត្រូវដឹកនាំ និងបន្តពិគ្រោះយោបល់ជាមួយនឹងអង្គការក្រៅរដ្ឋាភិបាល ដើម្បីធានាយ៉ាងណាឱ្យការផ្តល់សេវាអប់រំនឹងនាំឱ្យមានបរិយាបន្ន បំពេញតាមស្តង់ដារ និងស្របតាមគោលនយោបាយជាតិ។ រដ្ឋាភិបាលក៏គួរបង្កើតនូវលក្ខខណ្ឌអំណោយផល ដើម្បីឱ្យអង្គការក្រៅរដ្ឋាភិបាលអាចពិនិត្យតាមដាននូវការបំពេញការសន្យារបស់រដ្ឋាភិបាល និងតស៊ូដើម្បីអ្នកដែលត្រូវបានផាត់ចេញពីសេវាអប់រំ។

## ៧. ប្រើប្រាស់ការរៀបចំជាសកល ដែលផ្តល់ភាពងាយស្រួលសម្រាប់ទាំងអស់គ្នា (universal design)៖ ធានាថា ប្រព័ន្ធដែលមានបរិយាបន្នបំពេញសក្តានុពលរបស់អ្នករៀនសូត្រគ្រប់រូប

កុមារគ្រប់រូបគួររៀនសូត្រតាមកម្មវិធីសិក្សាដែលមានលក្ខណៈទន់ភ្លន់ ឆ្លើយតប និងងាយស្រួលយល់ដូចៗគ្នា ពោលគឺកម្មវិធីសិក្សាដែលទទួលស្គាល់ពីភាពចម្រុះ និងឆ្លើយតបទៅនឹងតម្រូវការខុសៗគ្នារបស់អ្នករៀនសូត្រ។ ភាសា និងរូបភាពនៅក្នុងសៀវភៅសិក្សាគួរបង្ហាញឱ្យឃើញពីរូបភាពរបស់មនុស្សគ្រប់គ្នានិងដកចេញនូវខ្លឹមសារទាំងឡាយដែលមានលក្ខណៈប្រកាន់គំនិតអវិជ្ជមាន។ការវាយតម្លៃគួរផ្តោតទៅលើដំណើរការនៃការរៀនសូត្រ និងផ្តល់លទ្ធភាពឱ្យសិស្សបង្ហាញពីការរៀនសូត្រតាមបែបផែនផ្សេងៗគ្នាជាច្រើន។ ហេដ្ឋារចនាសម្ព័ន្ធរបស់សាលារៀន មិនគួរផាត់នរណាម្នាក់ចេញនោះឡើយ និងគួរមានការពិនិត្យស្វែងយល់ពីសក្តានុពលដ៏ធំធេងនៃបច្ចេកវិទ្យា។

## ៨. រៀបចំ ផ្តល់ភាពអង់អាច និងលើកទឹកចិត្តដល់បុគ្គលិកអប់រំ៖ គួរមានការរៀបចំគ្រូបង្រៀនគ្រប់រូបឱ្យចេះបង្រៀនសិស្សគ្រប់រូប

មិនគួរចាត់ទុកគោលវិធីបែបបរិយាបន្ន ថាជាប្រធានបទឯកទេសនោះឡើយ ប៉ុន្តែជាសមាសភាគស្នូលនៃការអប់រំគ្រូ មិនថាជាការអប់រំដំបូង ឬការអភិវឌ្ឍវិជ្ជាជីវៈនោះឡើយ។ កម្មវិធីបែបនេះចាំបាច់ត្រូវឆ្លើយតបចំពោះការយល់ឃើញថាសិស្សមួយចំនួនមានការខ្វះខាត និងពុំមានសមត្ថភាពរៀនសូត្រ។ គួរមានការបំពាក់បំប៉នឱ្យនាយកសាលាចេះអនុវត្ត និងផ្សព្វផ្សាយគោលការណ៍សាលារៀនបរិយាបន្ន។ បុគ្គលិកអប់រំដែលមានលក្ខណៈចម្រុះក៏ជួយគាំទ្រដល់បរិយាបន្នផងដែរ។

## ៩. ប្រមូលទិន្នន័យអំពីបរិយាបន្ន និងទិន្នន័យ ដើម្បីជំរុញឱ្យមានបរិយាបន្ន ដោយយកចិត្តទុកដាក់ និងដោយមានការគោរព៖ ចៀសវាងដាក់ស្លាកសម្គាល់ជាការមាក់ងាយ

ក្រសួងអប់រំ ត្រូវសហការជាមួយនឹងក្រសួងផ្សេងទៀត និងទីភ្នាក់ងារស្ថិតិ ដើម្បីប្រមូលទិន្នន័យប្រជាជនឱ្យបានស៊ីសង្វាក់គ្នាសំដៅស្វែងយល់ពីកម្រិតនៃការជួបការលំបាករបស់ក្រុមដែលមានឱកាសតិចតួច។ ពាក់ព័ន្ធនឹងពិការភាពវិញ គួរផ្តល់អាទិភាពដល់ការប្រើប្រាស់កម្រងសំណួរបំព្រួញរបស់ក្រុមវ៉ាស៊ីនតោន និងម៉ូឌុលដែលបង្ហាញពីសមត្ថភាពធ្វើសកម្មភាពរបស់កុមារ។ ប្រព័ន្ធរដ្ឋបាលគួរខិតខំប្រមូលទិន្នន័យ ដែលជួយដល់ការធ្វើផែនការ និងថវិកា ដើម្បីផ្តល់សេវាអប់រំបរិយាបន្ន ក៏ដូចជាទិន្នន័យអំពីបទពិសោធន៍ជាមួយនឹងបរិយាបន្ន។ ទោះជាយ៉ាងណាក៏ដោយ បំណងចង់បានទិន្នន័យលម្អិត ឬទិន្នន័យជាក់លាក់ មិនគួរជាអាទិភាពជំនួសឱ្យការធានាថានឹងមិនបង្កការឈឺចាប់ដល់អ្នករៀនសូត្រនោះឡើយ។

## ១០. រៀនពីមិត្តភក្តិ៖ ការងាកទៅរកបរិយាបន្ន គឺមិនមែនជារឿងងាយស្រួលនោះឡើយ

បរិយាបន្នមានន័យថាជាការងាកចេញពីការរើសអើង និងបុរេនិច្ច័យ ឆ្ពោះទៅរកអនាគតដែលអាចកែសម្រួលឱ្យស្របតាមបរិបទ និងតថភាពផ្សេងៗ។ គេមិនអាចកំណត់ពីល្បឿន ឬទិសដៅជាក់លាក់នៃអន្តរកាលបានឡើយ។ ប៉ុន្តែគេអាចរៀនសូត្របានច្រើនតាមរយៈការចែករំលែកបទពិសោធន៍ តាមរយៈបណ្តាញគ្រូ វេទិកាជាតិ និងវេទិកាថ្នាក់តំបន់ និងថ្នាក់សកលលោក។

# ឧបករណ៍ PEA

## ឧបករណ៍របាយការណ៍ GEM ថ្មីសម្រាប់ធ្វើការពិនិត្យតាមដានក្នុងលក្ខណៈជាប្រព័ន្ធលើច្បាប់ និងគោលនយោបាយស្តីពីការអប់រំជាតិ




ឧបករណ៍នេះមានគោលបំណងបង្កលក្ខណៈ ងាយស្រួលដល់ការរៀនសូត្រពីគ្នាទៅវិញទៅមក និងលើកទឹកចិត្តឱ្យមានការពិគ្រោះយោបល់ គោលនយោបាយថ្នាក់តំបន់អំពីបញ្ហាដែលមានសារៈសំខាន់សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤។ អ្នកប្រើប្រាស់នៅកម្រិតប្រទេសដែលបានទទួលការអនុញ្ញាត អាចកែសម្រួលអត្ថបទដើម្បីឱ្យខ្លឹមសារនៃរបាយការណ៍នេះនៅតែមានភាពពាក់ព័ន្ធនិងមានបច្ចុប្បន្នភាពហើយគេអាចដោនឡូតខ្លឹមសារនៃរបាយការណ៍នេះបាន។

កំណែដំបូងនៃឧបករណ៍នេះ ប្រមូលចងក្រងព័ត៌មានសម្រាប់ប្រទេសជាង ១៦០ ផ្តោតលើផ្នែកចំនួន ៧ ដែលពាក់ព័ន្ធនឹងបរិយាបន្ន៖ និយមន័យ ការរៀបចំសាលារៀន ច្បាប់ និងគោលនយោបាយអភិបាលកិច្ចការបរិយាកាសនៃការរៀនសូត្រគ្រូបង្រៀននិងបុគ្គលិកផ្តល់ការគាំទ្រ និងការពិនិត្យតាមដាន។ កម្រងព័ត៌មានដែលបង្ហាញពីអ្នកផ្តល់សេវាមិនមែនរដ្ឋ និងក្របខ័ណ្ឌគតិយុត្តសម្រាប់តួអង្គមិនមែនរដ្ឋ នឹងត្រូវរៀបចំឡើងទន្ទឹមគ្នានឹងរបាយការណ៍ GEM សម្រាប់ឆ្នាំ ២០២១។

education-profiles.org

# ទសាលភាព

## ឧបករណ៍របាយការណ៍ GEM ប្រភេទថ្មីដែលមានលក្ខណៈអន្តរកម្មសម្រាប់បង្ហាញ ពីនិន្នាការថ្មីៗ ដើម្បីឈានទៅទៅសម្រេចគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី ៤។




ឧបករណ៍នេះផ្តល់លទ្ធភាពឱ្យអ្នកអាន របាយការណ៍ GEM ពិនិត្យមើលទិន្នន័យស្តីពីសូចនាករពិនិត្យតាមដានសំខាន់ៗ សម្រាប់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពទី ៤ ជាលើកដំបូង។ ប្រធានបទចំនួន ៥ រួមមាន លទ្ធភាពទទួលបានសេវាសមធម៌ ការរៀនសូត្រ គុណភាព និងហិរញ្ញប្បទាន ប្រមូលផ្តុំករណីសិក្សាសំខាន់ៗ ដែលបង្ហាញពីវឌ្ឍនភាពឆ្ពោះទៅសម្រេចចំណុចដៅឆ្នាំ ២០៣០។

ឧបករណ៍នេះអាចរកបានជា៧ភាសានិងប្រមូលទិន្នន័យពីប្រភពចម្រុះ ជាពិសេសវិទ្យាស្ថានស្ថិតិរបស់យូណេស្កូ។ ការបង្ហាញជារូបភាពបែបអន្តរកម្ម ដែលក្នុងនោះមានការប្រើប្រាស់ព័ត៌មានក្នុងរបាយការណ៍ GEM កន្លងមកផងដែរ ផ្តល់លទ្ធភាពឱ្យគេអាចធ្វើការប្រៀបធៀបប្រទេសមួយ និងប្រទេសមួយទៀត ជាមួយនឹងមធ្យមភាគថ្នាក់តំបន់ និងថ្នាក់សកល។ អ្នកប្រើប្រាស់អាចបង្កើតរូបភាព និងឯកសារទិន្នន័យដើម្បីស្វែងយល់បន្ថែមបោះពុម្ពដោនឡូត ចែករំលែក ឬប្រើប្រាស់តាមប្រព័ន្ធអនឡាញ ឬក្នុងបទបង្ហាញ។

education-profiles.org

# ការពិនិត្យតាមដានការអប់រំក្នុងក្របខ័ណ្ឌគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព

**ការអភិវឌ្ឍនៃក្របខ័ណ្ឌពិនិត្យតាមដានគោលដៅអភិវឌ្ឍប្រកបដោយចីរភាព (គ.អ.ច) ទី៤។** នៅក្នុងឆ្នាំ ២០១៩ ក្រុមអ្នកជំនាញអន្តរស្ថាប័ន (IAEG) ទទួលបន្ទុកសូចនាករ គ.អ.ច. បានធ្វើការពិនិត្យជាលើកដំបូងលើក្របខ័ណ្ឌពិនិត្យតាមដាន និងសូចនាករសកលចំនួន ២៣២ នៃគោលដៅនេះ។ មានការអភិវឌ្ឍសំខាន់ៗចំនួន ២ ពាក់ព័ន្ធនឹង គ.អ.ច ទី ៤។

ទី១ក្រុមការងារ IAEG បានអនុម័តលើសំណើរបស់វិទ្យាស្ថានស្ថិតិយូណេស្កូ (UIS) ដើម្បីប្រើប្រាស់អត្រាបញ្ចប់ការសិក្សាជាសូចនាករសកលទី ២ សម្រាប់ចំណុចដៅ ៤.១។ សំណើនេះ បើកចំហលទ្ធភាពឱ្យមានការប៉ាន់ប្រមាណពីសូចនាករនេះ ដោយប្រើប្រាស់គំរូស្ថិតិ ដើម្បីដោះស្រាយបញ្ហាដែលតែងកើតមានជាមួយនឹងការអង្កេតតាមខ្នងផ្ទះ ដូចជា ភាពទាន់ពេលវេលា ការប្រែប្រួល និងប្រភពចម្រុះ ដូចដែលធ្លាប់បានបង្ហាញនៅក្នុងរបាយការណ៍ពិនិត្យតាមដានការអប់រំកម្រិតសកលកន្លងមក។ លទ្ធផលដែលបានពីការប្រើប្រាស់គំរូនេះ គឺជាមុខងារគេហទំព័រពិនិត្យតាមដានអនឡាញថ្មីមួយនៃរបាយការណ៍នេះដែលមានឈ្មោះថា Education Progress ដែលផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់អាចប្រើទិន្នន័យ ដើម្បីសង្កេតមើលនិន្នាការនានា និងធ្វើការប្រៀបធៀបមធ្យមភាគនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់សកល។

ទី ២ ក្រោយពេលប៉ុនប៉ងមិនបានជោគជ័យចំនួន ២ លើករួចមក IAEG បានអនុម័តលើសំណើកែលម្អសូចនាករសកល ៤.៧.១ ស្តីពីកិច្ចខិតខំប្រឹងប្រែងរបស់ប្រព័ន្ធអប់រំ ក្នុងការបញ្ជ្រាបការអភិវឌ្ឍប្រកបដោយចីរភាព និងភាពជាពលរដ្ឋសកល ពីស្ថានភាពកម្រិតទី III (tier III) (ពុំមានវិធីសាស្ត្រណាមួយត្រូវបានបង្កើតឡើង) ទៅជាកម្រិតទី II (tier II) (មានវិធីសាស្ត្រត្រូវបានបង្កើតឡើង ប៉ុន្តែប្រទេសនានាពុំបានផលិតទិន្នន័យឱ្យបានជាប្រចាំ។ ខណៈពេលដែលសូចនាករនេះនៅតែបង្ហាញឱ្យឃើញពីបញ្ហាប្រឈមសំខាន់ៗមួយចំនួន សំណើដែលត្រូវបានកែសម្រួលនេះ បានដាក់ឱ្យអនុវត្តនូវវិន័យមួយចំនួន ជាពិសេសតាមរយៈការតម្រូវឱ្យប្រទេសនានាផ្តល់ឯកសារយោង ដើម្បីគាំទ្រការឆ្លើយតបរៀងៗខ្លួនរបស់ពួកគេ។

គិតត្រឹមខែ មីនា ឆ្នាំ ២០១៩ ក្រុមការងារ IAEG បានកែសម្រួលសូចនាករសកល ៤.២.១ ស្តីពីការអភិវឌ្ឍកុមារអាយុ ៣ ទៅ ៥ ឆ្នាំ ពីកម្រិតទី III ទៅកម្រិតទី II ក្រោយពេលដែលយូនីសេហ្វដែលជាស្ថាប័នទទួលខុសត្រូវលើសូចនាករនេះ បានដាក់ផែនការរបស់ខ្លួនរួចមក។ នេះមានន័យថា បច្ចុប្បន្ននេះពុំមានសូចនាករកម្រិតសកលនៃ គ.អ.ច. ទី ៤ នៅកម្រិតទី III នោះឡើយ។ សូចនាករដែលនៅសេសសល់ នឹងត្រូវទម្លាក់ចោល ក្រោយពេលមានការវាយតម្លៃដោយក្រុមការងារ IAEG។ សូចនាករសកលទាំង ១២ នេះត្រូវបំពេញបន្ថែមដោយសូចនាករតាមប្រធានបទចំនួន ៣១ ក្នុងគោលបំណងបង្កើនការយល់ដឹងអំពីវឌ្ឍនភាពឆ្ពោះទៅសម្រេច គ.អ.ច ទី ៤។ គិតត្រឹមពេលផ្សព្វផ្សាយទិន្នន័យនេះក្នុងឆ្នាំ ២០១៩ UIS កំពុងរៀបចំរបាយការណ៍ស្តីពីសូចនាករសកល និងសូចនាករតាមប្រធានបទចំនួន ៣៣ ក្នុងចំណោមសូចនាករសរុបទាំង ៤៣។

ការអភិវឌ្ឍសំខាន់ជាងគេនៅក្នុងកិច្ចប្រជុំក្រុមការងារសហប្រតិបត្តិការបច្ចេកទេសកាលពីខែសីហាឆ្នាំ២០១៩នៅ Yerevan គឺកិច្ចព្រមព្រៀងស្តីពីការកំណត់ចំណុចដៅអប្បបរមា សម្រាប់សូចនាករនៃចំនួន ៧ នៃ គ.អ.ច ទី ៤ ដែលប្រទេសនីមួយៗក្នុងតំបន់ត្រូវសម្រេចឱ្យបាន។ ឧទាហរណ៍ពាក់ព័ន្ធបំផុតសម្រាប់វិស័យអប់រំ គឺដំណើរការកំណត់ចំណុចដៅរបស់គណៈកម្មការអប់រំសម្រាប់សូចនាករអប់រំចំនួន ៧ ដែលប្រទេសនានានៅសហភាពអឺរ៉ុបត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ ២០២០ ដែលដំណើរការនេះត្រូវយកមកអនុវត្តបន្ត សម្រាប់ចំណុចដៅដែលត្រូវសម្រេចឱ្យបានត្រឹមឆ្នាំ ២០៣០។ សំណើនេះបានទទួលភ្លើងបៃតងពីគណៈកម្មាធិការដឹកនាំ គ.អ.ច សម្រាប់វិស័យអប់រំឆ្នាំ ២០៣០។ គណៈកម្មាធិការដឹកនាំថ្នាក់តំបន់ដែលទទួលខុសត្រូវលើ គ.អ.ច នឹងពិនិត្យលើសំណើនេះក្នុងឆ្នាំ ២០២០។

**បញ្ហាខ្វះទិន្នន័យធំៗសម្រាប់ពិនិត្យតាមដាន គ.អ.ច ទី៤។** ប្រព័ន្ធទិន្នន័យចំនួន ៣ មានសារៈសំខាន់សម្រាប់ពិនិត្យតាមដានវឌ្ឍនភាពនៃសូចនការ គ.អ.ច ទី ៤។

ការអង្កេតតាមខ្នងផ្ទះ គឺជាមូលដ្ឋានសម្រាប់បែងចែកសូចនាករអប់រំទៅតាមប្រភេទ ដូចជា អត្រាបញ្ចប់ការសិក្សាទៅតាមលក្ខណៈនីមួយៗ ដើម្បីប៉ាន់ប្រមាណពីសូចនាករសកល ៤.៥.១ សន្ទស្សន៍យុគភាព។ ការអង្កេតគួរធ្វើឱ្យបានញឹកញាប់។ សំណួរដែលប្រើប្រាស់ក្នុងការអង្កេត ត្រូវអាចយកមកធ្វើការប្រៀបធៀបគ្នាបាន និងត្រូវផ្សព្វផ្សាយទិន្នន័យជាសាធារណៈ។ ប្រទេសចំនួន ៥៩٪ បានបំពេញតាមលក្ខខណ្ឌទាំងនេះ ស្មើនឹង ៨៧٪ នៃចំនួនប្រជាជនសរុប។ បណ្ដាប្រទេសនៅអាហ្វ្រិកខាងជើង និងអាស៊ីខាងលិច មានអត្រាគ្របដណ្ដប់ទាបជាងគេ បើគិតពីចំនួនប្រជាជន (៤៦٪)។ ប្រទេសនៅអូសេអានី មានអត្រាគ្របដណ្ដប់ទាបជាងគេ បើគិតពីចំនួនប្រទេស (២៩٪)។

ការវាយតម្លៃលើលទ្ធផលនៃការសិក្សា គឺជាប្រភពព័ត៌មានសម្រាប់សូចនាករសកល ៤.១.១។ ខណៈពេលដែលប្រទេសជាច្រើន សម្រេចចិត្តរាយការណ៍ពីលទ្ធផលចេញពីការចូលរួមនៅក្នុងការវាយតម្លៃឆ្លងប្រទេស ការវាយតម្លៃនៅតាមប្រទេសក៏ត្រូវបានយកមកប្រើប្រាស់ផងដែរ ដូចជា ទិន្នន័យស្ដីពីបំណិនអំណាន នៅក្នុងប្រទេសមួយចំនួន ដូចជា ប្រទេសចិន (ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ) និងក្នុងប្រទេសឥណ្ឌា (ការអប់រំកម្រិតបឋមសិក្សា) ជាដើម។ ប្រព័ន្ធទិន្នន័យ UIS បង្ហាញថា ប្រទេសនៅអាហ្វ្រិកសាប់សាហារ៉ា ២៩٪ បានរាយការណ៍ពីទិន្នន័យស្ដីពីបំណិនអំណានសម្រាប់ថ្នាក់ដំបូងៗ ឬនៅចុងកម្រិតបឋមសិក្សាចាប់តាំងពីឆ្នាំ ២០១៤ មកស្មើនឹង ៣១٪ នៃចំនួនប្រជាជនសរុប។ តំបន់នេះជួបនឹងបញ្ហា ដោយសារភាពយឺតយ៉ាវក្នុងការបោះពុម្ពផ្សាយរបាយការណ៍ប្រចាំប្រទេស ចាប់គិតពីជុំទី ៤ នៃការវាយតម្លៃលើលទ្ធផលសិក្សាដែលធ្វើឡើង ដោយសម្ព័ន្ធអាហ្វ្រិកខាងត្បូង និងខាងកើត សម្រាប់ពិនិត្យតាមដានលើគុណភាពនៃការអប់រំ និងដោយសារមោនមន្ទិលសង្ស័យលើសុពលភាពនៃលទ្ធផលរបស់ខ្លួន។ បណ្ដាញទិន្នន័យសកល (Global Data Coalition) ដែលសម្របសម្រួលដោយ UIS មានបំណងឆ្លើយតបចំពោះបញ្ហាខ្វះព័ត៌មានអំពីការគាំទ្រដែលអ្នកផ្ដល់ជំនួយផ្ដល់ដល់ការវាយតម្លៃលទ្ធផលសិក្សានៅក្នុងតំបន់នេះ និងការខ្វះការសម្របសម្រួលគំនិតផ្ដួចផ្ដើមអ្នកផ្ដល់ជំនួយ។

ទិន្នន័យរដ្ឋបាលផ្ដល់នូវព័ត៌មានអំពីសូចនាករសកល ៤.គ.១ ភាគរយគ្រូដែលបានទទួលការបណ្ដុះបណ្ដាល។ ប្រទេសប្រមាណ ៥៨٪ នៅអាហ្វ្រិកសាប់សាហារ៉ា បានរាយការណ៍ទិន្នន័យអំពីការអប់រំកម្រិតបឋមសិក្សាចាប់តាំងពីឆ្នាំ ២០១៦ មក ប៉ុន្តែមានប្រទេសតែ ២៥٪ ប៉ុណ្ណោះដែលរាយការណ៍ពីការអប់រំកម្រិតមធ្យមសិក្សាទុតិយភូមិ។ ក្នុងចំណោមប្រទេសដែលមានប្រជាជនច្រើនជាងគេចំនួន ៦ នៅក្នុងតំបន់នេះ មានតែសាធារណរដ្ឋតង់សានីប៉ុណ្ណោះដែលបានរាយការណ៍ពីចំនួនគ្រូកម្រិតបឋមសិក្សាកាលពីពេលថ្មីៗនេះក្រោយឆ្នាំ ២០១៥។ ការបកស្រាយទិន្នន័យមានការពិបាកដោយសារការខ្វះភាពច្បាស់លាស់នៃនិយមន័យគ្រូដែលបានទទួលការបណ្ដុះបណ្ដាល ជាបញ្ហាប្រឈមដែល UIS នឹងធ្វើការដោះស្រាយ តាមរយៈកំណត់ប្រភេទស្ដង់ដារអន្តរជាតិថ្មីមួយសម្រាប់គ្រូ ដែលនេះជាដំណើរការថ្មីបានទទួលការអនុម័តនៅក្នុងសន្និសីទយូណេស្កូ កាលពីឆ្នាំ ២០១៩។

## ចំណុចដៅ ៤.១. ការអប់រំបឋមសិក្សា និងមធ្យមសិក្សា

អត្រាបញ្ចប់ការសិក្សា គឺ ៨៥٪ សម្រាប់បមសិក្សា, ៧៣٪ សម្រាប់មធ្យមសិក្សាបឋមភូមិ និង ៤៩٪ សម្រាប់មធ្យមសិក្សាទុតិយភូមិ។អត្រាបញ្ចប់ការសិក្សាខុសពីអត្រាចូលរៀនៈអត្រាបញ្ចប់ការសិក្សាមានការកើនឡើងជាបណ្តើរៗបើទោះបីជាក្នុងល្បឿនមួយយឺតក៏ដោយចាប់តាំងពីឆ្នាំ ២០០០ មក, អត្រាចូលរៀននៅទ្រឹងចាប់តាំងពីពាក់កណ្ដាលទសវត្សរ៍ ២០០០ មក។ គេត្រូវធ្វើការស្រាវជ្រាវបន្ថែមទៀតអំពីភាពខុសប្លែកគ្នាបែបនេះ។ នៅក្នុងឆ្នាំ ២០១៨ ប្រទេសនៅអាហ្វ្រិកសាប់សាហារ៉ា មានចំនួនកុមារក្មេងជំទង់ និងយុវវ័យ នៅក្រៅសាលាច្រើនជាងគេ ពោលគឺលើសពីចំនួននៅអាស៊ីកណ្ដាល និងអាស៊ីខាងត្បូង (**តារាងទី១**)។ គេរំពឹងថា និន្នាការនេះនឹងបន្តមានការកើនឡើង។ នៅត្រឹមឆ្នាំ ២០៣០ គេរំពឹងថាចំនួនប្រជាជនដែលដល់វ័យចូលរៀននៅអាហ្វ្រិកសាប់សាហារ៉ា នឹងមានចំនួន ២៥٪ នៃចំនួនប្រជាជនដែលដល់វ័យចូលរៀនសរុបក្នុងពិភពលោក ពោលគឺកើនឡើង ១២٪ ក្នុងឆ្នាំ ១៩៩០។ នៅក្នុងតំបន់នេះក៏មានចំនួនកុមារចូលរៀនលើសអាយុច្រើនជាងគេផងដែរ។

ទិន្ន័យ PISA ឆ្នាំ ២០១៨ រំលេចឱ្យឃើញពីការវិលថយក្រោយបន្តិចនៅក្នុងប្រទេសចំណូលខ្ពស់ក្នុងរយៈពេល ១៥ ឆ្នាំចុងក្រោយនេះ (ក្នុងចំណោមសិស្ស ៥ នាក់ មាន ១ នាក់ដែលរៀនចេះក្រោមកម្រិតស្ទាត់ជំនាញអប្បបរមា)។ ភាពនៅទ្រឹងនៅក្នុងប្រទេសចំណូលមធ្យម (ក្នុងចំណោមសិស្ស ២ នាក់ មាន ១ នាក់ដែលរៀនចេះក្រោមកម្រិតស្ទាត់ជំនាញអប្បបរមា) គួររាប់ថាជាការសម្រេចបាននូវវឌ្ឍនភាព ដោយសារតែការចូលរៀនរបស់កុមារអាយុ ១៥ ឆ្នាំនៅក្នុងប្រទេសជាច្រើន ដូចជា ប្រេស៊ីល ឥណ្ឌូនេស៊ី អ៊ូរ៉ាហ្គាយ មានការកើនឡើង បើទោះបីជាអត្រាវឌ្ឍនភាពនេះឋិតនៅក្រោមកម្រិតដែលចាំបាច់ ដើម្បីសម្រេច គ.អ.ច ទី ៤ ក៏ដោយ។ គួរមានការយកចិត្តទុកដាក់ចំពោះក្រុមដែលនៅផ្នែកខាងក្រោមនៃរបាយលទ្ធផលសិក្សា។ របាយការណ៍នេះបង្ហាញភស្តុតាងថ្មីស្ដីពី "ផលប៉ះពាល់នៃការកំណត់កម្រិតអប្បបរមាទាបពេក (floor effects)" ដែលបង្ហាញថាចំនួនអ្នករៀនសូត្រដែលរៀនចេះពីកម្រិតស្ទាត់ជំនាញអប្បបរមាក្នុងការវាយតម្លៃឆ្លងប្រទេស អាចត្រូវបានគេប៉ាន់ប្រមានលើសពីចំនួនជាក់ស្ដែងនៅក្នុងប្រទេសជាច្រើន ដោយសារតែគេពុំអាចញែកលទ្ធផលសិក្សាពិតប្រាកដ ចេញពីការទាយបែបចៃដន្យ ដោយប្រើប្រាស់សំណួរពហុចម្លើយនោះឡើយ។

**តារាងទី ១៖**
**សូចនាករមួយចំនួនស្ដីពីការចូលរៀន បែងចែកតាមក្រុមអាយុ ឆ្នាំ ២០១៨**

| តំបន់ | បឋមសិក្សា កុមារក្រៅសាលា | | មធ្យមសិក្សាបឋមភូមិ ក្មេងជំទង់ក្រៅសាលា | | មធ្យមសិក្សាទុតិយភូមិ យុវជនក្រៅសាលា | |
|---|---|---|---|---|---|---|
| | (000) | (%) | (000) | (%) | (000) | (%) |
| ពិភពលោក | 59 141 | 8 | 61 478 | 16 | 137 796 | 35 |
| អាហ្វ្រិកសាប់សាហារ៉ា | 32 214 | 19 | 28 251 | 37 | 37 026 | 58 |
| អាហ្វ្រិកខាងជើង/អាស៊ីខាងលិច | 5 032 | 9 | 3 998 | 14 | 8 084 | 30 |
| អាស៊ីកណ្ដាល/ខាងត្បូង | 12 588 | 7 | 16 829 | 15 | 64 745 | 45 |
| អាស៊ីបូព៌ា/អាគ្នេយ៍ | 5 697 | 3 | 9 016 | 10 | 17 870 | 21 |
| អាមេរិកឡាទីន/ការ៉ាបៀន | 2 267 | 4 | 2 544 | 7 | 7 159 | 23 |
| អូសេអានី | 210 | 5 | 109 | 5 | 408 | 25 |
| អឺរ៉ុប/អាមេរិកខាងជើង | 1 133 | 2 | 731 | 2 | 2 503 | 7 |
| ចំណូលទាប | 20 797 | 19 | 21 243 | 39 | 26 176 | 61 |
| ចំណូលមធ្យមកម្រិតខទាប | 30 444 | 9 | 30 706 | 17 | 87 730 | 44 |
| ចំណូលមធ្យមកម្រិតខ្ពស់ | 6 570 | 3 | 8 444 | 7 | 20 615 | 20 |
| ចំណូលខ្ពស់ | 1 330 | 2 | 1 085 | 3 | 3 275 | 8 |

ប្រភព៖ ប្រព័ន្ធទិន្នន័យ UIS ។

## ចំណុចដៅ ៤.២. ការអប់រំកុមារតូច

ការបកស្រាយទិន្នន័យស្ដីពីការចូលរួមក្នុងការអប់រំកុមារតូច អាស្រ័យលើការកំណត់ក្រុមអាយុ ព័ត៌មានដែលប្រមូលអំពីការរៀបចំស្ថាប័នផ្សេងៗគ្នា និងនិន្នាការនៃការធាប់ចូលរៀនតាមប្រទេស។ សម្រាប់កុមារដែលអាយុ ក្រោមអាយុដែលចូលរៀននៅសាលាបឋមសិក្សា ១ ឆ្នាំ ការចូលរួមក្នុងការអប់រំក្នុងប្រព័ន្ធ គឺ ៦៧៎ ក្នុងឆ្នាំ ២០១៨ (សូចនាករសកល ៤.២.២, ភាគរយមានចាប់ពី ៩៎ នៅឌីជីប៊ូទី រហូតដល់ ១០០៎ នៅក្នុងប្រទេសគុយបា និងវៀតណាម)។ មានការសង្កេតឃើញវឌ្ឍនភាពក្នុងសន្ទុះលឿនជាងគេក្នុងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ដែលក្នុងនោះការចូលរៀននៅកម្រិតមត្តេយ្យសិក្សា កើនឡើងពី ៣៨៎ ក្នុងឆ្នាំ ២០១១ ដល់ ៦៧៎ ក្នុងឆ្នាំ ២០១៨។ ក្នុងប្រទេសចំនួន ៩ ក្នុងចំណោមប្រទេសចំនួន ១៧ ដែលមានទិន្នន័យ MICS ថ្មីៗ កុមារនៅក្នុងក្រុមអាយុនេះដែលកំពុងរៀននៅកម្រិតបឋមសិក្សា មានចំនួនច្រើនជាងនៅសាលាមត្តេយ្យ។ សម្រាប់កុមារនៅក្នុងគ្រប់ក្រុមអាយុទាំងអស់ដែលត្រូវរៀននៅកម្រិតមត្តេយ្យ ដែលមានការប្រែប្រួលខុសៗគ្នាពីប្រទេសមួយទៅប្រទេសមួយទៀត ចាប់ពី ១ ឆ្នាំ ទៅ ៤ ឆ្នាំ អត្រានៃការចូលរួមក្នុងការអប់រំកម្រិតនេះគឺ ៥២៎ ក្នុងឆ្នាំ ២០១៨ ដែលភាគរយនេះមានចាប់ពី ១៎ ក្នុងប្រទេសឆាដ រហូតដល់ ១១៥៎ ក្នុងប្រទេសបែលហ្ស៊ិក និងប្រទេសហ្គាណា (**រូបភាពទី ៤**)។

ទិន្នន័យ MICS ត្រូវបានប្រើប្រាស់ ដើម្បីធ្វើការប៉ាន់ប្រមាណពីសន្ទស្សន៍អភិវឌ្ឍន៍កុមារតូច ជារង្វាស់ភាគរយកុមារដែលមានការអភិវឌ្ឍត្រូវតាមគន្លងនៃការអភិវឌ្ឍ (សូចនាករសកល ៤.២.១)។ នៅក្នុងប្រទេសម៉ាលី និងនីហ្សេរីយ៉ា មានកុមារជាង ៦០៎ ដែលត្រូវតាមគន្លងនៃការអភិវឌ្ឍក្នុងផ្នែកយ៉ាងហោចណាស់ចំនួន ៣ ក្នុងចំណោមផ្នែកទាំង ៤។ ប៉ុន្តែភាគរយកុមារដែលមានការអភិវឌ្ឍត្រូវតាមគន្លងនៃការអភិវឌ្ឍក្នុងផ្នែកមិនលើសពី ១ មាន ៥៎ ក្នុងប្រទេសមាលី និង ១០៎ ក្នុងប្រទេសនីហ្សេរីយ៉ា ដែលបង្ហាញថាឱ្យឃើញពីការកើនឡើងនូវវិសមភាពនៅក្នុងប្រទេសនីហ្សេរីយ៉ា។

## ចំណុចដៅ ៤.៣. ការអប់រំបច្ចេកទេស វិជ្ជាជីវៈ ឧត្តមសិក្សា និងការអប់រំសម្រាប់មនុស្សពេញវ័យ

បណ្ដាប្រទេសនៅអាហ្វ្រិកខាងជាង និងអាស៊ីខាងលិច គឺជាប្រទេសដែលមានការកើនឡើងនូវការចូលរួមនៅក្នុងការអប់រំកម្រិតឧត្តមសិក្សាក្នុងសន្ទស្សន៍ឆាប់រហ័សជាងគេ ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ ប៉ុន្តែក៏មានការប្រែប្រួលខុសៗគ្នាច្រើនពីប្រទេសមួយទៅប្រទេសមួយទៀតផងដែរ។ នៅរង្វង់ឆ្នាំ ២០១០ មានយុវជនប្រមាណ ១៥ ភាគរយបានចុះឈ្មោះចូលរៀនក្នុងកម្រិតឧត្តមសិក្សានៅក្នុងប្រទេសម៉ារ៉ុកនិងស៊ូដង់ ប៉ុន្តែភាគរយក្នុងប្រទេសស៊ូដង់បន្តនៅទ្រឹងដោយឡែកប្រទេសម៉ារ៉ុកមានការកើនឡើងយ៉ាងឆាប់រហ័ស រហូតដល់ ៣៦៎។ ប្រទេសអាល់ហ្សេរី និងអារ៉ាប់ប៊ីសាអូឌីត បានពង្រីកការចូលរួមរបស់ស្ត្រីរបស់ស្ត្រីបានរហូតដល់ ២ ភាគ ៣ នៃស្ត្រីវ័យក្មេង។

ការអង្កេតកម្លាំងពលកម្មដែលយកចេញពីប្រព័ន្ធទិន្នន័យរបស់អង្គការអន្តរជាតិខាងការងារ ត្រូវបានបញ្ចូលជាប្រភពទិន្នន័យសម្រាប់ពិនិត្យតាមដានសូចនាករសកល ៤.៣.១ ស្ដីពីការចូលរួមក្នុងការអប់រំ និងការបណ្ដុះបណ្ដាលមនុស្សពេញវ័យដែលនាំឱ្យមានការកើនឡើងនូវការគ្របដណ្ដប់ពី ៤៥ ទៅ ១០៦ ប្រទេស និងទៅកាន់តំបន់ផ្សេងទៀត ក្រៅតែពីអឺរ៉ុប។ បញ្ហាប្រឈមដែលនៅសេសសល់ រួមមានការមិនទាន់មានសំណួរស្តង់ដារអំពីប្រភេទការអប់រំ និងការបណ្ដុះបណ្ដាលមនុស្សពេញវ័យដែលបានចូលរួម រួមនឹងបម្រែបម្រួលក្រុមអាយុ ក៏ដូចជា ការកំណត់រយៈពេលយោងមិនដូចគ្នា៖ ការអង្កេតកម្លាំងពលកម្មជាច្រើនលើកឡើងពីខែចុងក្រោយ ខណៈពេលដែលសូចនាករសកលលើកឡើងពីឆ្នាំចុងក្រោយ។ ភស្តុតាងបង្ហាញឱ្យឃើញពីការចូលរួម

កម្រិតមធ្យមនៅក្នុងខែមុន មុនពេលមានការអង្កេត ដែលធ្វើឡើងនៅក្នុងប្រទេសចំណូលមធ្យមកម្រិតខ្ពស់ គឺត្រឹមតែ ៣% ប៉ុណ្ណោះ (**រូបភាពទី ៥**)។ ការអង្កេតលើការអប់រំមនុស្សពេញវ័យឆ្នាំ ២០១៦ បង្ហាញនូវព័ត៌មានស៊ីជម្រៅអំពីឧបសគ្គដែលធ្វើឱ្យប៉ះពាល់ដល់ការចូលរួមក្នុងការអប់រំប្រភេទនេះ។ ជាទូទៅ មិនសូវមានការស្រាវជ្រាវអំពីឧបសគ្គដែលពាក់ព័ន្ធនឹងឧបនិស្ស័យនោះឡើយ ប៉ុន្តែឧបសគ្គបែបនេះច្រើនតែរារាំងដល់ការរៀនសូត្ររបស់កុមារមនុស្សពេញវ័យ បើធៀបនឹងឧបសគ្គដទៃទៀត៖ អ្នកតបសំណួរ ៦០% បាននិយាយថា ពួកគេមិនឃើញពីភាពចាំបាច់ ដើម្បីចូលរួមក្នុងសកម្មភាពរៀនសូត្ររបស់មនុស្សពេញវ័យនោះឡើយ។ ក្នុងគ្រប់ប្រទេសទាំងអស់ លើកលែងតែប្រទេសដាណឺម៉ាកចេញ ស្ត្រីច្រើនតែលើកឡើងពីភាពប្រទាំងប្រទើសគ្នាជាមួយនឹងការទទួលខុសត្រូវនៅក្នុងគ្រួសារ។

មនុស្សជិត ១១ លាននាក់ដែលកំពុងឋិតនៅក្នុងគ្រឹះស្ថានអនុវត្តន៍ទោសព្រហ្មទណ្ឌ ដែលមានសិទ្ធិទទួលបានការអប់រំ ប៉ុន្តែពុំមានកម្មវិធី ដើម្បីបំពេញតម្រូវការរបស់ពួកគេនោះឡើយ។ ការអប់រំក្នុងពន្ធនាគារ ផ្តល់នូវអត្ថប្រយោជន៍ជាច្រើន៖ ការសិក្សាមួយដែលធ្វើឡើងក្នុងឆ្នាំ ២០១៣ នៅសហរដ្ឋអាមេរិក បានរកឃើញថា ទណ្ឌិតដែលចូលរួមក្នុងសកម្មភាពអប់រំកែប្រែ មានឱកាសប្រព្រឹត្តបទល្មើសឡើងវិញ តិចជាងអ្នកដែលពុំបានទទួលការអប់រំបែបនេះ ១១ ភាគរយចំណុច។

## ចំណុចដៅ ៤.៤៖ ជំនាញសម្រាប់ការងារ

ភាពអាចរកបាននៃទិន្នន័យស្តីពីជំនាញបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) កម្រិតមូលដ្ឋាន កំពុងមានការកើនឡើង បើទោះបីជាទិន្នន័យទាំងនេះមានច្រើននៅតាមប្រទេសដែលមានជីវភាពធូរធាយ៉ាងណាក៏ដោយ។ សូចនាករសកល ៤.៤.១ គ្របដណ្តប់លើជំនាញ ICT កម្រិតមូលដ្ឋានចំនួន ៩, នៅក្នុងប្រទេសតិចជាង ១ ភាគ ៣ នៃប្រទេសទាំងអស់ដែលមនុស្សពេញវ័យ យ៉ាងហោចណាស់ពាក់កណ្តាលមានជំនាញ ICT ចាប់ពី ៤ ឡើងទៅ ហើយពុំមានប្រទេសដែលមានចំណូលទាប ឬចំណូលមធ្យមណា រាយការណ៍ថាមនុស្សពេញវ័យពាក់កណ្តាលមានជំនាញបែបនេះចាប់ពី ៣ ឡើងទៅនោះឡើយ។ នៅឆ្នាំនេះ ប្រទេសនានាត្រូវធ្វើការផ្លាស់ប្តូរបណ្តុំសំណួរនៅក្នុងកម្រង់សំណួរដែលត្រូវបានផ្តល់ជាអនុសាសន៍ ដោយសហព័ន្ធទូរគមនាគមន៍អន្តរជាតិ ឧទាហរណ៍ត្រូវបន្ថែមជំនាញពាក់ព័ន្ធនឹងការរក្សាភាពជាឯកជន និងសន្តិសុខជាដើម។

ការអង្កេតអំពី ICT នៅអឺរ៉ុប ផ្តល់នូវព័ត៌មានស៊ីជម្រៅអំពីការទទួលបានជំនាញឌីជីថល និងសារៈសំខាន់នៃជំនាញទាំងនេះនៅក្នុងសាលារៀនកន្លែងធ្វើការនិងនៅផ្ទះ។បើទោះបីជាជំនាញICTមានភាពពាក់ព័ន្ធជាមួយនឹងការងារយ៉ាងណាក៏ដោយអ្នកតបសំណួរ ១០% បានចូលរួមនៅក្នុងការបណ្តុះបណ្តាល ICT នៅនឹងកន្លែងធ្វើការក្នុងឆ្នាំ ២០១៨ និង ២០% បានចូលរួមក្នុងសកម្មភាពទូទៅយ៉ាងហោចណាស់ចំនួន១ដើម្បីបង្កើនជំនាញកុំព្យូទ័រ សុហ្វវៀរ និងកម្មវិធីរបស់ខ្លួន។ជារឿយៗការអភិវឌ្ឍជំនាញ ICT ច្រើនធ្វើឡើង តាមរយៈការបណ្តុះបណ្តាលអនឡាញដោយផ្តល់ដោយមិនគិតថ្លៃ ឬតាមរយៈស្វ័យសិក្សា ជាពិសេសក្នុងចំណោមមនុស្សវ័យក្មេង។ បើទោះបីជាជម្រើសទាំងនេះជួយដោះស្រាយបញ្ហាប្រឈមដែលពាក់ព័ន្ធនឹងការចំណាយ កាលវិភាគ និងទីតាំងយ៉ាងណាក៏ដោយ ក៏គម្លាតយេនឌ័រនៅតែបន្តមាន។

ចំណុចដៅ ៤.៤ ក៏ផ្តោតលើការអភិវឌ្ឍលើជំនាញសហគ្រិនភាពផងដែរ។ សហគ្រិនជាង ៩០% នៅអាហ្វ្រិក និងរដ្ឋអារ៉ាប់ និងជាង ៨០%នៅអាស៊ី និងប៉ាស៊ីហ្វិក ធ្វើការងារនៅក្នុងវិស័យក្រៅប្រព័ន្ធ។ តម្រូវការបណ្តុះបណ្តាលនៅក្នុងតំបន់ទាំងនេះគួររៀបចំឱ្យត្រូវនឹងតម្រូវការរបស់សហគ្រាសខ្នាតតូចបំផុត ដែលមានសក្តានុពលរីកចម្រើនតិចតួចនៅឡើយ។

**រូបភាពទី ៤៖**

**មានកុមារតិចតួចប៉ុណ្ណោះនៅក្នុងប្រទេសក្រីក្រដែលទទួលបានប្រយោជន៍ពីការអប់រំកម្រិតមត្តេយ្យសិក្សា**

អត្រាសិក្សាសរុបសម្រាប់ការអភិវឌ្ឍកុមារតូច និងការអប់រំមត្តេយ្យសិក្សាបែងចែកតាមក្រុមចំណូល នៃប្រទេស ឆ្នាំ ២០១៨




GEM StatLink: http://bitly/GEM2020_Summary_fig4

ប្រភព៖ ប្រព័ន្ធទិន្នន័យ UIS។

**រូបភាពទី ៥៖**

**ការប៉ាន់ប្រមាណពីការចូលរួមនៅក្នុងការអប់រំមនុស្សពេញវ័យ មានការប្រែប្រួលខុសៗគ្នាទៅតាមរយៈពេលយោង**

ភាគរយនៃមនុស្សពេញវ័យដែលបានចូលរួមក្នុងការអប់រំមនុស្សពេញវ័យក្នុងប្រព័ន្ធ ឬក្រៅប្រព័ន្ធបែងចែកទៅតាមរយៈពេលយោង ឆ្នាំ ២០១៨ ឬឆ្នាំចុងក្រោយបំផុត




GEM StatLink: http://bitly/GEM2020_Summary_fig5

ប្រភព៖ Eurostat និងប្រព័ន្ធទិន្នន័យ UIS។

## ចំណុចដៅ ៤.៥៖ សមធម៌

នៅក្នុងសកលលោកទាំងមូល មានការសម្រេចបាននូវយុគភាពយេនឌ័រក្នុងការសិក្សាចាប់ពីកម្រិតមត្តេយ្យសិក្សា រហូតដល់មធ្យមសិក្សាទុតិយភូមិ។ ទោះជាយ៉ាងណាក៏ដោយ តួលេខនេះលាក់កំបាំងគម្លាតនៅកម្រិតប្រទេស។ នៅក្នុងប្រទេសដែលមានចំណូលទាប ១ ភាគ ៤ ខាងក្រោមគេ ក្នុងចំណោមកុមារា ១០០ នាក់ ដែលសិក្សានៅសាលាមធ្យមសិក្សាទុតិយភូមិ មានកុមារីច្រើនបំផុតត្រឹម ៦០ នាក់ប៉ុណ្ណោះ។ នៅក្នុងប្រទេសដែលមានចំណូលមធ្យមកម្រិតទាប គម្លាតយេនឌ័រអាចជាគម្លាតរបស់កុមារី ឬកុមារា។ រៀងរាល់កុមារា ១០០ ដែលឋិតនៅក្នុងបញ្ចភាគខាងក្រោមគេ មានកុមារី ៩២ នាក់ បើធៀបនឹងតួលេខកុមារា ៩១ នាក់សម្រាប់រៀងរាល់កុមារី ១០០ នាក់ដែលឋិតនៅក្នុងបញ្ចភាគខាងលើគេ។ របាយការណ៍នេះ ពិនិត្យលើភស្តុតាងអំពីប្រវត្តិឡង់ជាសកលនៃសាលារៀនដែលមានសិស្សភេទតែមួយ។

គម្លាតនៃការអប់រំបែងចែកតាមទ្រព្យធន ធ្វើការប្រៀបធៀបគ្រួសារ ២០៕ ក្រោមគេ និងគ្រួសារ ២០៕ លើគេ។ ដោយសារតែគ្រួសារដែលមានជីវភាពក្រីក្រច្រើនតែមានកូនច្រើន ការប្រៀបធៀបឆ្លងប្រទេសធ្វើឡើងមិនបានត្រឹមត្រូវនោះឡើយ ប្រសិនបើការប្រៀបធៀបធ្វើឡើងរវាងកុមារដែលមានជីវភាពក្រីក្រជាងគេ ២០៕ នៅក្នុងប្រទេសមួយ (ឧទាហរណ៍ អាហ្វហ្គានីស្ថាន) ជាមួយនឹងកុមារដែលមានជីវភាពក្រីក្រជាងគេ ២៥៕ នៅក្នុងប្រទេសមួយទៀត (ឧទាហរណ៍ ប្រទេសមីយ៉ាន់ម៉ា)។

ការបន្ថែមសំណុំសំណួរបំពេញអំពីពិការភាពរបស់ក្រុមវ៉ាស៊ីនតោន ទៅក្នុងការអង្កេត MICS ធ្វើឱ្យគេកាន់តែយល់ដឹងអំពីគម្លាតពិការភាពនៅក្នុងវិស័យអប់រំ។ ការប្រើសំណួរខុសៗគ្នា នាំឱ្យមានអត្រាប្រវ៉ាឡង់ពិការភាពខុសៗគ្នារវាងក្រុមអាយុ រហូតដល់អាយុ ១៧ ឆ្នាំ (សំណួរផ្អែកតាមម៉ូឌុលអំពីមុខងាររបស់កុមារ) និងអ្នកដែលមានអាយុចាប់ពី ១៨ ឆ្នាំឡើងទៅ ដែលអត្រាអាចថយចុះ

ប្រមាណ ៩០៎។ ប្រការនេះធ្វើឱ្យប៉ះពាល់ដល់ការបកស្រាយសូចនាករអប់រំ ដែលត្រូវបានគណនាតាមក្រុមអាយុ (ឧទាហរណ៍ ពីអាយុ ១៧ ដល់ ១៩ ឆ្នាំជាដើម)។

បណ្ដាប្រទេសនៅអាមេរិកឡាទីនខ្វះទិន្នន័យដែលអាចឱ្យគេធ្វើការប្រៀបធៀបគ្នាបានអំពីជនជាតិដើមភាគតិច។ខណៈពេលដែលប្រទេសភាគច្រើនប្រើប្រាស់ការកំណត់អត្តសញ្ញាណដោយខ្លួនឯង ប្រទេសមួយចំនួនប្រើប្រាស់លក្ខណវិនិច្ឆ័យបន្ថែមទៀតនៅក្នុងជំរឿន និងការអង្កេត ដូចជាការទទួលស្គាល់អត្តសញ្ញាណ និងភាសាជាផ្លូវការជាដើម។ បម្រែបម្រួលប្រជាសាស្ត្រធ្វើឱ្យព្រំប្រទល់ជាតិពន្ធុមានភាពច្បាស់លាស់ និងនាំឱ្យមានការកើនឡើងនូវអត្តសញ្ញាណជនជាតិដើមភាគតិច ដែលពុំមានភាពច្បាស់លាស់ មានន័យថាការប្រើលក្ខណៈវិនិច្ឆ័យផ្សេង នាំឱ្យមានលទ្ធផលផ្សេង ដូចជា លទ្ធផលពាក់ព័ន្ធនឹងសូចនាករអប់រំជាដើម។ នៅក្នុងការអង្កេតតាមខ្នងផ្ទះដែលធ្វើឡើងនៅក្នុងប្រទេសបូលីវី ហ្គាតេម៉ាឡា ម៉ិកស៊ិក និងប៉េរូ អត្រាចូលរៀនក្នុងចំណោមកុមារអាយុ ១៥ ដល់ ១៧ ឆ្នាំ សម្រាប់អ្នកដែលនិយាយភាសាជនជាតិដើមភាគតិច គឺមានកម្រិតទាបជាងអ្នកដែលកំណត់អត្តសញ្ញាណខ្លួនឯងថាជាជនជាតិភាគតិច ៣ ទៅ ១០ ភាគរយចំណុច។

## ចំណុចដៅ ៤.៦៖ អក្ខរកម្មមនុស្សពេញវ័យ

នៅក្នុងសកលលោកទាំងមូល មនុស្សពេញវ័យ ៨៦ ភាគរយ និងយុវជន ៩២ ភាគរយ ចេះអក្សរ។ ចំនួនស្ត្រីដែលចេះអក្សរនៅតែមានកម្រិតទាបជាង ប៉ុន្តែគម្លាតនេះកាន់តែតូចក្នុងមនុស្សជំនាន់ក្រោយ។ តួលេខទាំងនេះ រាប់បញ្ចូលតាំងការប៉ាន់ប្រមាណថ្មីៗដែលធ្វើឡើងសម្រាប់ប្រទេសចំនួន ៧២ ដែលក្នុងនោះនៅក្នុងប្រទេសចំនួន ២១ អត្រាអក្ខរកម្មថ្នាក់ជាតិកន្លងមក គឺមានតាំងពីឆ្នាំ ២០១០ ឬមុនឆ្នាំ ២០១០ មកម្ល៉េះ។ ចំនួនមនុស្សពេញវ័យដែលពុំបានបញ្ចប់ការអប់រំកម្រិតបឋមសិក្សា នឹងបន្តថយចុះបន្តិចម្ដងៗ និងអាចបន្តនៅលើសពី១០៎នៅអាហ្វ្រិករហូតដល់ឆ្នាំ២០៥០បើទោះបីជាមានការសម្រេចបានការបញ្ចប់ការអប់រំកម្រិតបឋមសិក្សាជាសកលត្រឹមឆ្នាំ២០៣០យ៉ាងណាក៏ដោយដែលនេះមានន័យថាអក្ខរកម្មនុស្សពេញវ័យនៅតែជាបញ្ហាប្រឈម។ក្នុងចំណោមប្រទេស២៥ដែលមានទិន្នន័យពាក់ព័ន្ធអត្រាអក្ខរកម្មមនុស្សពេញវ័យសម្រាប់អ្នកដែលមានពិការភាពណាមួយគឺទាបជាងមនុស្សពេញវ័យដទៃទៀតដែលគម្លាតបែបនេះប្រែប្រួលខុសៗគ្នាពី ៥៎ ក្នុងប្រទេសម៉ាលី រហូតដល់ ៤១៎ ក្នុងប្រទេសឥណ្ឌូនេស៊ី។

លទ្ធផលដែលទទួលបានពីលេកទី៣នៃកម្មវិធីវាយតម្លៃសមត្ថភាពមនុស្សពេញវ័យជាអន្តរជាតិ បានបន្ថែមភស្តុតាងមួយចំនួនសម្រាប់សូចនាករសេកល ៤.៦.១។ មនុស្សពេញវ័យប្រមាណ ៥១៎ ក្នុងប្រទេសម៉ិកស៊ិច ៧១៎ ក្នុងប៉េរូ និង ៧៧៎ ក្នុងប្រទេសអេក្វាឌ័រ មានសមត្ថភាពក្រោមកម្រិតស្ទាត់ជំនាញអប្បបរមាផ្នែកអក្ខរកម្មក្នុងឆ្នាំ ២០១៧។ នៅឯសហរដ្ឋអាមេរិក ភាគរយអ្នកដែលមានចំណេះដឹងលេខនព្វន្តក្រោមកម្រិតស្ទាត់ជំនាញអប្បបរមា កើនឡើងពី ២៧,៦៎ ក្នុងឆ្នាំ ២០១២ - ១៤ ដល់ ២៩៎ ក្នុងឆ្នាំ ២០១៧។

## ចំណុចដៅ ៤.៧៖ ការអភិវឌ្ឍប្រកបដោយចីរភាព និងភាពជាពលរដ្ឋសកល

ការវិភាគលើការឆ្លើយតបចំនួន៨៣នៅក្នុងកិច្ចពិគ្រោះយោបល់លើកទី៦កាលពីឆ្នាំ២០១៦/១៧ស្ដីពីអនុសាសន៍ឆ្នាំ១៩៧៤ ផ្ដល់នូវមូលដ្ឋានសម្រាប់ការពិភាក្សាអំពីសូចនាករសកល ៤.៧.១។ មានប្រទេសតែ ១២៎ ប៉ុណ្ណោះដែលបានឆ្លុះបញ្ចាំងពេញលេញ ឬបញ្ចូលគោលការណ៍ណែនាំនៃអនុសាសន៍នេះទៅក្នុងគោលនយោបាយអប់រំ កម្មវិធីសិក្សា វិក្រឹតការគ្រូ និងការវាយតម្លៃសិស្ស។ ប្រទេសតិចតួចប៉ុណ្ណោះដែលផ្ដល់ការបណ្ដុះបណ្ដាលពេញលេញដល់គ្រូអំពីការអភិវឌ្ឍប្រកបដោយចីរភាព ដែលត្រូវបានកំណត់នៅក្នុងគោល

នយោបាយ និងក្របខ័ណ្ឌកម្មវិធីសិក្សារបស់ខ្លួន និងដែលជាមូលដ្ឋានសម្រាប់ធ្វើការវាយតម្លៃសិស្ស។ នៅក្នុងប្រទេសមួយចំនួន ដូចជា ប៉ូរុនឌី កូឡុំប៊ី និងមីយ៉ាន់ម៉ាជាដើម សិស្សត្រូវបានវាយតម្លៃ បើទោះបីជាគ្រូពុំបានទទួលការបណ្តុះបណ្តាលក៏ដោយ (រូបភាពទី ៦)។ ប្រទេសប្រមាណ ៩៣៪ បង្រៀនពីការទប់ស្កាត់អំពើហិង្សាពាក់ព័ន្ធនឹងយេនឌ័រ ៣៤៪ បង្រៀនពីការទប់ស្កាត់អំពោះហិង្សាជ្រុលនិយម និង ២៩៪ ផ្តល់ការអប់រំអំពីភាពជាពលរដ្ឋសកល។

ខណៈពេលដែលមានភស្តុតាងបង្ហាញថា កម្មវិធីសិក្សាមានការប្រែប្រួលបន្តិចម្តងៗ ដើម្បីបញ្ចូលខ្លឹមសារស្តីពីចីរភាពបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ពុំមានការប្រមូលទិន្នន័យក្នុងលក្ខណៈជាប្រព័ន្ធជាអន្តរជាតិ អំពីរយៈពេលនៃការកែទម្រង់កម្មវិធីសិក្សា "ជាធម្មតា" ចាប់ពីពេលចាប់ផ្តើម រហូតដល់ពេលអនុវត្តន៍នោះឡើយ។ រយៈពេលដែលត្រូវការគឺអាស្រ័យទៅតាមកម្រិតនៃការផ្លាស់ប្តូរ ការពិគ្រោះយោបល់ ការសាកល្បង និងការបញ្ជាក់ផ្ទៀងផ្ទាត់។ ការកែសម្រួលអាចត្រូវការពេលរហូតដល់ ៥ ឆ្នាំ ឬយូរជាងនេះ ប្រសិនបើការកែសម្រួលនេះនាំឱ្យមានភាពចម្រូងចម្រាស់ខាងនយោបាយ ហើយគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនេះត្រូវទទួលបានការយកចិត្តទុកដាក់ឱ្យបានត្រឹមត្រូវ។ ការកែទម្រង់ដែលមានល្បឿនលឿនពេក ច្រើនតែជាការកែទម្រង់ដែលធ្វើបែបបន្ទាន់។ នៅក្នុងប្រទេសរូម៉ានី ក្នុងរយៈពេល ២ ឆ្នាំ មានការដាក់ឱ្យប្រើប្រាស់នូវសៀវភៅសិក្សាស្តីពីប្រវត្តិសាស្ត្រក្រុមជនជាតិភាគតិច ប៉ុន្តែគ្រូពុំបានទទួលការបណ្តុះបណ្តាលនោះឡើយ នៅពេលដែលសៀវភៅទាំងនេះមកដល់ថ្នាក់រៀន។

## ចំណុចដៅ ៤.ក. | សម្ភារូបវន្តដែលបម្រើដល់ការអប់រំ និងបរិយាកាសរៀនសូត្រ

កុមារីប្រមាណ៣៣៥លាននាក់ចូលរៀននៅសាលាបឋមសិក្សានិងមធ្យមសិក្សាដែលខ្វះការគ្រប់គ្រងអនាម័យកម្រិតមូលដ្ឋាន សម្រាប់ពេលមករដូវ។ សម្ភារូបវន្តអនាម័យអាចមិនផ្តល់ភាពងាយស្រួលសម្រាប់អ្នកដែលប្រើរទេះរុញនោះឡើយ។ នៅក្នុងប្រទេស អែលសាវ៉ាឌ័រ ហ្វីជី ប៉េរូ តាហ្ស៊ីគីស្ថាន និងយេមេន សាលារៀនយ៉ាងហោចណាស់ ៨០៪ មានសម្ភារូបវន្តអនាម័យដែលត្រូវបានកែលម្អ ប៉ុន្តែមានក្រោម ៥៪ ប៉ុណ្ណោះដែលអ្នកមានពិការភាពអាចប្រើប្រាស់បាន។

នៅក្នុងប្រទេសចំនួន ២៩ សីតុណ្ហភាពពិបាកទ្រាំ បង្កផលប៉ះពាល់អវិជ្ជមានដល់ការសម្រេចលទ្ធផលនៃការអប់រំ។ នៅអាស៊ីភាគអាគ្នេយ៍ កុមារដែលឋិតនៅក្នុងបរិយាកាសដែលមានសីតុណ្ហភាពខ្ពស់ជាងសីតុណ្ហភាពមធ្យមចំនួន ២ គម្លាតស្តង់ដារ (standard deviation) ត្រូវបានព្យាករណ៍ថា រៀនតិចជាងកុមារដែលរៀននៅក្នុងបរិយាកាសដែលមានសីតុណ្ហភាពមធ្យម ១,៥ ឆ្នាំ ។

គិតត្រឹមខែកុម្ភៈ ឆ្នាំ ២០២០ មានហត្ថលេខីចំនួន ១០២ លើសេចក្តីប្រកាសស្តីពីសាលារៀនដែលមានសុវត្ថិភាពឆ្នាំ ២០១៥។ ទោះជាយ៉ាងណាក៏ដោយ សាលារៀនជាង ១.០០០ កន្លែងនៅក្នុងអាហ្វហ្កានីស្ថានត្រូវបិទទ្វារ ដោយសារជម្លោះកាលពីចុងឆ្នាំ ២០១៨ ដែលធ្វើឱ្យកុមារកន្លះលាននាក់នៅក្រៅសាលា។ នៅ ប៊ូគីណា ហ្វាសូ ម៉ាលី និងនីហ្សេរីយ៉ា ចំនួនសាលារៀនដែលត្រូវបានបិទទ្វារកើនឡើង ២ ដង ចន្លោះពីឆ្នាំ ២០១៧ ដល់ឆ្នាំ ២០១៩ ដោយសារការកើនឡើងនូវបញ្ហាអសន្តិសុខ ដែលបង្កការរំខានដល់ការអប់រំកុមារជាង ៤០០.០០០ នាក់។

ខណៈពេលដែលប្រទេសចំនួន ១៣២ បានដាក់បម្រាមមិនឱ្យមានការដាក់ទណ្ឌកម្មលើរាងកាយនៅតាមសាលារៀន កុមារដែលដល់អាយុចូលរៀនពាក់កណ្តាល រស់នៅក្នុងប្រទេសដែលពុំមានការហាមឃាត់ឱ្យបានពេញលេញលើការដាក់ទណ្ឌកម្មបែបនេះ។ ការជំទាស់ទៅនឹងការដាក់ទណ្ឌកម្មលើរាងកាយនៅផ្ទះ មានទំនាក់ទំនងជាវិជ្ជមានជាមួយនឹងការថយចុះនូវកម្រិតនៃការដាក់ទណ្ឌកម្មលើរាងកាយក្នុងសាលារៀន។ ក្នុងប្រទេសឥណ្ឌា និងសាធារណរដ្ឋកូរ៉េ ការដាក់ទណ្ឌកម្មលើរាងកាយក្នុងសាលារៀនមានកម្រិតខ្ពស់ជាងកម្រិតដែលគេអាចព្យាករណ៍ដឹងបាន។

ក្នុងចំណោមមនុស្ស ១០០.០០០ នាក់នៅក្នុងប្រទេសដែលមានចំណូលទាប មានការបាត់បង់ជីវិតកុមារអាយុពី ៥ ទៅ ១៤ ឆ្នាំ ៦,២ នាក់ ដែលនៅតាមប្រទេសទាំងនេះ ជាមធ្យមក្នុងចំណោមប្រជាពលរដ្ឋ១.០០០នាក់មានយានជំនិះចំនួន៨គ្រឿង ធៀបនឹងអត្រាបាត់បង់ជីវិត ១,៧ នាក់នៅក្នុងប្រទេសដែលមានចំណូលខ្ពស់ដែលជាមធ្យមក្នុងចំណោមប្រជាពលរដ្ឋ១.០០០នាក់មានយានជំនិះ៥២៨គ្រឿង។ការអង្កេតលើផ្លូវដែលមានប្រវែងជិត ២៥០.០០០ គីឡូម៉ែត្រក្នុងប្រទេសចំនួន ៦០ បានរកឃើញថា ចម្ងាយផ្លូវជាង ៨០៉ ដែលមានលំហូរចរាចរណ៍ក្នុងល្បឿន ៤០ គីឡូម៉ែត្រក្នុងមួយម៉ោង និងដែលប្រើប្រាស់ដោយថ្មើរជើង គឺជាផ្លូវដែលពុំក្រាលកៅស៊ូ។

## ចំណុចដៅ ៤.ខ. | អាហារូបករណ៍

ទឹកប្រាក់ជំនួយសម្រាប់អាហារូបករណ៍ និងចំណាយចាត់ចែងផ្តល់អាហារូបករណ៍ដល់សិស្ស សរុបមានចំនួន ៣,៦ ពាន់លានដុល្លារ ក្នុងឆ្នាំ ២០១៧។ ទឹកប្រាក់ជំនួយអាហារូបត្ថម្ភគិតជាមធ្យមសម្រាប់សិស្សដែលរៀននៅឧត្តមសិក្សា ១ នាក់ មានការប្រែប្រួលខុសគ្នាឆ្ងាយ៖ ប្រទេសដែលសិស្សក្នុងចំនួនប្រាក់ប្រហែលគ្នានេះ ប្រែប្រួលជាមួយនឹងមេគុណចាប់ពី ១០០ ឡើងទៅ។លំហូរអាហារូបករណ៍ក្នុងប្រជាជន១នាក់ក្នុងកម្រិតខ្ពស់ជាងគេ គឺបានទៅរដ្ឋកំពុងអភិវឌ្ឍដែលឋិតនៅតាមដែនកោះតូចៗដែលអាចឱ្យពលរដ្ឋរបស់ពួកគេ អាចបន្តការសិក្សាជំនាញបច្ចេកទេសនៅក្រៅប្រទេសបាន។ ក្នុងចំណោមប្រទេសទាំងនេះ កោះការ៉ាបៀនទទួលបាននូវជំនួយ អាហារូបករណ៍គិតក្នុងប្រជាជន ១ នាក់តិចឆ្ងាយជាងកោះប៉ាស៊ីហ្វិក។

ការស្រាវជ្រាវដែលធ្វើឡើងសម្រាប់របាយការណ៍នេះប៉ាន់ប្រមាណថា មានការផ្តល់អាហារូបករណ៍ចំនួន ៣០.០០០ កន្លែង ដល់សិស្សមកពីអាហ្វ្រិកសាប់សាហារ៉ា ក្នុងឆ្នាំ ២០១៩ ដោយអ្នកផ្តល់អាហារូបករណ៍ធំជាងគេចំនួន ៥០ ដែលធ្វើការបែងចែកអាហារូបករណ៍ប្រមាណ៩៥៉នៃចំនួនអាហារូបករណ៍សរុបសម្រាប់សិស្សនៅទូទាំងសកលលោក នេះបើតាមបញ្ជីវិភាគលើអ្នកផ្តល់អាហារូបករណ៍ជាង ២០០។ អាហារូបករណ៍ប្រមាណ ៥៦៉ ត្រូវបានផ្តល់សម្រាប់ការសិក្សាកម្រិតបរិញ្ញាបត្រ។

**រូបភាពទី ៦៖**

**នៅក្នុងប្រទេសមួយចំនួន សិស្សត្រូវបានវាយតម្លៃ ប៉ុន្តែគ្រូពុំបានទទួលការបណ្តុះបណ្តាលអំពីការអប់រំ ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាពនោះឡើយ**

កម្រិតនៃការអនុវត្តអនុសាសន៍ ១៩៧៤ បែងចែកទៅតាមផ្នែក និងនិទ្នាការ ២០១៦/១៧




GEM StatLink: http://bitly/GEM2020_Summary_fig6

កំណត់សម្គាល់៖ រូបភាពនេះមិនបង្ហាញប្រទេសដែលមាននិន្នាការឆ្លើយតបពិសេសខុសពីគេនោះឡើយ។

ប្រភព៖ UNESCO (2019).

ការផ្តល់អាហារូបករណ៍ដល់សិស្សនៅអាហ្វ្រិកសាប់សាហារ៉ា ភាគច្រើនធ្វើឡើងដោយគំនិតផ្តួចផ្តើមដឹកនាំដោយរដ្ឋាភិបាល ដោយប្រទេសចិនជាអ្នកផ្តល់អាហារូបករណ៍ធំជាងគេតែមួយគត់ ដែលផ្តល់ឱកាសអាហារូបករណ៍ជាង ១២.០០០ កន្លែងក្នុងមួយឆ្នាំ។ បើទោះបីជាទំហំជំនួយអាហារូបករណ៍នៅទូទាំងសកលលោកនៅទ្រឹងចាប់តាំងពីឆ្នាំ ២០១០ យ៉ាងណាក៏ដោយ ចំនួនឱកាសដែលមានសម្រាប់សិស្សមកពីតំបន់អាហ្វ្រិកសាប់សាហារ៉ា មានការកើនឡើងចាប់តាំងពីឆ្នាំ ២០១៥ មក ហើយទំនងជានឹងបន្តកើនឡើងនៅក្នុងរយៈពេល ៥ ឆ្នាំទៀត។

ជារឿយៗ អ្នកផ្តល់អាហារូបករណ៍ ពុំមានរង្វាស់ដែលអាចព្យាករណ៍បានអំពីសមិទ្ធកម្មកម្មវិធី ដូចជា បរិយាបន្នជាដើមនោះឡើយ។ ក្នុងចំណោមអ្នកផ្តល់អាហារូបករណ៍ចំនួន ២០ ដែលត្រូវបានពិគ្រោះយោបល់ជាមួយសម្រាប់របាយការណ៍នេះ ភាគច្រើនពុំអាចផ្តល់ព័ត៌មានលម្អិតអំពីសាវតាររបស់អ្នកទទួលអាហារូបករណ៍ម្នាក់ៗនោះឡើយ ក្រៅតែពីយេនឌ័ររបស់ពួកគេ។ នីតិវិធីដាក់ពាក្យសុំ និងជ្រើសរើស ពុំត្រូវបានបន្សុីឱ្យស្របជាមួយនឹងតម្រូវការរបស់និស្សិត ៦០៪ ក្នុងចំណោមនិស្សិតមកពីតំបន់អាហ្វ្រិកសាប់សាហារ៉ា ដែលកំពុងសិក្សានៅខាងក្រៅតំបន់នេះឡើយ ដែលពួកគេកំពុងបន្តការសិក្សានៅក្នុងបរិយាកាសខុសស្រឡះពីបរិយាកាសដែលពួកគេធ្លាប់សិក្សាកន្លងមក។

## ចំណុចដៅ ៤.គ. គ្រូបង្រៀន

ក្នុងសកលលោកទាំងមូល គ្រូបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិប្រមាណ ៨៥៪ បានទទួលការបណ្តុះបណ្តាលទៅតាមនិយមន័យរបស់ជាតិ។ នៅតំបន់អាហ្វ្រិកសាប់សាហារ៉ា ភាគរយនេះមាន ៦៤៪ សម្រាប់បឋមសិក្សា និង ៥៨៪ សម្រាប់មធ្យមសិក្សាបឋមភូមិ។ គ្រូមត្តេយ្យសិក្សាក្រោមពាក់កណ្តាល (៤៩៪) នៅក្នុងតំបន់នេះបានទទួលការបណ្តុះបណ្តាល ហើយភាគរយសម្រាប់មធ្យមសិក្សាទុតិយភូមិគឺ ៤៣៪។ ការបកស្រាយទិន្នន័យអំពីចំនួនគ្រូដែលមាន មួយផ្នែកពឹងអាស្រ័យលើព័ត៌មានអំពីជំនួយការគ្រូ។ ទិន្នន័យសម្រាប់ប្រទេសដែលមានចំណូលទាប និងចំណូលមធ្យម កម្របញ្ជាក់ឱ្យច្បាស់ថាតើបុគ្គលិកគាំទ្រទាំងនេះក៏ចូលរួមនៅក្នុងការបង្រៀនដែរឬអត់នោះឡើយ។ ទិន្នន័យសម្រាប់ប្រទេស OECD បង្ហាញបានច្បាស់លាស់ជាង និងបង្ហាញពីប្រទេសនានា ដូចជាប្រទេសឈីលី និងចក្រភពអង់គ្លេស ដែលពឹងអាស្រ័យច្រើនលើជំនួយការបង្រៀនក្នុងការអប់រំកម្រិតមត្តេយ្យសិក្សា។ ការវិភាគលើចំនួនម៉ោងធ្វើការបង្ហាញថា គេមិនដឹងឱ្យបានគ្រប់គ្រាន់អំពីការបែងចែកពេលវេលាសម្រាប់គ្រូនោះឡើយ។ យ៉ាងហោចណាស់នៅក្នុងករណីមួយចំនួនតូច បញ្ញត្តិច្បាប់ដែលកំណត់ពីចំនួនម៉ោងធ្វើការ និងចំនួនម៉ោងបង្រៀន អាចពុំឆ្លុះបញ្ចាំងពីតថភាពជាក់ស្តែងនោះឡើយ។

ការវាយតម្លៃដែល OECD ធ្វើឡើងលើប្រទេសចំនួន ៩ បានបញ្ជាក់ថា គ្រូមត្តេយ្យសិក្សាអាចមានសមត្ថភាពខ្ពស់ ប៉ុន្តែពួកគេពុំបានទទួលការបណ្តុះបណ្តាលដែលចាំបាច់អំពីរបៀបធ្វើការងារជាមួយកុមារនោះឡើយ។ ភាគរយនៃគ្រូមត្តេយ្យសិក្សាដែលពុំបានទទួលការបណ្តុះបណ្តាលបែបនេះ គឺមាន ៦៤៪ នៅក្នុងប្រទេសអ៊ីស្លង់។ បើទោះបីជាមានការពេញចិត្តតិចតួចជាមួយនឹងប្រាក់បៀវត្ស យ៉ាងណាក៏ដោយ បុគ្គលិកបានរាយការណ៍ពីការពេញចិត្តខ្ពស់ជាមួយនឹងការងារ ចាប់ពី ៧៩៪ នៅសាធារណរដ្ឋកូរ៉េ រហូតដល់ ៩៨៪ នៅអ៊ីស្រាអែល។

# ការអប់រំក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពផ្សេងទៀត

គោលដៅសមភាពយេនឌ័រការប្រែប្រួលអាកាសធាតុនិងភាពជាដៃគូអាចផ្តួបកម្លាំងគ្នាក្នុងកម្រិតមួយខ្ពស់ជាមួយនឹងគោលដៅអប់រំ ដើម្បីសម្រេចសមិទ្ធផលឱ្យកាន់តែធំថែមទៀត ដែលនេះជាអ្វីដែលមិនទាន់សម្រេចបាននៅឡើយ។ ការវាយតម្លៃលើមធ្យោបាយដែលមានប្រសិទ្ធភាព ដើម្បីប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ ចាត់ទុកការអប់រំក្មេងស្រី និងស្ត្រី ថាជាដំណោះស្រាយទី ៦ និងផែនការគ្រួសារជាដំណោះស្រាយទី ៧ ក្នុងចំណោមដំណោះស្រាយចំនួន ៨០។ ការវាយតម្លៃនេះប៉ាន់ប្រមាណថា ការបំពេញគម្លាតហិរញ្ញប្បទានដែលត្រូវបានប៉ាន់ប្រមាណនៅក្នុងរបាយការណ៍ GEM នេះដែលមានចំនួន ៣៩ ពាន់លានដុល្លារក្នុងមួយឆ្នាំ អាចនាំឱ្យមានការកាត់បន្ថយការបញ្ចេញឧស្ម័ន ៥១ ជីកាតោន (gigaton) ត្រឹមឆ្នាំ ២០៥០ ជាផល "ដែលបានលើសលុបមិនអាចគណនាបាន" ពីការវិនិយោគទាំងនេះ។ជនជាតិដើមភាគតិចនិងសហគមន៍មូលដ្ឋានគ្រប់គ្រងកាបោនយ៉ាងហោចណាស់ ១៧% ក្នុងចំណោមកាបោនសរុបដែលត្រូវបានស្តុកទុកក្នុងដីព្រៃនៅក្នុងប្រទេសតំបន់ត្រូពិក និងត្រូពិករងចំនួន ៥២ មានន័យថាការការពារចំណេះដឹងរបស់ពួកគេ គឺជារឿងសំខាន់។ គិតត្រឹមឆ្នាំ ២០១៧ ក្នុងចំណោមរដ្ឋជាសមាជិកយូណេស្កូចំនួន ១៩៥ មាន ១០២ បានតែងតាំងជនបង្គោលទទួលបន្ទុកការអប់រំសម្រាប់សកម្មភាពផ្តល់ភាពអង់អាចផ្នែកអាកាសធាតុ ក្នុងគោលបំណងគាំទ្រដល់ការផ្តល់ការអប់រំអំពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

ខណៈពេលដែលយេនឌ័រគឺជាអាទិភាពអន្តរវិស័យនៅក្នុងគ្រប់មូលនិធិភាពជាដៃគូ ដែលមានការចូលរួមពីតួអង្គពាក់ព័ន្ធចម្រុះ ការភ្ជាប់ទំនាក់ទំនងរវាងការអប់រំ និងការប្រែប្រួលអាកាសធាតុ នៅមានកម្រិតខ្សោយនៅឡើយ។ ពុំមានការកំណត់ចំណុចដៅឱ្យបានច្បាស់ពីហិរញ្ញប្បទានអាកាសធាតុសកលក្នុងឆ្នាំ២០១៥-១៦ សម្រាប់ពង្រីកប្រព័ន្ធអប់រំនិងការអប់រំក្មេងស្រីការផ្លាស់ប្តូរឥរិយាបថជុំវិញសំណល់អាហារ និងរបបអាហារ និងវិធីសាស្រ្តប្រើប្រាស់ដី និងគ្រប់គ្រងដីរបស់ជនជាតិដើមភាគតិចនោះឡើយ។

# ហិរញ្ញប្បទាន

នៅក្នុងសកលលោកទាំងមូល មេដ្យានចំណាយសាធារណៈលើវិស័យអប់រំ គឺ ៤,៤% នៃ ផ.ស.ស និង ១៣,៨% ភាគរយនៃចំណាយសរុបរបស់រដ្ឋាភិបាលក្នុងឆ្នាំ ២០១៨ បើធៀបនឹងកម្រិត ៤% នៃ ផ.ស.ស និង ១៥% នៃចំណាយសរុបរបស់រដ្ឋាភិបាល ដូចដែលបានឯកភាពគ្នានៅក្នុងក្របខណ្ឌសកម្មភាពសម្រាប់ការអប់រំឆ្នាំ ២០៣០។ ក្នុងចំណោមប្រទេស ១៤១ ដែលមានទិន្នន័យ ប្រទេសចំនួន ៤៧ ឬ ១ ភាគ ៣ ពុំបានបំពេញតាមចំណុចដៅនេះឡើយ ដែលកើនឡើង ៤ ប្រទេស បើធៀបនឹងឆ្នាំមុន ហើយចំនួនប្រទេសដែលបានរាយការណ៍ មានតិចជាងមុនចំនួន ៧ ប្រទេស។ ដោយសារតែចំនួនប្រទេសដែលរាយការណ៍ពីទិន្នន័យចំណាយមានការប្រែប្រួលជារៀងរាល់ឆ្នាំ ការវិភាគកាលវេលាដែលមានភាពស៊ីសង្វាក់គ្នា តម្រូវឱ្យមានការប្រើប្រាស់វិធីសាស្ត្រមធ្យមភាគ។ ពីឆ្នាំ ២០០០ដល់២០១៨ចំណាយលើវិស័យអប់រំនៅទ្រឹងបើគិតជាភាគរយនៃផ.ស.សបើទោះជាលទ្ធផលនេះគ្របដណ្ដប់លើការប្រែប្រួលខុសៗគ្នានៅក្នុងតំបន់ចាប់ពីខ្ពស់ជាង ១,៧ ភាគរយចំណុចនៅអាមេរិកឡាទីន និងការ៉ាបៀន ដល់ទាបជាង ០,៥ ភាគរយចំណុចនៅអាហ្វ្រិកខាងជើង និងអាស៊ីខាងលិច យ៉ាងណាក៏ដោយ។

ចំណាយលើការផ្តល់ជំនួយដល់វិស័យអប់រំ មានចំនួន ១៣,៥ ពាន់លានដុល្លារក្នុងឆ្នាំ ២០១៧ ជាតួលេខមួយនៅទ្រឹងសម្រាប់ឆ្នាំទី ៨។ ការផ្តល់ជំនួយដល់ប្រទេសដែលមានចំណូលទាប កើនឡើងដល់ ២,៩ ពាន់លានដុល្លារ ប៉ុន្តែនៅទាបជាងកម្រិតឆ្នាំ ២០០៩ ចំនួន ១០%។ និន្នាការដែលគួរឱ្យកត់សម្គាល់មួយទៀត គឺ ១ ភាគ ៥ នៃថវិកាជំនួយសម្រាប់ការអប់រំនៅកម្រិតមូលដ្ឋាន ឬជាង ១ ពាន់លានដុល្លារនៅក្នុងឆ្នាំ ២០១៧ ត្រូវបានផ្តល់តាមរយៈវេទិកាផ្តល់មូលនិធិពហុភាគី ដូចជា ភាពជាដៃគូសកលសម្រាប់ការអប់រំជាដើម ខណៈពេលដែលភាគរយនៃថវិកាជំនួយសម្រាប់ការអប់រំកម្រិតមូលដ្ឋាន ដែលផ្តល់ដោយផ្ទាល់ទៅប្រទេសដែលមានចំណូលទាបមានការថយចុះ។ ថវិកាជំនួយមនុស្សធម៌សម្រាប់វិស័យអប់រំកើនឡើងទ្វេដង ចន្លោះពីឆ្នាំ ២០១៥ និង ២០១៨ រហូតដល់ ៥៦៨ លានដុល្លារ។

អង្គការ OECD កំពុងផ្លាស់ប្តូរនិយមន័យ និងវិធីសាស្ត្រសម្រាប់ធ្វើការគណនាទឹកប្រាក់ជំនួយ។ កម្មវិធីផ្តល់ការគាំទ្រជាផ្លូវការទាំងស្រុងដល់ការអភិវឌ្ឍប្រកបចីរភាព ដែលជាកម្មវិធីថ្មី ត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់ ជាច្រើនដល់វិស័យអប់រំ ។ លេខកូដថ្មីសម្រាប់យន្តការពហុភាគី ដូចជាភាពជាដៃគូសកលសម្រាប់ការអប់រំជាដើម នឹងធ្វើឱ្យភាគរយនៃថវិកាជំនួយសម្រាប់ការអប់រំដែលកន្លងមកពុំត្រូវបានវិភាជ សម្រាប់ប្រទេសនានានោះ នឹងមានការថយចុះ។ នឹងមានការផ្តល់ព័ត៌មាននៅកម្រិតវិស័យសម្រាប់ជំនួយមនុស្សធម៌។

ការរួមចំណែកដល់ទំនិញសាធារណៈសកល និងសេវាប្រឹក្សាគោលនយោបាយ ព្រមទាំងការងារស្រាវជ្រាវ ក៏នឹងត្រូវដកចេញផងដែរ។ មានតែភាគរយនៃឥណទានកម្ចីសម្បទានតែប៉ុណ្ណោះដែលនឹងរាប់បញ្ចូលជាទឹកប្រាក់ជំនួយ។

នៅពេលប្រទេសកាន់តែក្រ ភាគរយចំណាយរបស់គ្រួសារលើការអប់រំកាន់តែមានការកើនឡើង។ ទិន្នន័យដែលបានពីប្រទេសមួយចំនួនតូចបង្ហាញថា មេដ្យាននៃចំណាយនេះគឺ ០,៥% នៃ ផ.ស.ស នៅអឺរ៉ុប និងអាមេរិកខាងជើង ប៉ុន្តែ ១,៩% នៅអាហ្វ្រិកសាប់សាហារ៉ា។ ជារឿយៗ ចំណាយតាមគ្រួសារ គឺដើម្បីបង្គ្រប់ទឹកប្រាក់ចំណាយមិនគ្រប់គ្រាន់របស់រដ្ឋាភិបាល។ នៅក្នុងប្រទេសចំនួន ៦ ក្នុងចំណោមប្រទេសចំនួន ៩ ដែលគ្រួសារចំណាយយ៉ាងហោចណាស់ ២,៥% នៃ ផ.ស.ស លើការអប់រំ រដ្ឋាភិបាលចំណាយក្រោម ៤%។ គ្រួសារអាចបង្ហាញពីភាពលម្អៀងខាងយេនឌ័រ នៅពេលចំណាយប្រាក់នៅលើការអប់រំ ដោយលម្អៀងលើកូនប្រុស និងកូនស្រី បើទោះបីជាវិសាលភាពអាចមានការប្រែប្រួលខុសៗគ្នាទៅតាមបរិបទយ៉ាងណាក៏ដោយ។

**រូបភាពទី ៧៖**

**តំបន់អាមេរិកឡាទីន និងការ៉ាប៉ៀន មានការកើនឡើងនូវចំណាយលើវិស័យអប់រំខ្ពស់ជាងគេ**

ចំណាយលើការអប់រំសាធារណៈ គិតជាភាគរយនៃ ផ.ស.ស ២០០-១៨




GEM StatLink: http://bitly/GEM2020_Summary_fig7

ប្រភព៖ ការវិភាគធ្វើឡើងដោយក្រុមរៀបចំរបាយការណ៍ GEM ផ្អែកតាមប្រព័ន្ធទិន្នន័យ UIS។

# របាយការណ៍ពិនិត្យតាមដានការអប់រំសកល

ឆ្នាំ ២០២០ នេះ ពិនិត្យលើយន្តការសង្គម សេដ្ឋកិច្ច និងវប្បធម៌ ដែលរើសអើងចំពោះកុមារ យុវជន និងមនុស្សពេញវ័យដែលងាយរងគ្រោះ ធ្វើឱ្យពួកគេនៅក្រៅការអប់រំឬធ្វើឱ្យពួកគេមានឱកាសតិចតួចដើម្បីទទួលបានសេវាអប់រំ។ ជំរុញដោយការប្តេជ្ញាចិត្ត ដើម្បីសម្រេចឱ្យបាននូវសិទ្ធិទទួលបានការអប់រំបរិយាបន្ន ប្រទេសនានា កំពុងពង្រីកចក្ខុវិស័យបរិយាបន្នក្នុងការអប់រំរបស់ខ្លួន ដោយចាត់ទុកភាពចម្រុះថាជាចំណុចផ្តោតដ៏សំខាន់នៅក្នុងប្រព័ន្ធរបស់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ ការអនុវត្តច្បាប់ និងគោលនយោបាយដែលមានបំណងល្អ ជារឿយៗងាកចេញពីគោលបំណងទាំងនេះ។ របាយការណ៍ដែលផ្សព្វផ្សាយនៅពេលចាប់ផ្តើមទសវត្សរ៍សកម្មភាពឈានទៅឆ្នាំ ២០៣០ នេះ របាយការណ៍នេះលើកឡើងថា ការមិនឆ្លើយតបចំពោះតម្រូវការរបស់អ្នករៀនសូត្រម្នាក់ៗ គឺជាការគំរាមកំហែងពិតប្រាកដដល់ការសម្រេចចំណុចដៅអប់រំជាសកល។

បរិយាបន្ន និងការអប់រំ៖ ទាំងអស់គ្នា មានន័យថា យើងទាំងអស់គ្នា បង្ហាញពីការអនុវត្តក្នុងវិស័យអភិបាលកិច្ច និងហិរញ្ញវត្ថុ, កម្មវិធីសិក្សា សៀវភៅសិក្សា និងការវាយតម្លៃ, ការអប់រំគ្រូ, ហេដ្ឋរចនាសម្ព័ន្ធសាលារៀន, និងទំនាក់ទំនងជាមួយសិស្ស ឪពុកម្តាយ និងសហគមន៍ ដែលអាចបង្ហាញឱ្យពីដំណើរការដែលត្រូវអនុវត្ត ដើម្បីសម្រេចបរិយាបន្ន។ របាយការណ៍នេះផ្តល់អនុសាសន៍គោលនយោបាយដើម្បីធ្វើឱ្យភាពចម្រុះរបស់អ្នករៀនសូត្រក្លាយជាចំណុចខ្លាំង ដើម្បីត្រូវអបអរសាទរ និងជាកម្លាំងដើម្បីជំរុញឱ្យមានភាពចុះសម្រុងគ្នានៅក្នុងសង្គម។

គេហទំព័រថ្មីចំនួន ២ បំពេញបន្ថែមលើកំណែទី ៤ នៃរបាយការណ៍ពិនិត្យតាមដានការអប់រំសកល។ Education Profiles រៀបរាប់ពីរបៀបដែលប្រទេសនានាឆ្លើយតបចំពោះបរិយាបន្ន និងមានតួនាទីជាធនធានសម្រាប់បម្រើដល់កិច្ចពិគ្រោះយោបល់កម្រិតគោលនោបាយ។ Education Progress ផ្តល់ឱកាសឱ្យគេអាចធ្វើអន្តរកម្មជាមួយទិន្នន័យ និងស្វែងយល់បន្ថែមទៀតអំពីសូចនាករមួយចំនួននៃ គ.អ.ចទី ៤។

---

បរិយាបន្នដែលដាក់ឱ្យអនុវត្តពីខាងលើទៅ នឹងមិនមានប្រសិទ្ធភាពនោះឡើយ ដូច្នេះសំណួរដែលរបាយការណ៍GEMឆ្នាំ២០២០សួរទៅអ្នកទាំងអស់គ្នាដែលជាអ្នកអាន គឺថាតើអ្នកបានត្រៀមខ្លួនដើម្បីតតាំងនឹងផ្នត់គំនិតបច្ចុប្បន្ននេះ និងត្រៀមខ្លួនដើម្បីធ្វើការសម្រេចចិត្តថាការអប់រំគឺសម្រាប់ទាំងអស់គ្នា – ទាំងអស់គ្នា មានន័យថាទាំងអស់គ្នាដែរឬទេ។

**លោកជំទាវ** Helen Clark
**ប្រធានគណៈកម្មាធិការប្រឹក្សារបាយការណ៍** GEM

ការបោះជំហានទៅរកបរិយាបន្ន គឺជាអ្វីដែលត្រូវធ្វើឱ្យខានតែបាន។ ការប្រងើយកន្តើយចំពោះបរិយាបន្ន គឺផ្ទុយទៅនឹងមូលហេតុដែលជំរុញឱ្យគ្រប់គ្នាខិតខំកសាងពិភពលោកមួយដែលកាន់តែមានលក្ខណៈល្អប្រសើរជាងមុន។ យើងអាចមិនសម្រេចបានពេញលេញនោះឡើយ ប៉ុន្តែការខកខានមិនធ្វើសកម្មភាព មិនមែនជាជម្រើសនោះឡើយ។

**អូដ្រេ អាហ្សូឡាយ** (Audrey Azoulay)
**អគ្គនាយកយូណេស្កូ**

*ប្រសិនបើយើងមិនជំរុញឱ្យមានការបង្កភាពងាយស្រួល និងបរិយាបន្នក្នុងសាលារៀននោះទេ យើងកំពុងធ្វើឱ្យមនុស្សគ្រប់ជំនាន់ទាំងអស់ជឿថា ការបែងចែកមនុស្សជាប្រភេទ គឺជាដំណោះស្រាយដែលមានប្រសិទ្ធភាពចំពោះ "បញ្ហា" នៃអត្ថិភាពរបស់មនុស្សដែលមានលក្ខណៈខុសៗគ្នា។*

***អារីយ៉ាណា អាប៊ូឡាហ្វៀ*** *(Ariana Aboulafia)*
***និស្សិតសាលាច្បាប់នៃសាកលវិទ្យាល័យ*** *Miami*
***សហរដ្ឋអាមេរិក***

*ជំហានសំខាន់ជាងគេ ដែលជួយឱ្យខ្ញុំមានអារម្មណ៍ថាបានចូលរួមនៅក្នុងសាលារៀន គឺដាក់ខ្ញុំនៅក្នុងបរិយាកាសរៀនសូត្រដូចគ្នានិងមិត្តរួមការងារដែលមានសមត្ថភាពជាងខ្ញុំ។ខ្ញុំទទួលបានការស្វាគមន៍ដូចអ្នកដទៃទៀតដែរ ហើយក៏ទទួលទណ្ឌកម្មដូចពួកគេផងដែរ។ ខ្ញុំបានដាក់ចេញនូវអារម្មណ៍ថាខ្លួនខ្ញុំមិនស្មើអ្នកដទៃ។*

***គីគូឌី មារ*** *(Kikudi Marc)*
*CONEPT*
***សាធារណរដ្ឋប្រជាធិបតេយ្យកុងហ្គោ***

*ការអប់រំបរិយាបន្ន គឺជាវឌ្ឍនភាពក្នុងធម្មជាតិ ដើម្បីឈានទៅសម្រេចសិទ្ធិមនុស្សនៅក្នុងប្រព័ន្ធអប់រំ។ វាគឺជាអ្វីដែលយើងចាំបាច់ត្រូវធ្វើនៅគ្រប់ម៉ោងទាំងអស់។*

***ភឺស៊ី កាដូហ្សូ*** *(Percy Cardozo)*
***ប្រធានកម្មវិធី និងជាអ្នកផ្តល់ប្រឹក្សា***
***ប្រទេសឥណ្ឌា***

*យើងចាំបាច់ត្រូវបង្រៀនកុមារ ឱ្យចេះឆ្លើយតបចំពោះលក្ខណៈផ្សេងៗគ្នា ដោយមិនត្រូវចាត់ទុកវាថាជារឿងអវិជ្ជមាននោះឡើយ ប៉ុន្តែជាអ្វីដែលយើងអាចរៀនសូត្របាន ដើម្បីក្លាយជាមនុស្សកាន់តែល្អ ជាសិស្សកាន់តែល្អ និងជាពលរដ្ឋកាន់តែល្អ។*

***ហឺមីណូ កូរៀ*** *(Herminio Corrêa)*
***សមាជិកក្រុមប្រឹក្សាភិបាលអង្គការ*** *Parents International* ***ប្រទេសព័រទុយហ្គាល់***

Global Education Monitoring Report

United Nations Educational, Scientific and Cultural Organization

Sustainable Development Goals

4 QUALITY EDUCATION

Sustainable Development Goals